ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- អតីតកាលដែលនៅតែមានជីវិត
- មាគ៌ាឆ្ពោះទៅរកការផ្សះ-ផ្សាជាតិនៅកម្ពុជា

លេខ៩៣ ខែកញ្ញា ឆ្នាំ២០០៧

**ស្វែងរកការពិត**

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៤៥ ខែកញ្ញា ឆ្នាំ២០០៣

## មាតិកា

◆ សំបុត្រៈ អតីតកាលដែលនៅតែមានជីវិត ..............................១

**ផ្នែកឯកសារ**

◆ គ្រូបង្រៀននៅវត្តសំពៅមាស ..............................................៣

◆ បទខុសឆ្គងរបស់សមមិត្ត ឌុច ..............................................៨

◆ កំណត់ហេតុនៃការប្រជុំគណមន្ទីរអគ្គការ៧០៣ ........................១១

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១..........១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ខ្មែរស្រុះស្រួលគ្នាទើបខ្មែរបានសុខ ......................................១៤

◆ ឆ្លងកាត់បួនរបបដឹកនាំ ......................................................២០

◆ ខ្មែរក្រហមបានរំលោភសិទ្ធិកុមារយ៉ាងព្រៃផ្សៃបំផុត ................២៣

**ផ្នែកច្បាប់**

◆ តើអ្នកណាជាម្ចាស់នៃច្បាប់សង្គ្រាម? ..................................២៥

**ខេមិកាពិភាក្សាសាធារណៈ**

◆ ប្រសិនបើមេដឹកនាំខ្មែរក្រហមស្លាប់អស់ ...............................៣៥

◆ មាគ៌ាឆ្ពោះទៅរកការផ្សះផ្សាជាតិនៅកម្ពុជា ...........................៣៩

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ បញ្ជីឈ្មោះសមាជិកគ្រួសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ....៤៦

◆ ហេង ស៊ីនិត្យៈ រូបភាពជនដៃដល់ ......................................៤៩

◆ ភ្ជុំបិណ្ឌរំឭកដល់អ្នកស្លាប់ក្នុងរបបខ្មែរក្រហម .........................៥៣

◆ តែងតែរស់នៅក្នុងបេះដូងនិងអារម្មណ៍ ...............................៥៥

**សិល្បៈខ្មែរក្រហម**

◆ រូបថត ៖ អតីតកងទ័ពខ្មែរក្រហម ..............................ក្របក្រោយ



(រូបថតៈ ហេង ស៊ីនិត)

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ:** យិន នាន, សុខ វណ្ណៈ, ទុម ទិរ៉ា, យេណោត អាន់ជីសុន, ចូអាណា រ៉េបេកា ម៉ាន់សុន, ហ៊ុយ វណ្ណៈ **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សើ សាយ្យាណា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** ស្ល ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

*សំបុត្រ:*

# អតីតកាលដែលនៅតែមានជីវិត

ថ្ងៃបុណ្យភ្ជុំបិណ្ឌបានមកដល់ជាថ្មីម្តងទៀត ។ អស់រយៈពេល២៥ឆ្នាំហើយដែលបុណ្យភ្ជុំបិណ្ឌនៅប្រទេសយើងមានអត្ថន័យខុសប្លែកពីធម្មតា ដោយមូលហេតុថា ប្រជាជនទាំងអស់ដែលយកចង្ហាន់ទៅប្រគេនព្រះសង្ឃ គឺតែងតែបានឧទ្ទិសមគ្គផលដល់សាច់សាលោហិតដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ តាំងពីព្រះមហាក្សត្ររហូតដល់រាស្ត្រកសិករដែលរស់នៅចុងកាត់មាត់ញកក្នុងប្រទេសកម្ពុជាទាំងមូល គឺសុទ្ធតែមានសមាជិកគ្រួសារដែលត្រូវខ្មែរក្រហមធ្វើទារុណកម្មឬសម្លាប់ចោល ។

តើការទាមទារយុត្តិធម៌ពីរបបដ៏ព្រៃផ្សៃនេះចេះតែវិលចុះវិលឡើងដូចទឹកទន្លេបួនមុខ ដែលគ្រាន់តែជាការរំពុកឡើងវិញអំពីរដូវទឹកឡើងនិងទឹកស្រក ឬគ្រាន់តែដើម្បីជាការលួងចិត្តដល់ជនរងគ្រោះដោយគ្មានដំណោះស្រាយផ្លូវច្បាប់? តើឆន្ទៈពិតប្រាកដក្នុងការឲ្យមានតុលាការមាននៅក្នុងផ្នត់គំនិតអ្នកនយោបាយខ្មែរដែរឬទេ? តើគ្មានការរួបរួមគ្នានៅប្រទេសយើងដើម្បីយុត្តិធម៌ឬមួយយ៉ាងណា? តើយើងគួរទទួលយកទម្លាប់មួយថាយើងអាចរួបរួមគ្នាបានតែនៅក្នុងអំពើឧក្រិដ្ឋ ឬបិទបាំងកំហុសឬមួយយ៉ាងដូចម្តេចទៅវិញ? តើយើងបានរៀនសូត្រអំពីអតីតកាលដែរឬទេ?

ការរំលោភសិទ្ធិដែលបានធ្វើឲ្យមនុស្សរាប់លាននាក់ស្លាប់បាត់បង់ជីវិត ប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហម នឹងក្លាយជាបន្ទុកដ៏ធ្ងន់ធ្ងរដល់យុវវ័យជំនាន់ក្រោយ ប្រសិនបើបញ្ហានេះមិនត្រូវបានដោះស្រាយនាពេលបច្ចុប្បន្ន ។ បន្ទុកនេះនឹងក្លាយទៅជាចំណោទសង្គមដែលប្រទាក់ក្រឡាវេញស៊ីង ហើយនឹងប៉ះពាល់ដល់ការអភិវឌ្ឍន៍ជាតិនៅក្នុងថ្ងៃអនាគត ។

បុណ្យភ្ជុំបិណ្ឌឆ្នាំនេះមិនត្រឹមតែនាំមកនូវអតីតកាលដែលនៅតែមានជីវិតតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំមកនូវការពិចារណាជាថ្មីម្តងទៀតថាតើអ្នកនយោបាយកម្ពុជាមានការស្មោះត្រង់ដែរឬទេក្នុងការស្វែងរកការពិតនិងយុត្តិធម៌ជូនដល់ជនរងគ្រោះរាប់លាននាក់ ។

**ឆាំង យុ**

# ឯកសារជួយដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

កម្ពុជាកំពុងតែពុះពារដោះស្រាយបញ្ហាដែលបន្សល់ទុកដោយសង្គ្រាមស៊ីវិលបីទសវត្សរ៍ ។ ប្រជាជនកម្ពុជាប្រមាណពីរលាននាក់បានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ ការកំណត់ថាត្រូវផ្តន្ទាទោសដោយវិធីណាចំពោះជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ គឺជាកត្តាចាំបាច់ចំពោះការរស់ឡើងវិញរបស់ប្រទេសកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការស្វែងរកយុត្តិធម៌និងការផ្សះផ្សារបួសអតីតកាល ។

មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមែប្រមូលនិងចងក្រងយ៉ាងយកចិត្តទុកដាក់នូវរាល់ឯកសារទាំងឡាយទាក់ទងនឹងបទឧក្រិដ្ឋដែលបានធ្វើឲ្យប្រជាជនកម្ពុជាប្រហែលជាង២០ភាគរយបាត់បង់ជីវិត ។ ទន្ទឹមនឹងនេះដែរគឺជាការសំខាន់ណាស់ ដែលឯកសារ

ខ្មែរក្រហមនិងឯកសារពាក់ព័ន្ធដទៃទៀតត្រូវបានប្រមូលចងក្រងរក្សាទុកសម្រាប់អប់រំយុវវ័យជំនាន់ក្រោយឲ្យយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួន ។ យើងគ្រប់រូបក៏ជាផ្នែកមួយនៃប្រវត្តិ-សាស្ត្រដែរ ។ អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយវិធីម្យ៉ាងក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ គឺត្រូវវិនិច្ឆ័យបទឧក្រិដ្ឋទាំងនោះតាមផ្លូវច្បាប់ និងត្រូវយល់ដឹងនិងរៀនសូត្រអំពីអ្វីដែលបានកើតឡើង ។ ការយល់ដឹងអំពីអ្វីដែលបានកើតឡើង គឺជាអាវុធមួយដ៏ប្រសើរបំផុតសម្រាប់យើងទាំងអស់គ្នា ហើយវាគឺជាសន្តិវិធីក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យកើតឡើងសាជាថ្មី ។

មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានរៀបចំបញ្ជីសំណួរពិសេសសម្រាប់សួរអតីតកម្មាភិបាលខ្មែរក្រហមនិងជនដៃដល់ ពីព្រោះដោយមូលហេតុយើងបានដឹងជាមុនថា កម្មាភិបាលនោះធ្លាប់បានធ្វើអ្វី និងកំពុងធ្វើអ្វីនាពេលបច្ចុប្បន្ន ។ កិច្ចការបែបនេះគឺជាការគោរពដល់សិទ្ធិរបស់កម្មាភិបាលទាំងនោះ ។ ម្យ៉ាងទៀតយើងមិនមានចេតនាសួរសំណួរដែលផ្ចាញ់ផ្ចាលដល់កម្មាភិបាលទាំងនោះឡើយ ។ ផ្ទុយទៅវិញយើងបានរៀបចំសំណួរ សំដៅធ្វើយ៉ាងណាឲ្យក្រុមកម្មាភិបាលយល់ថាខ្លួនជាអ្នកណា បានជួបប្រទះអ្វីខ្លះ និងបានធ្វើអ្វីខ្លះ ។

របបខ្មែរក្រហមបានរៀបចំឯកសារកម្មេចខ្មាំងរបស់ខ្លួនដោយផ្ចិតផ្ចង់បំផុត ។ ខ្មែរក្រហមមានបំណងថែរក្សាឯកសារនិងចងក្រងឯកសារគ្រប់បែបយ៉ាង ដោយខ្លួនយល់ឃើញថាឯកសារទាំងនោះគឺជាឆពណ្ណរង្សី និងគឺជាជ័យជម្នះរបស់ខ្លួន ពីព្រោះឯកសារទាំងនេះបញ្ជាក់ថា ខ្លួនមានលទ្ធភាពកម្ទេចខ្មាំងជាបន្តបន្ទាប់ និងជារៀងរាល់ថ្ងៃ ។ កិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺចងក្រងឯកសារខ្មែរក្រហមទាំងអស់ ធ្វើយ៉ាងណាឲ្យកាន់តែមានលក្ខណៈងាយស្រួលសម្រាប់សាធារណជនទូទៅក្នុងការស្រាវជ្រាវ ។ ជាមូលដ្ឋានគឺយើងប្រមូលឯកសារ និងរៀបចំចុះបញ្ជីត្រឹមត្រូវដើម្បីឲ្យសាធារណជនទទួលបាននូវឯកសារដែលចង់បានដោយចំណាយពេលតិចប៉ុន្តែមានប្រសិទ្ធភាព ។

គោលបំណងសំខាន់បំផុតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺសំដៅធ្វើជាកន្លែងផ្តល់សារអចិន្ត្រៃយ៍ដល់ជនដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងដល់ជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ធ្វើយ៉ាងដូចនេះគឺដើម្បីឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាក្លាយ ១) ជាកន្លែងដែលជនរងគ្រោះអាចទុកនូវអតីតកាលដែលកន្លងផុតទៅ ២) ជាកន្លែងដែលជនរងគ្រោះអាចស្វែងរកពត៌មានដើម្បីផ្សះផ្សា និងលែងវិលវល់នឹងអតីតកាល ៣) ជាកន្លែងដែលជនដៃដល់អាចរកវិធីក្នុងការសារភាពឬនិយាយប្រាប់នូវរឿងរ៉ាវរបស់ខ្លួន ៤) ជាកន្លែងដែលអ្នកផ្សេងទៀតអាចស្វែងយល់អំពីរឿងរ៉ាវទាំងនេះ ៥) ជាកន្លែងដែលបេក្ខជនអនុបណ្ឌិតឬបណ្ឌិតអាចសរសេរនិក្ខេបបទរបស់ខ្លួនបាន ហើយក៏ជាប្រភពឯកសារសម្រាប់កម្មវិធីសិក្សានៅតាមសាលាដើម្បីផ្តល់មេរៀនប្រវត្តិសាស្ត្រខ្មែរក្រហមដល់សិស្សសាលានៅក្នុងប្រទេសកម្ពុជា ។

តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមានការពិភាក្សាដេញដោលនៅក្នុងសហគមន៍អន្តរជាតិនិងនៅក្នុងប្រទេសកម្ពុជាដែលដូចគ្នាទៅនឹងការពិភាក្សាដេញដោលដែលធ្វើឡើងនៅអតីតយូហ្គោស្លាវី និងរ៉ូវ៉ាន់ដា និងដូចគ្នាទៅនឹងតុលាការនានាក្រោយសង្គ្រាមលោកលើកទីពីរដែរ ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងកើតឡើង ហើយឯកសារដែលយើងប្រមែប្រមូលបាននឹងក្លាយជាឯកសារដែល«អាចមានតម្លៃ»ជាភ័ស្តុតាង ។ យើងនឹងផ្តល់ពត៌មានដល់មេធាវីការពារក្តី និងដល់ព្រះរាជអាជ្ញា ។ ប៉ុន្តែយើងមិនមែនជាអ្នកក្រសោបអ្វីគ្រប់យ៉ាងតែម្នាក់ឯងនោះទេ ។ ខ្ញុំសង្ឃឹមថា នៅពេលដែលមានតុលាការកើតឡើង ខ្ញុំជឿជាក់ថាយើងមានពត៌មានគ្រប់គ្រាន់ ។ តុលាការនឹងមិនចាប់ផ្តើមដំណើរការជាមួយសាក្សីតែម្នាក់ ប៉ុន្តែតុលាការនឹងចាប់ផ្តើមឡើងជាមួយនឹងសាក្សីរាប់ម៉ឺននាក់ ឯកសាររាប់សែនសន្លឹក ព្រមទាំងរូបថតរាប់ពាន់សន្លឹក និងរណ្តៅសាកសពរាប់ម៉ឺនរណ្តៅ ។ នេះសបញ្ជាក់ឲ្យឃើញថាយើងមានពត៌មានដ៏ច្រើនសន្ធឹកសន្ធាប់ដើម្បីគាំទ្រដំណើរការតុលាការ ។ មេធាវីការពារក្តីនិងទាំងព្រះរាជអាជ្ញា និងសាធារណជនទូទៅគួរតែមានសិទ្ធិទទួលបាននូវឯកសារដូចៗគ្នា ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# អតីតគ្រូបង្រៀននៅវត្តសំពៅមាស

នូ ផួន គឺជាគ្រូបង្រៀននៅសាលាបឋមសិក្សាវត្តសំពៅមាស ក្រុងភ្នំពេញ ដែលបានទៅបន្តការសិក្សាផ្នែកប្រវត្តិសាស្ត្រនៅប្រទេសបារាំងរហូតដល់ឆ្នាំ១៩៧៦ទើបត្រឡប់មកប្រទេសកម្ពុជាវិញ។ នូ ផួន ត្រូវអង្គការសម្លាប់ចោលនៅថ្ងៃ២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីបានសួរចម្លើយអស់រយៈពេលបួនថ្ងៃ។

ខាងក្រោមជានេះសេចក្តីសង្ខេបចម្លើយសារភាពរបស់ នូ ផួន÷

នូ ផួន មានស្រុកកំណើត នៅភូមិក្រាំងចេក ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

នូ ផួន បានសិក្សានៅបឋមសិក្សាខេត្តកំពង់ស្ពឺចាប់តាំងពីឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៦៣។ នៅពេលនោះ នូ ផួន និងមិត្តភក្តិជិតស្និទ្ធតែងតែត្រូវលោកគ្រូៗរបស់ខ្លួនអប់រំឲ្យជឿតាមគំនិតគាត់រៀងៗខ្លួន។ ក្នុងនោះលោកគ្រូ ជា សារ៉ង់ គឺអប់រំឲ្យស្អប់ចលនារបស់ប្រជាជនបដិវត្តក្នុងការតស៊ូទាមទារឯករាជ្យពីអាណានិគមបារាំង។ ឆ្នាំ១៩៦០ នូ ផួន ត្រូវបានលោកគ្រូឈ្មោះ ជួប សារឿន អប់រំឲ្យចេះស្រឡាញ់បុណ្យស័ក្តិ ហ៊ឺហាតាមរបៀបអ្នកក្រុង។ ឆ្នាំ១៩៦១ លោកគ្រូ សៀង ណៃ បានពន្យល់ណែនាំ នូ ផួន ថា ប្រជាជនបដិវត្តគឺជាអ្នកបម្រើយួន ហើយពួកអាណានិគមនិយមបារាំង គឺជាអ្នកនាំមកនូវការរីកចម្រើនលូតលាស់គ្រប់បែបយ៉ាងដល់ប្រទេសកម្ពុជា។ ឆ្នាំ១៩៦៣ នូ ផួន បានមកបន្តការសិក្សានៅវិទ្យាល័យព្រះយុគន្ធរក្រុងភ្នំពេញ។ នូ ផួន ត្រូវមិត្តភក្តិជាច្រើនពន្យល់ឲ្យខ្លួនមានគំនិតប្រឆាំងនឹងយុវជនបដិវត្តដែលរៀននៅក្នុងសាលារៀនជាមួយគ្នា។ ឆ្នាំ១៩៦៤ នូ ផួន បានចូលរៀនភាសាអង់គ្លេសជាមួយសាស្ត្រាចារ្យជនជាតិអាមេរិកាំងម្នាក់ឈ្មោះ វីស្ហាល់។ សាស្ត្រាចារ្យរូបនេះ បានពន្យល់បង្ហាញ នូ ផួន អំពីការរីកលូតលាស់ផ្នែកសេដ្ឋកិច្ច និងនយោបាយរបស់សហរដ្ឋអាមេរិក ហើយថែមទាំងបង្ហាញថាសហរដ្ឋអាមេរិកនឹងបន្តជំនួយសេដ្ឋកិច្ចនិងយោធាដល់ប្រទេសកម្ពុជាឲ្យលូតលាស់តទៅទៀត។

ខែឧសភា ឆ្នាំ១៩៦៦ នូ ផួន និងមិត្តភក្តិឈ្មោះ ជា យុត, សំ អឿន, ឈាង ទូច, អ៊ូ វ៉ាន់ឌី, ព្រំ សង្វា និង ប៊ុច ឈន់ បាននាំគ្នាចូលជាសមាជិកសេ.អ៊ី.អា នៅស្ថានទូតអាមេរិកប្រចាំកម្ពុជា តាមរយៈ វីស្ហាល់។ លក្ខខណ្ឌនៃការចូលនោះ ដំបូងមានចុះហត្ថលេខាលើកិច្ចសន្យានិងបំពេញការងារផ្សេងៗរបស់អង្គការ សេ.អ៊ី.អា អាមេរិកនៅកម្ពុជាដោយដើរស៊ើបរកមើលខ្សែបណ្តាញរបស់ចលនាបដិវត្តនៅគ្រប់ទីកន្លែង ឃោសនានយោបាយចិត្តសាស្ត្រដល់ប្រជាជនកម្ពុជានៅក្នុងប្រទេសនិងស្វែងរកភ្នាក់ងារថ្មីៗដែលមានចិត្តស្មោះត្រង់មិនវៀចវេរ និងអនុវត្តការងាររបស់អង្គការ សេ.អ៊ី.អា ដោយគ្មានលក្ខខណ្ឌ។ នូ ផួន បានទទួលប្រាក់ឧបត្ថម្ភចំនួន៤០០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែពីអង្គការនេះ។

ខែធ្នូ ឆ្នាំ១៩៦៦ នូ ផួន បាននាំមិត្តភក្តិប្រាំនាក់ទៀតឲ្យចូលជាសមាជិក សេ.អ៊ី.អា ដែរ។

### ក) សកម្មភាពនៅសាលាយុគន្ធរ

ឆ្នាំ១៩៦៧ នូ ផួន និងឈ្មោះ ជាយុត, សំអឿន ដែលមានគំនិតប្រឆាំងនឹងចលនាបដិវត្តបានឃោសនាឲ្យមានចលនាប្រឆាំងនឹងបដិវត្តក្នុងពេលដែលសភាពការណ៍កំពុងតែចលាចលហើយបានរាយការណ៍ទៅឲ្យក្រសួងសម្ងាត់របស់ឧត្តមសេនីយ៍ លន់ ណុល ឲ្យចាប់មេដឹកនាំនិស្សិតបដិវត្តនៅក្នុងវិទ្យាល័យនេះទៅព្រមាន។ ក្រោយពីនោះទៀត នូ ផួន និង ចាន់ គីស៊ុយ បានរាយការណ៍ទៅឲ្យមេប៉ូលិសម្នាក់ឈ្មោះ ស៊ីជួ ថានៅក្នុងវិទ្យាល័យយុគន្ធរ មានសិស្សខ្មែរក្រហម៣នាក់ ឈ្មោះ ម៉ែន ជន់, ម៉ែន សារូ និង កែ ស្រេង កំពុងធ្វើសកម្មភាពប្រឆាំងនឹងកងទ័ពជាតិ។ ប៉ុន្មានថ្ងៃក្រោយមកសិស្សទាំងបីត្រូវបានចាប់ខ្លួនទៅសួរចម្លើយដើម្បីតាមចាប់មេដឹកនាំធំៗ។ បួនខែក្រោយ នូ ផួន បានផ្តល់

ដំណឹងដល់ ស៊ីជួ ម្តងទៀតឲ្យមកចាប់សិស្សម្នាក់ឈ្មោះ ឡុច សឿន ដែលជាសមាជិកសមាគមមួយមានទីស្នាក់ការនៅផ្លូវត្រសក់ផ្អែម ។ នៅខែធ្នូ បន្ទាប់ពីបានចូលរួមសកម្មភាពចាប់ខ្មែរក្រហមនៅភ្នំពេញរួច នូ ងួន ក៏បាននាំមិត្តរបស់ខ្លួន៥នាក់ឈ្មោះ ស ចំរើន, ចាន់ គីស៊ុយ, ជា ចំរើន, នុប ភិវ៉ាន់, សុខ មុនី ចូលជាភ្នាក់ងារសេ.អ៊ី.អា នៅផ្ទះរបស់សាស្ត្រាចារ្យ វិស្ហាល់ ។

### ខ) វិទ្យាល័យស៊ីសុវត្ថិ

ឆ្នាំ១៩៦៨-៦៩ ជាឆ្នាំដែលត្រូវបញ្ចប់ការសិក្សានៅវិទ្យាល័យ នូ ងួន និងមិត្តបីនាក់បានផ្លាស់ទៅរៀននៅវិទ្យាល័យស៊ីសុវត្ថិ ។ នៅចន្លោះឆ្នាំនេះ នូ ងួន និងមិត្តភក្តិទាំងបី បានធ្វើសកម្មភាពយ៉ាងច្រើននៅក្នុងសាលា ដោយរាយការណ៍ទៅប៉ូលិសស៊ីជួ ឲ្យចាប់លោកគ្រូ ម៉ៅ រុន បង្រៀននៅសាលាបឋមសិក្សានាគវ័នពីបទឃោសនាចេញមុខនៅក្នុងជួរបុគ្គលិកសិក្សាប្រឆាំងនឹងសកម្មភាពរបស់កងទ័ពជាតិ ដែលធ្វើការឆែកឆេរផ្ទះរបស់ ហ៊ូ យន់, ខៀវ សំផន និង ហ៊ូ នឹម ដើម្បីរកឯកសារភ័ស្តុតាងវិទ្ធង្សនាប្រឆាំងនយោបាយប្រទេសជាតិ (ក្រោយមក ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម បានបាត់ខ្លួន) និងសិស្សពីរនាក់ទៀតឈ្មោះ ចែម នាង និង ឌុច ប្រាង នៅវិទ្យាល័យស៊ីសុវត្ថិពីបទថា សិស្សទាំងពីរនាក់នេះបានបិទខិត្តប័ណ្ណជំរុញឲ្យសិស្សនៅក្នុងសាលាចូលរួមបះបោរនឹងសារពត៌មានខ្មែរឯករាជ្យមួយដែលបានសរសេរប្រមាថមើលងាយក្មេងវត្ត ។

ឆ្នាំ១៩៦៩ នូ ងួន មិត្តភក្តិពីរនាក់ និងសាស្ត្រាចារ្យឈ្មោះ សាំង សារូ (អគ្គានុរក្ស) តែងតែធ្វើសកម្មភាពប្រឆាំងនឹងនិស្សិតបដិវត្តជានិច្ច ហើយរាយការណ៍ពីសិស្សឈ្មោះ អ៊ួង សាវ៉ាត និង កែវ អុន ថាអ្នកទាំងនោះបានឃោសនាថា សម្តេច សីហនុ និង លន់ ណុល ជាអ្នកសម្លាប់តំណាងរាស្ត្រទាំងបី ហើយថែមទាំងបានចោទប្រកាន់សម្តេច សីហនុ និង លន់ ណុល ថាធ្វើនយោបាយលក់ជាតិឲ្យអាមេរិកាំង ។ សិស្សទាំងពីនាក់នេះក្រោយមកក៏ត្រូវស៊ីជួ ចាប់ខ្លួនដែរ ។

### គ) សាលាគរុកោសល្យ

ឆ្នាំ១៩៧០ នូ ងួន បានចូលសិក្សានៅមហាវិទ្យាល័យគរុកោសល្យ ។ ឆ្នាំនោះ គាត់បានធ្វើសកម្មភាពច្រើនជាមួយនិស្សិតគ្រូបង្រៀននិងសាស្ត្រាចារ្យនៅក្នុងមហាវិទ្យាល័យដោយបំផុសឲ្យនិស្សិតគ្រូៗចូលរួមធ្វើបាតុកម្មប្រឆាំងនឹងយួនកុម្មុយនិស្តដែលមកតាំងលំនៅនៅតាមព្រំដែនខាងកើតនៃទឹកដីកម្ពុជា ។ នូ ងួន បានសរសេរថា ខែមីនា ឆ្នាំ១៩៧០នេះ អង្គការសេ.អ៊ី.អា មានផែនការបញ្ចូលប្រទេសកម្ពុជាឲ្យទៅជាមូលដ្ឋានសឹកសម្រាប់ធ្វើសង្គ្រាមទប់ទល់នឹងចលនាកុម្មុយនិស្តឥណ្ឌូចិន ។ ដោយអនុវត្តទៅតាមផែនការៈ ទី១) ទប់ទល់នឹងសកម្មភាពរបស់ខ្មែរក្រហមដែលនៅសេសសល់ ផ្តួលរំលំអ្នកកាន់អំណាចមួយចំនួននៅក្នុងរដ្ឋាភិបាល និងរដ្ឋសភាដែលមានបំណងប្រឆាំងនឹងកងទ័ពជាតិ និងទី២) បង្ខំឲ្យរដ្ឋសភាបោះឆ្នោតជាចំហដើម្បីចោទបង្កាច់ សម្តេច សីហនុ ថាជាអ្នកលក់ទឹកដីឲ្យយៀកកុង ។

នៅដើមខែមេសា មេខ្មែរក្រហមមួយចំនួនបានបាត់ខ្លួន ហើយមួយចំនួនទៀតត្រូវបានចាប់ឃុំឃាំង ។ នូ ងួន និងសមាជិក៨នាក់ទៀតបានប្រជុំរៀបចំគម្រោងធ្វើបាតុកម្មនិងក្តាប់សភាពការណ៍ជុំវិញខ្លួនក្រែងមានការរំដើបរំជួលនៅក្នុងទីក្រុងភ្នំពេញ ។ នូ ងួន បានបញ្ចូលគ្រូបង្រៀនបីនាក់ឈ្មោះ ឃ្លោក យ៉ុម, វ៉ាន់ ថេត និង ជូ ផល្លី និងបញ្ចុះបញ្ចូលរហូតដល់គាត់ទាំងបីសុខចិត្តចូលជាភ្នាក់ងារសេ.អ៊ី.អា ។

ការងារជាបន្តបន្ទាប់របស់ នូ ងួន និងសមាជិករបស់គាត់គឺតាមស៊ើបរកខ្សែរយៈយួនកុម្មុយនិស្តដែលបង្កប់ខ្លួននៅភ្នំពេញ ។ នូ ងួន បានរកឃើញនិងរាយការណ៍ឲ្យ ស៊ីជួ ទៅចាប់ខ្លួនជនដែលសង្ស័យមកសួរចម្លើយជាបន្តបន្ទាប់ ។

ឆ្នាំ១៩៧១ នូ ងួន បានទៅបង្រៀននៅសាលាបឋមសិក្សាបាក់ទូក ។ ជាមួយនឹងការងារបង្រៀននេះ គាត់បានបំពេញការងាររបស់ខ្លួនមួយទៀត គឺបញ្ចុះបញ្ចូលគ្រូបង្រៀនបីនាក់ឈ្មោះ ប៊ុន ទី, ម៉ុក ស៊ុន និង អ៊ាវ យាត ដែលកំពុងបំពេញសំណុំបែបបទចូលបម្រើកងទ័ពសាធារណរដ្ឋឲ្យផ្លាស់ប្តូរចិត្តទៅធ្វើជាគ្រូដដែលព្រមទាំងសុំចូលជាភ្នាក់ងារសេ.អ៊ី.អា ។ អ្នកទាំងអស់នេះត្រូវបាន នូ ងួន បញ្ជូនឲ្យទៅបង្កប់ខ្លួននៅតាមតំបន់រំដោះនានា ដូចជាខេត្តកំពង់ចាម និងខេត្តក្រចេះជាដើម ។ ម៉ុក ស៊ុន បានបាត់ខ្លួន ។ ចំណែក ប៊ុន ទី ត្រូវស្លាប់ដោយសារការប៉ះទង្គិចរវាងកងទ័ពបដិវត្តនិងកងទ័ពសាធារណរដ្ឋខ្មែរ ។ នៅខែ

វិច្ឆិកា នូ ឌួន បានបន្តបេសកកម្មរបស់ខ្លួននៅផ្សារកំពង់ត្រាំ ក្នុងខេត្តកំពង់ស្ពឺ ហើយបានរាយការណ៍ទៅថ្នាក់លើឲ្យចាប់ជនសង្ស័យចំនួនបីនាក់ជាកម្លាំងរបស់អង្គការបដិវត្តដែលមកបង្កប់ខ្លួនក្នុងជួរកងទ័ពសាធារណរដ្ឋខ្មែរនិងម្នាក់ទៀតដែលចូលទៅបញ្ចុះបញ្ចូលឲ្យបុគ្គលិកសិក្សានៅសាលាបាក់ទូករត់ចូលព្រៃ ។

ឆ្នាំ១៩៧២ នូ ឌួន បានចូលរៀននៅមហាវិទ្យាល័យអក្សរសាស្ត្រមនុស្សសាស្ត្រនិងនៅមហាវិទ្យាល័យច្បាប់ ។ ពេលនោះ នូ ឌួន ចាប់ផ្តើមស៊ើបរកនិស្សិតបដិវត្តនៅទីនោះតាមការចាត់តាំងរបស់អង្គការសេ.អ៊ី.អា ។ មានពេលមួយក្នុងអង្គប្រជុំជាមួយសមាគមនិស្សិតនៅមហាវិទ្យាល័យ នូ ឌួន បានឡើងបញ្ចេញយោបល់ដើម្បីបញ្ចុះបញ្ចូលនិស្សិតទាំងនោះឲ្យប្រឆាំងនឹងការវាយប្រហារផ្នែកយោធារបស់កងទ័ពបដិវត្តនៅក្នុងខេត្តតាកែវនិងខាងត្បូងភ្នំពេញ ប៉ុន្តែមាននិស្សិតម្នាក់ក្នុងចំណោមនោះ ឈ្មោះ ថាន់ ណារ៉ាក់ បានងើបឡើងប្រឆាំង ហើយដាក់ទោសទៅលើរដ្ឋាភិបាល លន់ ណុល ថា ជារដ្ឋាភិបាលផ្តាច់ការ យោធានិយមនិងថ្កោលទោសចក្រពត្តិអាមេរិកជាអ្នកនាំវិនាសកម្មចូលប្រទេសកម្ពុជា ។ និស្សិតទាំងអស់សុទ្ធតែគាំទ្រគំនិតរបស់ ថាន់ ណារ៉ាក់ លើកលែងតែមិត្តថ្មី៥នាក់របស់ នូ ឌួន ប៉ុណ្ណោះ ។ និស្សិតម្នាក់នេះត្រូវ នូ ឌួន ផ្តល់ដំណឹងមកឲ្យ ស៊ីដូ ចាប់ខ្លួនយកទៅឃុំឃាំង ហើយក្រោយមកបានចាប់និស្សិតមហាវិទ្យាល័យច្បាប់ឆ្នាំទី២ ម្នាក់ទៀតឈ្មោះ សុធារី បន្ទាប់ពីបានរកឃើញថា ឈ្មោះនេះជាអ្នកសរសេរខិត្តប័ណ្ណបាចអំពាវនាវឲ្យនិស្សិតងើបឡើងប្រឆាំងនឹងចក្រពត្តិអាមេរិក, លន់ ណុល, សិរីមតៈ និង សឺង ង៉ុកថាញ់ និងឲ្យចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជាដើម្បីរំដោះប្រទេសឲ្យផុតពីសង្គ្រាមវិនាសកម្មដែលបង្កឡើងដោយចក្រពត្តិអាមេរិកនិងបរិវារនៅភ្នំពេញ បាងកក និង ព្រៃនគរ ។

នៅក្នុងខែមិថុនា ការបះបោររបស់និស្សិតបានរីករាលដាលគ្រប់មហាវិទ្យាល័យទាំងអស់នៅទីក្រុងភ្នំពេញ ហើយបាតុកម្មរបស់ក្រុមយុវជននៅតាមវិទ្យាល័យនិងនៅជនបទនានាក៏បានផ្ទុះឡើងព្រមគ្នា ។ នូ ឌួន, ស៊ីដូ និងភ្នាក់ងាររបស់ខ្លួនបានបន្លំខ្លួនចូលក្បួនបាតុកម្មដែរ ដោយបានចាប់ឈ្មោះ ប៊ុន រឿន ជាអ្នកដឹកនាំសិស្សនិស្សិតបះបោរឲ្យមានកំហឹងបដិវត្ត ។ បន្ទាប់មកបានបន្តចាប់សាស្ត្រាចារ្យបួននាក់ទៀត នៅមហាវិទ្យាល័យអក្សរសាស្ត្រឈ្មោះ នួន យឿន, ថាន់ ណារ៉ាក់, យិន យិតដល, ដា ប្លែង និងនិស្សិត ឈ្មោះ ខៀវ សេរីវ៉ាត់, ជុំ សុដល និង ហុយ ម៉ៅ ដែលឈ្មោះនេះមាននៅក្នុងឯកសាររបស់ ប៊ុន រឿន ។ បន្ទាប់ពីបាតុកម្មនិងសកម្មភាពចាប់ខ្មែរក្រហមនៅក្នុងជួរនិស្សិតរួចមក នូ ឌួន និងភ្នាក់ងាររបស់ខ្លួនបានទៅឃោសនារកសំឡេងឆ្នោតឲ្យ អ៊ិនតាំ ដែលជាបេក្ខជនឈរឈ្មោះនៅខេត្តបាត់ដំបង ។ នៅខែកក្កដា នូ ឌួន បានបញ្ចប់សកម្មភាពរបស់ខ្លួន ដើម្បីរៀបចំសំណុំលិខិតឆ្លងដែនទៅសិក្សាផ្នែកប្រវត្តិសាស្ត្រទៅប្រទេសបារាំង ។

### ឃ) ការងារក្រៅប្រទេស

នៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧២ នូ ឌួន បានទៅដល់ប្រទេសបារាំង ។ នូ ឌួន ត្រូវបានទទួលស្វាគមន៍ពីនិស្សិតខ្មែរម្នាក់ដែលជាតំណាងរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំនៅប្រទេសបារាំងឈ្មោះ សំ ប៊ុន ហើយបាននាំគាត់ឲ្យទៅស្នាក់នៅផ្ទះខ្មែរដែលមានក្រុមនិស្សិតខ្មែរជាច្រើនរស់នៅទីនោះ ។ នូ ឌួន បានស្គាល់និស្សិតខ្មែរជាច្រើននាក់ ដែលមានឈ្មោះ ស៊ី ផុន, គឹម វ៉ា, អ៊ុក ថុល, យ៉ាវ លី, ប៊ុន នី និងសាស្ត្រាចារ្យ កេង វ៉ាន់សាក់ ។ អ្នកទាំងនោះភាគច្រើនគឺជាអ្នកប្រឆាំងនឹងបដិវត្តរបស់ប្រជាជនកម្ពុជាដែរ ។

ខែកក្កដា ឆ្នាំ១៩៧៣ នូ ឌួន បានទៅធ្វើការនៅសមាគមមួយឈ្មោះសមាគមនិស្សិតសាធារណរដ្ឋខ្មែរនៅប្រទេសបារាំងតាមរយៈសាស្ត្រាចារ្យ កេង វ៉ាន់សាក់ ។ ខែតុលា នូ ឌួន បានចូលរួមការប្រជុំមួយដែលដឹកនាំដោយ កេង វ៉ាន់សាក់ នៅក្នុងស្ថានទូតខ្មែរប្រចាំប្រទេសបារាំង ស្តីអំពីការបង្ក្រាបចលនាបដិវត្តរបស់យុវជននិងនិស្សិតខ្មែរក្រហមនៅទីក្រុងភ្នំពេញនិងខេត្តនានា ។ កម្មវិធីប្រជុំនោះមាន «១) បង្ក្រាបចលនានិស្សិតយុវជន និងបុគ្គលិកសិក្សាដែលបម្រើសកម្មភាពខ្មែរក្រហម ២) បញ្ចូលចលនាបះបោរនេះឲ្យចូលបម្រើក្នុងកងយោធាសាធារណរដ្ឋនិងការសម្រុះសម្រួលចលនានិស្សិតនិងក្រុមយោធាសាធារណរដ្ឋ» ។ ក្រោយមក នូ ឌួន បានចូលបម្រើសកម្មភាពនៅសមាគមមួយដែលបង្កើតឡើងដោយនិស្សិតបួននាក់ឈ្មោះ អ៊ុក ថុល និស្សិតខាងសេដ្ឋកិច្ចនៅមហាវិទ្យាល័យប៉ារីសទី១ ស៊ីផុន, គឹមវ៉ា

និងយ៉ាវលី និស្សិតមហាវិទ្យាល័យឱសថសាស្ត្រ ។ សមាគមនេះបង្កើតឡើងដើម្បីធ្វើយុទ្ធនាការឃោសនាប្រឆាំងនឹងបដិវត្តរបស់ប្រជាជនកម្ពុជាដែលមាននៅក្រៅប្រទេស ។

ឆ្នាំ១៩៧៤ នូ ផួន បានចូលបម្រើការនៅក្នុងអង្គការមួយតាមរយៈសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រ៣រូបឈ្មោះ ឆេណូ ហ្សង់, ប៊ូដាវែល និងអេម៉ើរី ។ នៅក្នុងអង្គការនោះមាននិស្សិតគ្រប់សញ្ជាតិ ។ នូ ផួន ត្រូវបានសាស្ត្រាចារ្យ ឆេណូ ហ្សង់ ឧបត្ថម្ភថវិកាយ៉ាងច្រើនសម្រាប់សិក្សាស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រគ្រប់សម័យកាលនៃមនុស្សជាតិ ពិសេសគឺស្រាវជ្រាវអំពីប្រវត្តិ និងមុខងាររបស់បញ្ញាជនកម្ពុជាក្នុងការកសាងវប្បធម៌និងនយោបាយចាប់តាំងពីឆ្នាំ១៩៥៨ដល់ឆ្នាំ១៩៧៥ ។ ក្រោមការឧបត្ថម្ភពី ឆេណូ ហ្សង់ បានធ្វើឲ្យគាត់បានបន្តការសិក្សាបរិញ្ញាប័ត្រផ្នែកប្រវត្តិសាស្ត្រនៅមហាវិទ្យាល័យអក្សរសាស្ត្រប៉ារីសទៀត ។ នូ ផួន បានទទួលការអប់រំពីសាស្ត្រាចារ្យជនជាតិបារាំងជាច្រើនអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា ពិសេសនយោបាយរបស់អង្គការបដិវត្តដែលបានជម្លៀសប្រជាជនចេញពីទីក្រុងនាថ្ងៃ១៧ មេសា ១៩៧៥ ថា ជានយោបាយដែលដើរខុសឆ្គងប្រឆាំងនឹងមាគ៌ាបដិវត្តន៍នៅគ្រប់ប្រទេសសង្គមនិយមក្នុងលោក ។

ក្រោយមក ដោយសារថា ការសិក្សាផ្នែកនេះពុំមានទាក់ទងទៅនឹងស្ថានការណ៍ពិតរវាងការស្រាវជ្រាវផ្នែកទ្រឹស្តីនិងការជាក់ស្តែងបានធ្វើឲ្យការសិក្សារបស់គាត់ត្រូវផ្អាកនៅឆ្នាំ១៩៧៦ ។ ចំណែកឯការទំនាក់ទំនងជាមួយសាស្ត្រាចារ្យបារាំងនិងសាស្ត្រាចារ្យខ្មែរនៅតែមានបន្ត ។

នៅក្នុងឆ្នាំ១៩៧៤ នូ ផួន បានចូលរួមសម័យប្រជុំផ្សេងៗជាមួយនិស្សិតខ្មែរឯទៀតៗ នៅទីក្រុងប៉ារីសដែលក្រុមនិស្សិតខ្មែរទាំងនោះ សុទ្ធតែអ្នកប្រឆាំងនឹងបដិវត្តន៍ប្រជាជនកម្ពុជា និងជាអ្នកបម្រើឲ្យអង្គការសេ.អ៊ី.អា ដែលមានខ្សែរយៈនៅប្រទេសបារាំង និងប្រទេសថៃ ។ នូ ផួន ក៏បានជួបនិស្សិតខ្មែរមួយចំនួនទៀតឈ្មោះ យិន យិតធល និង ឡុច សឿន ប្រធានសមាគមនិស្សិត, គុន ថាណារ៉ាក់ អនុប្រធាន ។ យិន យិតធល និង ហុង អ៊ាវដា (វេជ្ជបណ្ឌិត) បានបបួលគាត់ឲ្យត្រឡប់មកប្រទេសកម្ពុជាវិញដើម្បីកសាងខ្លួនក្នុងមាគ៌ាបដិវត្ត ។ ប៉ុន្តែ នូ ផួន មិនបានត្រឡប់មកកម្ពុជាតាមអ្នកទាំងពីរទេ ។

នៅខែសីហា នូ ផួន បានទទួលដំណឹងអំពីសភាពការណ៍នៅកម្ពុជាតាមរយៈនិស្សិតខ្មែរនៅប្រទេសបារាំង៣នាក់ឈ្មោះ យិន សុខ, ថោង ដាន និង ហុក ឌី (ឈ្មោះទាំងបីនេះកំពុងបម្រើនយោបាយវិទ្យុផ្សាយរបស់អាមេរិកាំង) ថា "យួនកុម្មុយនិស្តបានមកតាំងនៅក្នុងស្រុកខ្មែរខាងកើតទន្លេមេគង្គ ចំណែកផ្នែកខាងលិចទន្លេមេគង្គពួកខ្មែរក្រហមចែកជាបក្សពួកវាយដណ្តើមអំណាចនៅក្នុងទីក្រុងភ្នំពេញនិងប្រព្រឹត្តការកាប់សម្លាប់ប្រជាជនស្លូតត្រង់នៅក្នុងក្រុងនិងខេត្តនានាយ៉ាងសាហាវឃោរឃៅ" ។

ឆ្នាំ១៩៧៦ នូ ផួន បានចូលរួមប្រជុំមួយនៅបូរីអន្តរជាតិដែលមានខ្មែរនិងបរទេសចំនួន៣០នាក់ចូលរួម ។ អ្នកទាំងអស់នេះខ្លះជាទាហានរបបសាធារណរដ្ឋខ្មែរដែលភៀសខ្លួននិងខ្លះទៀតជាភ្នាក់ងាររបស់សេ.អ៊ី.អា ។ យិន សុខ, បាន សៀង, គឹម ហួត និង ថោង ដាន បានឃោសនាថា ទឹកដីកម្ពុជាបានពុះច្រៀកផ្នែកខាងកើតខេត្តស្វាយរៀងនិងព្រៃវែងនិងកោះខ្លះនៅតាមសមុទ្រទៅឲ្យវៀតណាមដោយសារថា ទី១ប្រជាជនកម្ពុជាគ្មានសមត្ថភាពនឹងត្រួតពិនិត្យទឹកដីទាំង១៨១ពាន់គីឡូម៉ែត្រក្រឡា ទី២ដើម្បីជាការសងគុណដល់សម្ព័ន្ធមិត្តវៀតណាមដែលបានជួយច្បាំងយកអំណាចឲ្យខ្មែរក្រហម ។ ខែមិថុនា នូ ផួន បានចូលរួមប្រជុំជាមួយនិស្សិតខ្មែរនៅប្រទេសបារាំង ដែលអ្នកទាំងអស់នោះពីមុនមកធ្លាប់បានរួមសកម្មភាពប្រឆាំងនឹងបដិវត្តន៍ជាមួយគ្នា ។ នូ ផួន និងនិស្សិតប្រឆាំងនឹងបដិវត្តន៍មួយចំនួនបានរៀបចំផែនការមួយបញ្ជូនឈ្មោះ ចាន់ សៀង, គឹម ហួត និង អៀង ឈុន ចូលមកប្រទេសកម្ពុជាដើម្បីទាក់ទងជាមួយអ្នកដែលប្រឆាំងបដិវត្តន៍និងនិស្សិតមួយចំនួនដែលចូលមកប្រទេសមុនមានឈ្មោះ គាន់ម៉េង, មាន, កែវ វ៉ាន់, សម្បត្តិ, អ៊ុក ហាត ក្នុងគោលបំណង "១) បង្កើតចលនាកងទ័ពបះបោរនៅក្នុងស្រុក ទី២) ប្រមូលភ្នាក់ងារទាំងអស់ឲ្យចូលរួមធ្វើការក្នុងតំបន់បះបោរនិងទាក់ទងប្រជាពលរដ្ឋឲ្យរត់ចូលតំបន់បះបោរដែលនឹងបង្កើតនៅតំបន់និរតីទីក្រុងភ្នំពេញចាប់ពីខេត្តតាកែវ, ពោធិសាត់, បាត់ដំបង និងខេត្តកំពត ។ បន្ទាប់មកនឹងបន្តវាយសម្រុក ដណ្តើមយកខេត្តខ្មែរនៅតាមព្រំដែនខ្មែរ-សៀមទៀត ។ នៅពេលដណ្តើមបានខេត្តខ្មែរនៅតាម

ព្រំដែនហើយនឹងវាយសម្រុកពីព្រំដែនខ្មែរ-សៀម តាមខេត្តបាត់ដំបង និងព្រះវិហារ រួចចាប់ដៃជាមួយកងទ័ពដែលបានបង្កើតនៅតាមព្រំដែនខ្មែរ-សៀម ហើយចាប់ផ្តើមអនុវត្តផែនការយកតំបន់ខេត្តទាំងបី ។ ឆ្នាំ១៩៧៨ នឹងមានបញ្ជូនជំនួយកងទ័ពបន្ថែមទៀតទៅតាមមុខព្រួញបី ទី១) មុខព្រួញខេត្តព្រះវិហារ មុខព្រួញទី២) ពីស្រុកស្វាយស៊ីសុផុន បាត់ដំបង និងមុខព្រួញទី៣នៅតាមព្រំដែនខ្មែរ-សៀម នៅខេត្តពោធិសាត់តាមជួរភ្នំដងរែក ។ មុខព្រួញទី៤ គឺមានពីរផ្នែកតាមជើងគោកនិងជើងទឹក មុខព្រួញនេះគឺតាមខេត្តកោះកុងទ័ពជើងគោកមានគ្នា៣ពាន់នាក់និងទ័ពជើងទឹកមាន៨រយនាក់ ។ នេះជាផែនការរបស់សេ.អ៊ី.អា ដែលមានគម្រោងវាយប្រហារប្រទេសកម្ពុជារហូតដល់ឆ្នាំ១៩៧៩ ក្នុងគម្រោងបំបែកប្រទេសកម្ពុជាជាពីរ ហើយត្រូវការអនុវត្តផែនការនេះឲ្យបានសម្រេចរហូតដល់ដើមឆ្នាំ១៩៨០» ។

ខែធ្នូ នូ ផ្លូន, ស សេង, ចៀម វើងសៀន, គ្រាន់តាំងសារិន, តាន់ លាភផេង និង ឈាង ទូច បានទទួលភារកិច្ចពីអង្គការសេ.អ៊ី.អាឲ្យមកទាក់ទងនិស្សិតខ្មែរនៅប្រទេសបារាំងនិងនៅប្រទេសកម្ពុជា ។ នូ ផ្លូន បានចាកចេញពីប្រទេសបារាំង ហើយមកដល់ភ្នំពេញថ្ងៃទី២៤ នៅវេលាម៉ោងបីរសៀល ។ រថយន្តបាននាំ នូ ផ្លូន ទៅដល់សហករណ៍បឹងត្របែក ។ នៅពេលដល់ទីនោះ ទ្រី ម៉េងហួត ដែលជាអ្នកតំណាងសហករណ៍បានចេញមកទទួល ។ នៅថ្ងៃបន្ទាប់ នូ ផ្លូន បានជួបជាមួយ រស់ សារិន, សំបាត់, អ៊ុក ហាត (មកដល់ស្រុកខ្មែរបីខែ) ដែលឲ្យដឹងថា អ្នកដែលមានផែនការប្រឆាំងនឹងបដិវត្តកម្ពុជា មានឈ្មោះ ចាន់ សៀង, អៀង ឈុន, គឹម ហួត បានចេញទៅតាមសហករណ៍អស់ហើយដើម្បី អនុវត្តផែនការនេះ ។ ចំណែក ចាន់ គីស៊ុយ និង អុះ បែលក៏ចេញទៅសហករណ៍ដើម្បីពន្យល់ប្រជាជននៅក្នុងសហករណ៍នីមួយៗ ឲ្យចូលរួមធ្វើសកម្មភាពប្រឆាំងនឹងនយោបាយកសាងប្រទេសរបស់អង្គការបដិវត្តនៅដំណាច់ឆ្នាំ១៩៧៧ដែរ ។

នូ ផ្លូន បានសារភាពថា គាត់ត្រឡប់កម្ពុជាគឺដោយសារគាត់បានទទួលភារកិច្ចឲ្យមកទាក់ទងនិងរួមសកម្មភាពជាមួយអ្នករួមការងារចាស់ៗដែលធ្លាប់បម្រើនយោបាយសហរដ្ឋអាមេរិកនិងអង្គការសេ.អ៊ី.អា ជាមួយនឹងអ្នកដែលប្រឆាំងនឹងចលនាបដិវត្តដើម្បីត្រៀមចាំការវាយប្រយុទ្ធតាមផែនការចក្រពត្តិអាមេរិកដែលប្រុងនឹងចែកប្រទេសកម្ពុជាជាពីរចំណែក មួយផ្នែកខាងទន្លេមេគង្គឲ្យចូលជាប្រទេសដែលស្ថិតនៅក្រោមរណបសហរដ្ឋអាមេរិក និងប្រមូលកម្លាំងដើម្បីទប់ទល់ការវាយសម្រុកបន្តពីឆ្នាំ១៩៨០នឹងចលនាកុម្មុយនិស្តនៅអាស៊ី-អាគ្នេយ៍ ។ ភ្ជាប់មកជាមួយនឹងចម្លើយសារភាពនេះ នូ ផ្លូន បានរៀបរាប់ឈ្មោះមួយចំនួនដែលខ្លួនបានពាក់ព័ន្ធ និងបានធ្វើសកម្មភាពជាមួយ ។

**លី សុផល**

# ស្តាប់ប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣ៈ៣០-៣ៈ៤៥នាទី តាមរយៈវិទ្យុ១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

**ផាត រចនា និង លី សុផល**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# បទឧទ្ទេសនាមរបស់សមមិត្ត ឌុច
## ប្រធានមន្ទីរ ស-២១ ឬ មេគុកទួលស្លែង
### ថ្ងៃទី១០, ១២ ខែឧសភា ឆ្នាំ១៩៧៦

***ទស្សនៈ សភាពការណ៍បដិវត្តន៍កម្ពុជាបច្ចុប្បន្ន***

*ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៦*

*១) រំពុកអត្ថន័យនៃមហាជោគជ័យថ្ងៃ១៧ មេសា ៧៥*

*អត្ថន័យទីមួយៈ មហាជោគជ័យនៃការតស៊ូប្រជាជាតិ និងតស៊ូវណ្ណៈ ១៧ មេសា ៧៥ មហាជោគជ័យធំធេងណាស់ព្រោះយើងបានបោសសម្អាតរបបសក្តិភូមិ នាយទុន អធនប្រតិកិរិយា និងចក្រពត្តិឲ្យអស់ពីកម្ពុជា ទាំងរបបវណ្ណៈអធននិយម សន្តមកិច្ចយោធា ដូច្នេះរបបវណ្ណៈសក្តិភូមិ នាយទុន អធន ចក្រពត្តិត្រូវរលំរលាយអស់នៅថ្ងៃ១៧ មេសា ៧៥នេះ ។*

*លើផ្នែកចាត់តាំង មានតែកម្មករនិងកសិករ សព្វថ្ងៃសក្តិភូមិ នាយទុន អធន វាទៅជាកសិករអស់ហើយ និងគ្មានលទ្ធភាពអ្វីទាំងអស់ ។*

*យោធាបដិវត្តន៍វណ្ណៈពិសេស ព្រោះគ្មានកម្មសិទ្ធិឯកជន គ្មានអ្វីទាំងអស់ ។ ក្រោយ១៧ មេសា ៧៥ អស់មានវណ្ណៈសក្តិភូមិ នាយទុន អធន ប្រតិកិរិយាទៀតហើយ វណ្ណៈនៅសល់ក្នុងកម្ពុជាមានតែពីរគត់ កម្មករនិងកសិករ ដូច្នេះចក្រពត្តិអាមេរិកកាំងនិងចក្រពត្តិ ផ្សេងៗទៀត ត្រូវបោសសម្អាតអស់ពីកម្ពុជា ។*

*ខាងចាត់តាំងនៅកម្ពុជាយើង មានវណ្ណៈតែពីរគត់គឺកម្មករនិងកសិករ ។*

*អត្ថន័យទីពីរៈ ១៧ មេសា ជាមហាជោគជ័យ មហាលោតផ្លោះ រយៈកាលប្រជាជាតិប្រតិកិរិយាចប់ហើយ គេធ្វើបដិវត្តន៍បដិរូបដីស្រែ គឺចាប់ផ្តើមធ្វើសហករណ៍ទើបគេធ្វើបដិវត្តន៍បដិរូបដីស្រែ ។*

*ឆ្នាំ១៩៧២ រៀបចំសហករណ៍នៅកំពង់ឆ្នាំង ។*

*ឆ្នាំ១៩៧៣ ចាប់ផ្តើមបិទផ្សារទូទាំងប្រទេស និងរៀបចំសហករណ៍កម្រិតខ្ពស់ ។*

*ឆ្នាំ១៩៧៤ រៀបចំកែលម្អសហករណ៍ ។*

*១៧ មេសា យើងបោសសម្អាតអស់សក្តិភូមិ នាយទុន អធន ។*

*១៧ មេសា ៧៥ ជាការបញ្ចប់បដិវត្តន៍ប្រជាជាតិប្រតិកិរិយាផង ហើយឈានចូលបដិវត្តសង្គមនិយម ។*

*២) ធាតុពិតនៃបដិវត្តន៍កម្ពុជាបច្ចុប្បន្ន*

- *បន្តធ្វើបដិវត្តន៍សង្គមនិយមតទៅទៀត*
- *កសាងសង្គមនិយមនៅកម្ពុជា ដែលហៅថាបដិវត្តសង្គមនិយម យើងធ្វើបដិវត្តន៍សក្តិភូមិដែលវានៅសេសសល់ពីមុនមកត្រូវគាស់រំលើងឲ្យអស់ ។*

*ទ្រឹស្តីកសាងសង្គមនិយមរបស់កសិករ គឺមួយហិកតាឲ្យបាន៣តោន ។*

*៣) ជោគជ័យមួយឆ្នាំនេះនៃការការពារប្រទេសនិងកសាងប្រទេស ។*

- *សេ.អ៊ី.អា ដែលមានសេសសល់នៅកម្ពុជា ត្រូវយើងកម្ទេចជាបន្តបន្ទាប់ងើបមិនរួច ។*
- *យើងគ្រប់គ្រងប្រជាជនថ្មី ដោយម្ចាស់ការបដិវត្តន៍ផង ហើយមានលទ្ធភាពពេញទីក្នុងការដឹកនាំនិងកសាងគេឲ្យបានចម្រើនជឿនលឿន ខាងគោលដៅហរផង ។*
- *ផែនការ៣តោនមួយហិកតា និងលើកប្រព័ន្ធភ្លឺស្រែថ្មីឲ្យបានមួយភាគបី បានក្លាយទៅគោលដៅហរប្រយុទ្ធគោលដៅហរសកម្មភាពរបស់ប្រជាជនយើងទូទាំងប្រទេស ។*
- *គោលដៅហរអំពីផលដែលទទួលបានឈរលើទីតាំងសមូហភាពរឹងប៉ឹងមួយកម្រិតហើយ ។*

*១៩៣០ កកើតបក្សហៅហ៊ីកឲ្យឈ្មោះថា បក្សឥណ្ឌូចិន ដើម្បីរំដោះឥណ្ឌូចិនឲ្យរួចពីចក្រពត្តិបារាំង ព្រោះចក្រពត្តិមិនមែនជិះជាន់តែវៀតណាមទេ ជិះជាន់លាវនិងកម្ពុជាទេ គឺជិះជាន់*

ឥណ្ឌូចិន ១៨-៣-៧០ វៀតណាមបានបញ្ចូលកម្មាភិបាលពីរពាន់នាក់មកកម្ពុជា ហើយបន្ទំឲ្យបក្សយើងស៊ីញ៉េទទួលស្គាល់កងទ័ពវៀតណាមចូលមកកម្ពុជាមានបីកងពលធំ ។

ទីមួយ វៀតណាមត្រូវស្អុយឈ្មោះ លើសកលលោក វាជាអ្នកឈ្លានពានគេ ទីពីរមិនឈ្លានពានយើង ព្រោះវៀតណាមខ្វះខាតអង្ករ១០លានតោន ។

វិបត្តិព្រំដែននៅមានតទៅទៀត រវាងវៀតណាមនិងយើង ។

◆ វៀតណាមមានយុទ្ធសាស្ត្រឈ្លានពាន យើងក៏គ្មានលទ្ធភាពឈ្លានពាន សព្វថ្ងៃកំពុងដំណើរការលួចរំកិលព្រំដែន កាលពីថ្ងៃ២០ មេសា ៧៦ ចក្រពត្តិអាមេរិកកាំងដកទ័ពចេញពីប្រទេសថៃ ។

◆ គ្មានលទ្ធភាពឈ្លានពានយើងទេ ព្រោះចក្រពត្តិអាមេរិកវាអស់មូលដ្ឋានសឹក បដិវត្តវៃនៅចាំតែវៃឈ្នះ ។

៤) អត្ថន័យនៃផែនការ(១៩)៧៦

◆ ផែនការ៧៦ គឺ៣តោនមួយហិកតា និងប្រព័ន្ធភ្លឺស្រែមួយភាគបី ។

អត្ថន័យទី១ៈ ជំហានដំបូងដ៏ធំ ក្នុងការកសាងកសិកម្មនិងឧស្សាហកម្មសម័យនៅកម្ពុជា ។

អត្ថន័យទីពីរៈ ជំហានដំបូងក្នុងការរៀបចំកិច្ចការពារប្រទេសទាន់សម័យ ។

អត្ថន័យទីបីៈ បីតោនមួយហិកតា និងផែនការតទៅមុខទៀតគឺជាទង់ប្រយុទ្ធនៃម៉ាក្សឡេនីននាសម័យបច្ចុប្បន្ន ។

## សាមគ្គីភាពឯកភាពផ្ទៃក្នុងបក្ស

ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៦

១) សារសំខាន់នៃសាមគ្គីភាពឯកភាពផ្ទៃក្នុងបក្ស

◆ ប្រវត្តិការកសាងបក្សគឺជាប្រវត្តិនៃការកសាងសាមគ្គីភាពឯកភាព ។ ពីឆ្នាំ១៩៤៥ដល់១៩៤៦ ចាប់មានអ្នកតស៊ូ ពីឆ្នាំ១៩៥១ កកើតបានបក្សកុម្មុយនិស្តកម្ពុជាពីឆ្នាំ១៩៥៤ យើងសាមគ្គីភាពគ្នាបានផ្ដើមតស៊ូមកដល់ថ្ងៃ៣០ ខែកញ្ញា ឆ្នាំ១៩៦០ យើងមានមាគ៌ាប្រជាជាតិឯករាជ្យម្ចាស់ការឆ្នាំ១៩៦៥ បក្សបានបោះត្រាក់ពេញប្រទេស ចាប់ផ្ដើមឆ្នាំ១៩៦៦-៦៧ ពួកស៊ីវហេង សៀមវាចាប់ផ្ដើមវាតល្បាតកម្លាំងបដិវត្តន៍នៅពាមនៅព្រៃទឹង នៅស្នួល តើយើងសាមគ្គីគ្នាលើអ្វី គឺសាមគ្គីគ្នានៅលើចលនាឆ្នាំ១៩៦៧ ចាប់ផ្ដើមចេញកម្មាភិបាលឆ្នាំ១៩៦៨ យើងចាប់ផ្ដើមវាយខ្មាំងជាបន្តបន្ទាប់ ហើយសាមគ្គីភាពគ្នាបានរឹងមាំរវាងផ្ទៃក្នុង ចង់អ្នកណាហ៊ានចូលវាយខ្មាំងដណ្ដើមអាវុធពីខ្មាំង ហ៊ានតស៊ូលំបាកជាមួយឆ្នាំ១៩៦៨ យើងសាមគ្គីគ្នាបានរឹងមាំល្អ១៩៧០ រដ្ឋប្រហារយើងរំដោះបានភូមិ២៥ ហើយជាមូលដ្ឋានបង្អែកបដិវត្តន៍ ពេលនោះមានបញ្ហាពីរចោទឡើងគឺសីហនុនិងវៀតណាម ។

ខែកុម្ភៈ (១៩)៧៣ វៀតណាមចរចា តែបក្សយើងសុខចិត្តវាយខ្មាំងម្នាក់ឯង ហើយកាន់កាប់វាសនាខ្លួនដោយខ្លួនឯង មិនរណបគេ ថ្ងៃទៅមុខយើងឯកភាពគ្នាក្នុងកសាងសង្គមនិយម ។

◆ សាមគ្គីភាព ឯកភាពផ្ទៃក្នុង ជាកត្តាកំណត់ជោគជ័យរបស់ពួក របស់ក្រុម របស់កងនីមួយៗ ។

◆ ចង់កសាងខ្លួនអំពីវណ្ណៈអធន អំពីសមត្ថភាពដឹកនាំ អំពីសមត្ថភាពបច្ចេកទេសចាំបាច់បំផុត គឺត្រូវកសាងខ្លួនខាងគោលជំហរសាមគ្គីភាពឯកភាព ។

២) ត្រូវក្ដាប់សភាពការណ៍អត្តនោម័តិនិងសត្យានុម័តិឲ្យជាប់និងឲ្យច្បាស់ ដើម្បីថែរក្សាកសាងនិងពង្រឹងសាមគ្គីភាពឯកភាពផ្ទៃក្នុង

◆ សភាពការណ៍អត្តនោម័តិរបស់ជួរយើង

ទោះចេះមិនចេះ សព្វថ្ងៃនេះ អ្នកណាក៏ដឹងថាធ្វើបដិវត្តន៍សង្គមនិយម គឺរៀបចំប្រព័ន្ធភ្លឺស្រែ ដើម្បីត្រៀមលក្ខណៈសម្បត្តិឲ្យបានមួយហិកតា៣តោន ។

ទីមួយៈ ក្នុងជួរយើងទាំងមូល បច្ចុប្បន្ននេះឯកភាពគ្នាល្អណាស់ មិនមែនឯកភាពតែលើសម្ដីទេ គឺឯកភាពជាក់ស្ដែងលើគោលជំហរនយោបាយវាយសម្រុក ជំហរសតិអារម្មណ៍អង់អាចក្លាហាន ហ៊ានពលីកម្មនិងជំហរវណ្ណៈ ដែលនាំឲ្យមានការកោតសរសើរទាំងក្នុងប្រទេស ទាំងលើផ្ទៃពិភពអន្តរជាតិ ។

ទីពីរៈ ទន្ទឹមនេះ ជួរបដិវត្តន៍របស់យើងនៅមានការខ្វះខាតពីរយ៉ាង ។ ម្យ៉ាងគឺ មិនជ្រួតជ្រាបគោលជំហរនយោបាយ សតិអារម្មណ៍របស់បក្សឲ្យរឹងប៉ឹង ម្យ៉ាងទៀតសមមិត្តខ្លះនៅមានសតិអារម្មណ៍បុគ្គលនិយមក្រាស់នៅឡើយ ។

◆ *សភាពការណ៍សត្យានុម័តិរបស់ជួរយើង*

*ទីមួយៈ ពួកសេ.អ៊ី.អា កំពុងដើរខបាយកលវាយយើងពីក្នុងនិងពីក្រៅនេះជាសភាពការណ៍មួយទាក់ទងដល់យើងរវាងសាមគ្គីភាពឯកភាពផ្ទៃក្នុង ។*

*ទីពីរៈ វណ្ណៈសក្តិភូមិ នាយទុន ដែលរលំរលាយទៅនេះ កំពុងរិះរកខបាយកលបំផ្លាញយើង ដោយម្យ៉ាងបុករុកបំបែកបំបាក់ផ្ទៃក្នុងបដិវត្តន៍យើងតាមវិធីខែទំនាស់អូសទាញ ទិញទឹកចិត្ត ហើយម្យ៉ាងទៀតរណោបរណើបឆ្មៀតបញ្ចូលកូនចៅក្នុងជួរបដិវត្តន៍ ដើម្បីទៅអនាគតវាងណ្តើមនាទីដឹកនាំ ហើយឈានទៅសម្រេចសំណូមពរបម្រើផលប្រយោជន៍វាវិញ ។*

*ទីបីៈ មិត្តបរទេសខ្លះ គេមានមាគ៌ាក្លែងពីមាគ៌ារបស់យើង ។ គេរកគ្រប់វិធីបង្វែរយើងឃ្លាតចេញពីមាគ៌ារបស់យើង ។ យើងត្រូវប្រុងប្រយ័ត្ន ។*

◆ *វិធានការជាទិសដោះស្រាយ*

*ទីមួយៈ យើងត្រូវខំកសាងអត្តនោម័តិរបស់ជួរយើងតទៅទៀត តាមវិធីរបស់បក្សដើម្បីកសាងនិងពង្រឹងគោលជំហរសាមគ្គីភាពឯកភាពផ្ទៃក្នុងលើមាគ៌ា ។ កសាងតាមវិធីរបស់បក្សគឺកសាងតាមការរៀនសូត្រ សន្និបាត ប្រជុំដកពិសោធន៍ជីវទស្សន៍បដិវត្តន៍ បើកសាងតាមវិធីមិនបានត្រូវមានវិធានការចាត់តាំង ។*

*ទីពីរៈ ត្រូវខំកសាងកងទ័ពយើង រដ្ឋអំណាចយើង និងប្រជាជនយើង ឲ្យមានជំហរបដិវត្តរឹងមាំ សាមគ្គីភាព ឯកភាពគ្នាលើមាគ៌ារបស់បក្ស កុំឲ្យខ្វាំងចូលចុះដាច់ខាត ។*

◆ *សាមគ្គីភាពឯកភាពផ្ទៃក្នុង ត្រូវឈរដាច់ខាតលើមាគ៌ានយោបាយ មាគ៌ាសតិអារម្មណ៍និងមាគ៌ាចាត់តាំងរបស់បក្ស ។*

*ទីមួយៈ សាមគ្គីភាព ឯកភាព កុំឈរលើបុគ្គលសួនតួ លើអត្តនោម័តិ លើបក្សពួកឲ្យសោះ ។*

*ទីពីរៈ ដើម្បីការពារនិងពង្រឹងសាមគ្គីភាព ឯកភាពផ្ទៃក្នុងបានល្អត្រូវអប់រំផ្ទៃក្នុងឲ្យជាប់ ត្រូវបំពាក់ និងបំប៉នជំហរនយោបាយ ជំហរសតិអារម្មណ៍ និងជំហរចាត់តាំងរបស់បក្សឲ្យជាប់ធ្វើឲ្យផ្ទៃក្នុងទាំងមូលយល់ជ្រួតជ្រាប ហើយកាន់តែជ្រួតជ្រាបន័យអនុវត្តជាក់ស្តែងនៃមាគ៌ានយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្ស ។*

*ទីបីៈ ត្រូវប្រជុំជីវភាព ទៀងទាត់ ប្រជុំសន្តិបាត ដកពិសោធន៍ខុសត្រូវទៀងទាត់ ដើម្បីសាមគ្គីភាពឯកភាពគ្នាតាមសមូហភាពនិងតាមចាត់តាំង ។*

*ទីបួនៈ បើសាមគ្គីភាពឯកភាពផ្ទៃក្នុងវាស្រាំ ក៏កាន់តែត្រូវដោះស្រាយដោយឈរលើមាគ៌ាជានិច្ច ។ ត្រូវដោះស្រាយដោយនឹងនខាងនយោបាយ សតិអារម្មណ៍ជាមុន ក្នុងស្មារតីទទួលខុសត្រូវចំពោះបក្ស គឺត្រូវរៀនសូត្រនិងធ្វើជីវទស្សន៍បដិវត្តន៍ ។ ធ្វើដូច្នេះសមាសភាពល្អពិតជាកែប្រែ ហើយជួនកាលកែប្រែបានទាំងអស់គ្នាផង ។*

◆ *ត្រូវយកចិត្តទុកដាក់ទាក់ទងគ្នាទៅវិញទៅមក ដោយសាមគ្គីភាព ឯកភាពផ្ទៃក្នុងរឹងមាំជានិច្ច ។*

*ត្រូវទាក់ទងគ្នាឲ្យបានស្រួលបួលទៅតាមគោលជំហរសាមគ្គីភាពឯកភាពផ្ទៃក្នុងពីព្រោះ÷១) បុគ្គលយើងម្នាក់ៗ អង្គភាពយើងនីមួយៗ សុទ្ធតែជាសាច់ជាឈាមរបស់បក្សយើងទាំងអស់គ្នា ។ យើងត្រូវឃើញថា មានតែមួយមិនមែនទីទៃគ្នាទេ ។ ត្រូវទាក់ទងគ្នាក្នុងស្មារតីទទួលខុសត្រូវខ្ពស់ជានិច្ច ។ ២) អ្នកទាំងនេះសុទ្ធតែត្រូវការគ្នាទៅវិញទៅមក គ្រាន់តែតិចនិងច្រើនផ្ទាល់ និងប្រយោលប៉ុណ្ណោះ ។*

*ក្នុងការប្រាស្រ័យទាក់ទងនេះ បើសិនជាមានការខុសឆ្គងលើសលោះគ្នាខ្លះក៏មិនយកលេសនេះបិទទ្វារដោយឈរលើក្របខ័ណ្ឌនិយមគ្នា ។*

◆ *ត្រូវយកចិត្តទុកដាក់ចំពោះអាកប្បកិរិយាមួយចំនួន*

*ទីមួយៈ កុំអត្តនោម័តិ ចិត្តស្រាល ត្រចៀកស្រាល ត្រូវនឹងនហ្មត់ចត់ ។*

*ទីពីរៈ ត្រូវទប់ទល់ការបចេកបចូច ញុះញង់ ។*

*ទីបីៈ ត្រូវបេះអត់ធ្មត់អធ្យាស្រ័យ កុំឲ្យប៉ះទង្គិចប្រេះឆាបាន ។*

*ទីបួនៈ ត្រូវប្រយ័ត្នពួកឱកាសនិយម ពួកសមាសភាពមិនល្អសមាសភាពអន្តរាយ ត្រូវប្រយ័ត្នសង្គ្រាមចិត្តសាស្ត្រ សន្តិសម្ព័ន្ធចារកម្ម សកម្មភាពខែទំនាស់ស្កះទំនាស់ផ្ទៃក្នុងយើង ដែលវណ្ណៈជិះជាន់ និងពួកសេ.អ៊ី.អា វាកំពុងដំណើរការបំផ្លិចបំផ្លាញបក្សបក្សបដិវត្តន៍យើង ។*

**ឯកសារខ្មែរក្រហម D២១៩០៥**

# កំណត់ហេតុនៃការប្រជុំខាងមន្ទីរអង្គការ៧០៣និងស-២១

◆ **បញ្ហារើសបានខិត្តប័ណ្ណៈ** *រើសយប់៧-៩-៧៦ ម៉ោង១០ៈ៣០នាទី លើផ្លូវជិតវត្តបទុម ខាងកើតវត្តបទុម ។ ខិត្តប័ណ្ណ ១២សន្លឹក ។ បងប្អូនរើសបានពេលប្តូរយាម ។ បានពិនិត្យសភាពការណ៍ភ្លាម តែរកពុំឃើញភ័ស្តុតាងអីទៀត ។ ពេលនោះផ្លូវនោះងងឹតបន្តិច ។ អ្នកយាមម្នាក់ឲ្យការណ៍ថា ម៉ោងហ្នឹង មានមនុស្សម្នាក់ដើរពីវិមានឯករាជ្យមក ។ សួរថា មិនស្គាល់ មិនមែនគ្នាឯង ។*

◆ **សមមិត្ត ប៉ង់ សន្និដ្ឋានៈ** *លទ្ធភាពមនុស្សនេះចូលធ្វើសកម្មភាពតាមច្រកពីផ្លូវនរោត្តម ហើយចេញវិញតាមផ្លូវក្បែរដើមពោធិមុខវត្ត ផាកទៅត្បូង ក្បែររោងរាំមួយ ។ មនុស្សនេះតាមមើលទៅ ពីក្រៅហើយ មានសមត្ថភាពពីក្នុងក៏ពិបាកធ្វើដែរ ។ ខ្លឹមសារខិត្តប័ណ្ណដូចគ្នានឹងខ្លឹមសារដែលវាបោះមុន ក្បែរទូតចិន ។ មនុស្សដដែលវាធ្វើ ។ ឧទាហរណ៍ពាក្យ ស៊ីតូចដោយតូច ស៊ីធំដោយធំ និងពាក្យអង្គការបដិវត្តន៍ថ្មីបរិសុទ្ធ ។ យប់ថ្ងៃទី៧ ម៉ោង៨ ទៅ ៩ដដែល មានមនុស្សចាក់ខ្សែអាត់ មានខ្លឹមសារកងទ័ពត្រូវអនុវត្តផ្តាច់ការរបស់បក្ស ។ ឮត្រង់មុំផ្ទះសមមិត្ត សន លេខាវរៈសេនាធំ៣១ នៅកងពល ៧០៣ ។ ចិនឮដែរ គេឈរស្តាប់ដែរ ។*

◆ **សមមិត្ត ពីនៈ** *អង្គភាពនេះមានបាតុភាពលើកមុនបានប្តូរអង្គភាពថ្មីមកជំនួសមុខសញ្ញា ។ កន្លងមក កងនេះមានបញ្ហាមកដំបូង យកអង្ករអង្គការ ។ កន្លងមក សមមិត្ត សន មានអប់រំនយោបាយឲ្យ បងប្អូន រវាង២-៣ថ្ងៃក្រោយ ។*

◆ **សមមិត្ត ឌុចៈ** *ខ្សែខិត្តប័ណ្ណ យើងចាប់អាសម្បត្តិ ។ សួរអាលាត អាម៉ាត់ថា ខិត្តប័ណ្ណយកពី ភួន កងពល១៧០ ។ តាមសន្និដ្ឋាន វាអាចបោះច្រើន នៅមុខសញ្ញាដទៃដែរ តែបងប្អូនមិនដែលចាប់អារម្មណ៍លើបញ្ហានេះ ។*

◆ **បង៨៩ៈ** *១) ខិត្តប័ណ្ណនេះខ្លឹមសារតែមួយ ក្បាលម៉ាស៊ីនតែមួយ ។ យើងឯកភាពគ្នាលើចំណុចនេះ ។ ២) ជិតមកបោះព្រោះក្តាប់សភាពការណ៍បាន? ៣) ឆ្ងាយមកបោះបានដែរ? ត្រូវពិនិត្យកង១៨០, កង៧០៣ និងអង្គភាពផ្សេងទៀតដែលបោះក្បែរនោះ ។*

◆ **មតិសរុបបង៨៩ៈ** *១) ពិនិត្យខ្លឹមសារខិត្តប័ណ្ណ ដូចអាខែ៦និងខែ៧ ។ ខិត្តប័ណ្ណនេះធ្វើនៅជិតនៅភ្នំពេញ ។ ធ្វើនៅកន្លែងធ្វើការស្របច្បាប់ ជាមន្ទីរកងពល-វរសេនាធំ ឬក្រសួងផ្សេងៗ ។ ២) បញ្ហានេះមិនមកពីក្រៅទេ ។ ៣) គោលគំនិត អាចពីក្រៅ ឬនៅជិតក្រៅពីកងទ័ព ។ ៤) ខ្សែវា ជាប់កងពល១៧០ ច្រើនក្នុងអង្គភាពបច្ចុប្បន្ន ឬ១៧០ ឲ្យទៅខស្សរាហកម្ម ។ ឬពួក២២០ ដែលអាលីដែលបញ្ជូលមក ។ ពួក៧០៣ ដែលមកពីតំបន់២៥ ឬពួកនៅកសិដ្ឋានរដ្ឋខ្សែពីតំបន់២៥ ។ ៥) វាបោះបាន ត្រូវតែក្តាប់សភាពការណ៍ប្រចាំថ្ងៃ ប្រចាំម៉ោងបាន ។ ដូច្នេះ វានៅជិត ឬនៅក្នុងកងការពារយើងជាអ្នកឲ្យពត៌មាន ។ ខ្មាំងចង់ឲ្យយើងឈប់ទុកចិត្តកង៧០៣ និង១៨០ ។ ៦) បញ្ហាខិត្តប័ណ្ណនេះ មិនមានខាតអីដល់យើង គ្រាន់តែជាការអុកឡុក បំផុសប្រមូលកម្លាំងវានិងបំបែកកម្លាំងយើង ។ សកម្មភាពនេះ ជាផែនការរួមរបស់ខ្មាំង ។ ត្រូវប្រយ័ត្នខ្មាំងលួចបាញ់អង្គការ ។ ប្រយ័ត្នរនុកក្នុងដែលនៅជិតយើង ។*

◆ **វិធានការៈ** *១) ទស្សនៈប្រុងប្រយ័ត្នបដិវត្តឲ្យខ្ពស់ ដោយទំនាស់កាន់តែស្រួចណាស់ កំហឹងវណ្ណៈរបស់ខ្មាំងទាំងខាងលិចទាំងខាងកើត ចំពោះបដិវត្តកម្ពុជាកាន់តែខ្លាំងណាស់ ។ ត្រូវតែវាយយើង វាទុកយូរទៀតមិនបានទេ ។ ២) បញ្ហាចាត់តាំងសមមិត្ត ប៉ង់ និងខាំមី ត្រូវឃើញភារកិច្ចធ្ងន់ធ្ងរ, ខំអប់រំនយោបាយ-សតិអារម្មណ៍ឲ្យជាប់ ។ ក្តាប់ប្រវត្តិរូប ក្តាប់សតិអារម្មណ៍ឲ្យជាប់ ។ ប្រយ័ត្នកុំឲ្យមានទំនាស់សតិអារម្មណ៍ ខ្មាំងអូសបាន ទិញបាន ។ អ្នកណាយើងសង្ស័យត្រូវយកចេញ ។ ត្រូវខំរកដែរ ពិនិត្យហេតុភេទកន្លែងនោះ ។ ខាងក្រៅ សមមិត្ត ពីន ពិនិត្យអង្គភាពឡើងវិញ តើយប់ហ្នឹង ម៉ោងហ្នឹង សកម្មភាពយ៉ាងម៉េច? ទិសរក គឺខ្សែអាសុខចាស់ ។ ខ្លឹមសាររៀនសូត្រ ស្នើសួរតើអប់រំយ៉ាងម៉េច? យើងចង់និយាយប្រៀបធៀបបដិវត្តយើងជាមួយបរទេស ។ សន្តិសុខស្នើតាមដានសភាពការណ៍ខ្មាំងថែម ។ ស្នើសមមិត្ត ប៉ង់ ទាក់ទងក្រសួងផ្សេងៗ ។ ពួក១៧០ គួរប្រមូល ។*

**ឯកសារខ្មែរក្រហម L ០០០១៤៤៥**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

***(តពីលេខមុន)***

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៨៨៩ | អៀម តឿ | កងវរយ | ទូរលេខទូរពុម្ព | ២៩-៨-៧៦ | ១៦-៩-៧៦ |
| ៨៩០ | ចេង ហុកជី | ស័ក្តិ២កាំភ្លើងធំ | ភូមិតាឡី | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៩១ | សែម គីមទីង | ស័ក្តិ២ម៉ារីន | ភូមិតាឡី | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៩២ | ព្រុំ សុខា ហៅ ឯក | ស័ក្តិ២យន្តហោះ | ភូមិតាឡី | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៩៣ | ព្រុំ អេងឈុន | បើកប្រាក់ឲ្យទាហាន | ភូមិតាឡី | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៩៤ | យូ តុល | ស័ក្តិ៣កាំភ្លើងធំ | ភូមិតាឡី | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៩៥ | ហ៊ីង ស៊ីមង៉ាន់ | ស័ក្តិ១យន្តហោះ | ភូមិតាឡី | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៩៦ | ជា លាង ហៅ សំសុត | ស័ក្តិ៣ | ភូមិតាឡី | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៩៧ | ឡាំ អៀវ | ស័ក្តិ២ | ភូមិតាឡី | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៩៨ | តាំង វ៉ាន់ណាល់ | ជាងយន្តហោះ | ភូមិតាឡី | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨៩៩ | ហុង សឿន ហៅ ជា សុភាព | អាត់សាជង់ | តំបន់២០ | ១១-៩-៧៦ | ១៦-៩-៧៦ |
| ៩០០ | សុក រស់ | ស័ក្តិ៣ | ពោធិ៍ចិនតុង | ១១-៩-៧៦ | ១៦-៩-៧៦ |
| ៩០១ | សួន ពៅ (ស្រី) | ប្រជាជន | តំបន់១៥ | ១៩-៨-៧៦ | ១៦-៩-៧៦ |
| ៩០២ | កិន អូន ហៅ សាន | ប្រធានមន្ទីរ | ចម្ការកៅស៊ូ | ១០-៧-៧៦ | ១៧-៩-៧៦ ឈឺស្លាប់ |
| ៩០៣ | ខៀវ ឈាង ហៅ អាត | វរសេនាតូច | ឃ្លាំងរដ្ឋ | ១៨-៧-៧៦ | ១៧-៩-៧៦ ឈឺស្លាប់ |
| ៩០៤ | សារ៉ាយ ហ៊ុប | ប្រជាជន | តំបន់២៥ | ២៧-៣-៧៦ | ១៨-៩-៧៦ ឈឺស្លាប់ |
| ៩០៥ | ឌឹម ដន | កម្មករកំពង់ផែ | ព្រែកក្តាម | ២១-១២-៧៥ | ១៩-៩-៧៦ |
| ៩០៦ | ប៊ុន សយ ហៅ ប៊ុន ណា | កម្មករ | រទេះភ្លើង | ១៦-៦-៧៦ | ១៩-៩-៧៦ |
| ៩០៧ | យឹម បារាំង | ប្រជាជន | កំពង់សោម | ៧-៥-៧៦ | ១៩-៩-៧៦ |
| ៩០៨ | ឆឹយ ឈិន | មេក្រុម | ពោធិ៍ចិនតុង | ១៦-៦-៧៦ | ១៩-៩-៧៦ |
| ៩០៩ | វ៉ាំង ហ៊ន ហៅ អ៊ិត | យុទ្ធជន | ពាណិជ្ជកម្ម | ៩-១០-៧៥ | ១៩-៩-៧៦ |
| ៩១០ | ជិន លុន | មេក្រុម | កង៤៨៨ | ២៩-៧-៧៦ | ២០-៩-៧៦ ឈឺស្លាប់ |
| ៩១១ | វ៉ា ឡឿន | យុទ្ធជន | កងពល២៩០ | ២២-៨-៧៦ | ២២-៩-៧៦ ឈឺស្លាប់ |
| ៩១២ | អោ សេថា | យុទ្ធជន | កងពលទី៣ | ១១-៩-៧៦ | ២២-៩-៧៦ ឈឺស្លាប់ |
| ៩១៣ | សុន សាត | កងហា | តំបន់១៥ | ៤-៧-៧៦ | ២២-៩-៧៦ ឈឺស្លាប់ |
| ៩១៤ | នៅ ភាព | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩១៥ | ដេង អឿន | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |

| | | | | | |
|---|---|---|---|---|---|
| ៩១៦ | ស៊ិន មុត | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩១៧ | គង់ អឿន | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩១៨ | ហួ រ៉ាត | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩១៩ | កែវ រិទ្ធ | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩២០ | គឹម វ៉ៃ | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩២១ | ដា ថន | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩២២ | ឡាយ ឆេង ហៅ ធឿន | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩២៣ | ប៉ាង បាក់ឡេង | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩២៤ | លយ ម៉ុយ | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩២៥ | ដុំ អ៊ុ | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩២៦ | អ៊ួច វ៉ន | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩២៧ | ភិន ម៉ោញ | មេពួក | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩២៨ | ដាន ផន | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩២៩ | ម៉ៅ ស្រ៊ិន | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩៣០ | ឡឹង ស្រេង | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩៣១ | ញ៉ែម អ៊ុម | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩៣២ | តឹក សៀងគង | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩៣៣ | សៀម ម៉ុងស៊ុន | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩៣៤ | សាន គុន | យុទ្ធជន | ស-២១យ | ២២-៩-៧៦ | ២៣-៩-៧៦ |
| ៩៣៥ | ញយ ផេង | កម្មករនេសាទ | កំពង់សោម | ២៨-៨-៧៦ | ២៣-៩-៧៦ ឈឺស្លាប់ |
| ៩៣៦ | មាន ចុង | មេក្រុម | កងពល៥០២ | ២៥-៦-៧៦ | ២៣-៩-៧៦ ឈឺស្លាប់ |
| ៩៣៧ | ឃឹង ដាន់ | កម្មករ | រទេះភ្លើង | ១៤-៨-៧៦ | ២៣-៩-៧៦ ឈឺស្លាប់ |
| ៩៣៨ | អ៊ុក ផេង | កម្មករ | អគ្គិសនីចាក់អង្រែ | ៤-៨-៧៦ | ២៣-៩-៧៦ ឈឺស្លាប់ |
| ៩៣៩ | ប៉ែន រ៉ាត ហៅ សារ៉ាយ | មេក្រុម | កងពល៣១០ | ១-៨-៧៦ | ២៥-៩-៧៦ ឈឺស្លាប់ |
| ៩៤០ | ចាន់ ថារីម ហៅ ថារ៉ាត | យុទ្ធជន | កងពល២៩០ | ១២-៦-៧៦ | ២៥-៩-៧៦ ឈឺស្លាប់ |
| ៩៤១ | សែម សុត | មេក្រុម | កងពល១៦៤ | ១៦-៦-៧៦ | ២៥-៩-៧៦ ឈឺស្លាប់ |
| ៩៤២ | ស៊ិន ស្រាន | យុទ្ធជន | ស្រែអំបិល | ២៥-៦-៧៦ | ២៧-៩-៧៦ ឈឺស្លាប់ |
| ៩៤៣ | សាំង មឿង | កម្មករ | រោងចក្រ គ-២ | ១២-៧-៧៦ | ២៨-៩-៧៦ ឈឺស្លាប់ |
| ៩៤៤ | សាយ ណែម | យុទ្ធជន | កងពល១៦៤ | ១៥-៦-៧៦ | ២៩-៩-៧៦ ឈឺស្លាប់ |
| ៩៤៥ | ចាន់ សុក | មេក្រុម | កងពល៥០២ | ២៤-៩-៧៦ | ២៩-៩-៧៦ |
| ៩៤៦ | ដា ប៉ោ | មេក្រុម | កងពល៥០២ | ២៤-៩-៧៦ | ២៩-៩-៧៦ |
| ៩៤៧ | ប៉ែន ប៉ុន | មេពួក | កងពល៥០២ | ២៤-៩-៧៦ | ២៩-៩-៧៦ |

**(នៅមានត)**

# ខ្មែរស្រុះស្រួលគ្នាទើបខ្មែរបានសុខ

ប្រជាជនកម្ពុជាជាច្រើននាក់បានសរសេរអំពីរឿងរ៉ាវជីវិតរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាជាបន្តបន្ទាប់ និងមួយចំនួនទៀតបានផ្តល់បទសម្ភាសន៍ដល់បុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខាងក្រោមនេះគឺជារឿងរ៉ាវរបស់ស្ត្រីមេម៉ាយម្នាក់ដែលរស់នៅខេត្តកំពង់ឆ្នាំង÷

យាយ គឹម ថេង អាយុ៨៦ឆ្នាំ រស់នៅជាមួយចៅស្រីនៅភូមិខ្ទម្ពរ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ជារៀងរាល់ថ្ងៃ យាយនៅផ្ទះមើលថែទាំចៅទួតដែលនៅតូចៗនិងជួយចម្អិនម្ហូបអាហារ ក្នុងខណៈពេលដែលចៅស្រីរបស់យាយទៅលក់ទំនិញនៅក្នុងសាលារៀន ។ ខ្ញុំបានជួបយាយនៅពេលដែលយាយកំពុងតែយោលអង្រឹងចៅទួតនៅក្រោមផ្ទះក្បឿងធំបន្តួរមួយដែលសង់នៅលើដីកេរពីឪពុកម្តាយរបស់យាយ ។

យាយ ថេង កើតនៅឆ្នាំកុរ ដែលជាកូនទី៣នៅក្នុងគ្រួសារធូរធារមួយដែលមានបងប្អូន៨នាក់ ។ ឪពុករបស់យាយឈ្មោះ អ៊ូ មានដើមកំណើតនៅខេត្តកំពង់ឆ្នាំង ចំណែកម្តាយរបស់យាយឈ្មោះ គូ មានដើមកំណើតនៅខេត្តកំពង់ធំ ។ យាយបានរំឭកអំពីប្រវត្តិឪពុកម្តាយរបស់យាយថា កាលពីកំលោះ ឪពុករបស់យាយបានបួសហើយធ្វើដំណើរពីខេត្តមួយទៅខេត្តមួយដើម្បីរៀនសូត្រ ហើយបានឃើញម្តាយរបស់យាយនៅខេត្តកំពង់ធំក៏ចាប់ចិត្តស្រលាញ់ ។ ត្រឡប់មកដល់ស្រុកកំណើតវិញឪពុករបស់យាយក៏លាចាកសិក្ខាបទ ហើយទៅដណ្តឹងម្តាយរបស់យាយរៀបការនិងរស់នៅខេត្តកំពង់ធំ ។ ច្រើនឆ្នាំក្រោយមកកើតមានជំងឺអុតធំរាតត្បាត នៅក្នុងស្រុកកំណើតរបស់ម្តាយយាយនិងបានសម្លាប់អ្នកស្រុកអស់ជាច្រើន ។ ឪពុកម្តាយរបស់យាយដែល


លោកយាយ គឹម ថេង

ស្លាប់កូនអស់ពីរនាក់ក៏នាំគ្នាផ្លាស់ទីលំនៅមករស់នៅខេត្តកំពង់ឆ្នាំង វិញ ។

ផ្ទះរបស់យាយគឺជាផ្ទះរោងដោល ។ ជីវភាពគ្រួសាររបស់យាយ គឺធូរធារល្មមរស់ដោយស្រួលមិនមានខ្វះខាត ។ យាយនិយាយថា «នៅពីក្មេងនោះវាគ្រាន់តែម៉ាគ្រប់មិនដឹពាក់គេ មិនពិបាកទេ សុខគ្រាន់ល្អមើល» ។ ក្រៅពីការធ្វើស្រែចម្ការ ឪពុករបស់យាយប្រកបរបរដូរញដូរពីស្រុកមួយទៅស្រុកមួយ ។ គាត់បររទេះគោ ដែលផ្ទុកទៅដោយគ្រឿងទេស ថ្នាំជក់ ត្រីងៀត ត្រីឆ្អើរ ស្ករត្នោត និងក្រណាត់សម្លៀកបំពាក់ទៅលក់ដូរនៅស្រុកឆ្ងាយៗរយៈពេលពីរបីថ្ងៃទើបត្រឡប់មកផ្ទះវិញជាមួយនឹងស្រូវអង្ករ ដែលដូរបាន ។ ជួនកាលគាត់ទៅជាមួយនឹងបងប្រុសរបស់យាយ ដោយបររទេះពីរឬបី ។ ចំណែកយាយនិងបងស្រីព្រមទាំងម្តាយទូលទំនិញលក់នៅក្នុងភូមិនិងនៅភូមិជិតខាង ។ យាយនិយាយដោយមោទនកភាពថា ឪពុកនិងបងប្អូនរបស់យាយមិនមានអ្នកណាម្នាក់ធ្វើការរាជការទេ ប៉ុន្តែបច្ចុប្បន្ននេះកូនប្រុសពីរនាក់របស់យាយបានធ្វើការរាជការ ។

បងប្អូនប្រុសៗរបស់យាយសុទ្ធតែបានបួសរៀនទាំងអស់ លើកលែងតែយាយនិងបងស្រីដែលមិនបានទៅរៀន ។ យាយនិយាយថា «ចិត្តនោះចង់ទៅរៀនណាស់មិនមែនថាមិនចង់ទេ ប៉ុន្តែម៉ែឪមិនឲ្យទៅរៀន ចាស់ពីដើមថាឲ្យកូនស្រីទៅរៀនខ្លាចចេះអក្សរទៅសរសេរសំបុត្រស្នេហាទាក់ទងជាមួយប្រុស អ៊ីចឹងហើយស្រីៗអត់បានរៀនទេ» ។ នៅពេលដែលយាយមានអាយុប្រហែល ៤០ឆ្នាំ យាយបានទៅរៀនអក្ខរកម្ម ប៉ុន្តែយាយរៀនមិនចេះទេ ព្រោះរវល់តែបារម្ភនឹងកូនយំ គោគ្មានអ្នកថែ ស្ករត្នោតដែលកំពុងតែរំងាស់គ្មានអ្នកដុតភ្លើង ។ យាយនិយាយថា «កាលពីក្មេងមិនឲ្យរៀនដល់ចាស់ហើយឲ្យរៀន រៀនម៉េចចេះ ម៉េចចាំ ។ សព្វថ្ងៃនេះខ្ញុំទិញសៀវភៅបឹកធ្វើបុណ្យផ្សងឲ្យជាតិក្រោយចេះអក្សរនឹងគេ» ។

កាលយាយនៅពីក្មេង សម្លៀកបំពាក់ប្រចាំថ្ងៃរបស់យាយគឺអាវបំពង់វែងត្រឹមជង្គង់រឹបដៃនិងសំពត់ចងក្បិន ។ យាយនិយាយថាស្ត្រីខ្មែរពីដើមមិនស្លៀកខោទេ ស្លៀកតែសំពត់ចងក្បិន ហើយនៅពេលដែលត្រូវទៅចូលរួមពិធីបុណ្យទានជាប្រពៃណីឬពិធីរៀបមង្គលការ ទើបស្ត្រីបានស្លៀកសំពត់បត់ប្រជាជនខ្មែរនិយមហៅថាសំពត់(សំឡុយ) ហូលឬផាមួង ។ យាយមិនចេះត្បាញទេ ក្រមានិងហូលផាមួងល្អៗដែលយាយប្រើគឺជារបស់ម្តាយយាយដែលយកមកពីខេត្តកំពង់ធំ ។

នៅស្រុករបស់យាយមានចោរហរយខ្លះដែរដែលម្តងម្កាលបានចូលមកក្នុងភូមិនៅវេលាយប់ ហើយឆក់ប្លន់ប្រជាជនណាដែលមានជីវភាពធូរធារគ្រាន់បើ ។ ចោរទាំងនោះមានកាំភ្លើងស្នូកឈើនិងកាំបិតជាអាវុធ ។ បន្ទាប់ពីទទួលទានអាហារពេលល្ងាចរួច ក្រុមគ្រួសាររបស់យាយទៅសុំផ្ទះអ្នកជទែសម្រាកមិនហ៊ានសម្រាកនៅក្នុងផ្ទះរបស់ខ្លួនឯងទេ ព្រោះខ្លាចចោរប្លន់ ។ មានតែឪពុករបស់យាយម្នាក់ប៉ុណ្ណោះដែលនៅចាំផ្ទះដោយត្រៀមអាវុធសម្រាប់ប្រយុទ្ធតទាំងនឹងចោរ និងត្រៀមផ្លូវសម្រាប់រត់ដោះខ្លួនជាស្រេច ។

ឪពុករបស់យាយស្លាប់នៅអាយុ៤០ឆ្នាំ ។ បន្ទាប់ពីឪពុករបស់យាយស្លាប់ទៅម្តាយរបស់យាយមិនរៀបការទៀតទេ ។ គាត់ចិញ្ចឹមកូនៗរហូតដល់ធំនិងរៀបចំទុកដាក់ឲ្យមានប្តីប្រពន្ធគ្រប់ៗគ្នាហើយគាត់ក៏ទៅសុំសីលនៅវត្ត ។ បងប្អូនទាំងអស់របស់យាយ បន្ទាប់ពីរៀបការរួចក៏បែកលំនៅផ្សេងៗគ្នា ប៉ុន្តែនៅក្នុងភូមិស្រុកតែមួយ ។

នៅពេលដែលយាយមានអាយុ២៨ឆ្នាំ ម្តាយរបស់យាយបានរៀបការយាយជាមួយបុរសម្នាក់ដែលរស់នៅឃុំពង្រ ។ ប្តីរបស់យាយឈ្មោះ កែ យ៉ូន ជាកូនកំព្រាឪពុកម្តាយ ។ យាយបានឲ្យដឹងថា មានបុរសជាច្រើននៅក្នុងភូមិបានចូលដណ្តឹងយាយ ប៉ុន្តែម្តាយរបស់យាយមិនពេញចិត្តទើបគាត់មិនព្រមឲ្យលុះដល់ កែ យ៉ូន ចូលស្តីដណ្តឹង គាត់ក៏លើកយាយឲ្យម្ល៉ោះហើយនាំឲ្យមានការច្រណែនពីសំណាក់បុរសនៅក្នុងភូមិដែលចង់បានយាយ ។ នៅថ្ងៃរៀបការរបស់យាយ មានមនុស្សលួចដុតរោងការ ប៉ុន្តែប្រជាជនក្នុងភូមិបានជួយពន្លត់ទាន់ ហើយពិធីរៀបការក៏ប្រព្រឹត្តទៅរហូតដល់ចប់ចុងចប់ដើមក្នុងរយៈពេលពីរថ្ងៃកន្លះ ។ បន្ទាប់ពីរៀបការរួច ប្តីរបស់យាយមានបំណងនាំយាយទៅរស់នៅឃុំពង្រ ព្រោះបារម្ភក្រែងមានការព្យាបាទណាមួយទៀត ប៉ុន្តែយាយមិនព្រមទៅ ។ យាយនិយាយថា «ទៅរស់នៅស្រុកគេ

ខ្ញុំមិនចេះនៅទេ ខ្ញុំសុខចិត្តនៅស្រុកឯង បើវាយ៉ាងម៉េច ក៏ឲ្យដឹងគ្នាទៅ» ប៉ុន្តែអ្នកដែលធ្លាប់ប៉ះពាល់បាទយាយពីមុនមិនបានធ្វើអ្វីទៀតឡើយ ហើយប្តីប្រពន្ធរបស់យាយក៏រស់នៅជាមួយគ្នាដោយសុខដុមរមនា ។ យាយនិយាយថា ប្តីប្រពន្ធយាយ មានការយោគយល់អធ្យាស្រ័យគ្នាល្អណាស់ ។

នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យចាប់ផ្តើមគ្រប់គ្រងប្រទេសកម្ពុជា ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសាររបស់យាយឆ្ងាយពីស្រុកកំណើតទៅរស់នៅតំបន់ដាច់ស្រយាលមួយដែលមានឈ្មោះថាត្រពាំងម្ជូ រួចជម្លៀសជាបន្តបន្ទាប់ច្រើនដំណាក់កាលទៀត ។ នៅទីនោះ សមាជិកគ្រួសារត្រូវបានបំបែកចេញពីគ្នា ប្រមូលផ្តុំតាមភេទនិងវ័យនៅតាមកងចល័តនិងសហករណ៍ ហើយត្រូវធ្វើការរួមនិងហូបរួម ។ របស់របរទាំងប៉ុន្មានត្រូវប្រមូលដាក់ជាទ្រព្យសម្បត្តិរួមទាំងអស់ សូម្បីតែដំណាំដែលប្រជាជនដាំនៅតាមផ្ទះក៏ដោយ ។ កម្មសិទ្ធិសមរម្យរបស់ប្រជាជនម្នាក់ៗគឺស្បៀងតូចមួយ ដែលនៅក្នុងនោះមានចានមួយស្លាបព្រាមួយក្រមាមួយនិងខោអាវមួយ ឬពីរបន្លាស់ ។ ប្រជាជនធ្វើការយ៉ាងនឿយហត់រយៈពេលជាងដប់ម៉ោងក្នុងមួយថ្ងៃដើម្បីប្តូរនឹងអាហារពីរពេលដែលអង្គការផ្តល់ឲ្យ ។

ប្តីរបស់យាយត្រូវអង្គការចាត់តាំងឲ្យធ្វើការផ្សារសព្វមុខតាមតែត្រូវការ ដូចជា ឃ្វាលគោ សង់រោង ភ្ជួររាស់ ដកស្ទូង ច្រូតស្រូវនិងដឹកជញ្ជូន ។ ចំណែកយាយអង្គការចាត់តាំងឲ្យនៅក្នុងកងយាយចាស់ៗ ធ្វើជី ធ្វើចង្ក្រានអុស និងត្បាញកន្ទេលស្លឹកត្នោតឬកន្ទេលរំចេក ។ ប្រធានសហករណ៍ដាក់កម្រិតឲ្យយាយម្នាក់ៗត្បាញកន្ទេលមួយដែលមានបណ្តោយ១២ហត្ថទទឹង៤ហត្ថ ឲ្យហើយក្នុងរយៈពេល២ថ្ងៃ ។ ដោយសារយាយមិនអាចអង្គុយបានយូរ យាយបានសុំប្រធានសហករណ៍ពន្យារពេលត្បាញកន្ទេលមួយក្នុងរយៈពេល៤ថ្ងៃ ។ ទោះជាក្រុមយាយៗធ្វើការនៅក្នុងភូមិក៏ដោយ ក៏មិនបានឈប់សម្រាកមុនក្រុមស្ទូងដែរ ។ យាយនិយាយថា «មិនមែនថា យើងធ្វើការនៅក្បែរហ្នឹងគេឲ្យយើងឈប់ហូបបាយមុនទេ ត្រូវចាំទាល់តែអ្នកស្ទូងដកត្រឡប់មកដល់សហករណ៍វិញទើបបានឈប់សម្រាកហូបបាយទាំងអស់គ្នា» ។

ខែខ្លះក្រុមយាយៗត្រូវធ្វើជី ។ ព្រលឹមឡើងយាយៗកាន់កាំបិតទៅកាប់ដើមទន្ទ្រានខែត្រ ហើយដឹកតាមរទេះគោឬទូលយកមកសហករណ៍ ។ បន្ទាប់ពីអាហារថ្ងៃត្រង់រួច នាំគ្នាកាប់ចិញ្ច្រាំដើមទន្ទ្រានខែត្រលាយច្របល់ជាមួយអាចម៍គោ រួចគរទុកឲ្យក្រុមដឹកមកដឹកយកទៅដាក់ក្នុងស្រែ ។ នៅខែប្រាំងប្រធានសហករណ៍ចាត់តាំងឲ្យយាយធ្វើចំការអុស ។ យាយឲ្យដឹងថាដើម្បីធ្វើចង្ក្រានអុស មុនដំបូងត្រូវទូលស្លឹកឈើយកទៅដាក់ឲ្យពេញចង្ក្រានដែលបានភ្ជួររួច ។ នៅពេលដែលស្លឹកឈើស្ងួតទើបចាប់ផ្តើមដុត រួចបុកដីដាំស្រូវឬពោត ។ ពេលដែលពោតឬស្រូវចេញផ្លែត្រូវទៅចាំយាមក្រែងជ្រូកព្រៃស៊ីបំផ្លាញ ។ ស្ត្រីយាមពេលថ្ងៃ បុរសយាមពេលយប់ ។

ផ្ទុយអំពីការងារដ៏ធ្ងន់ធ្ងរ របបអាហារដែលប្រជាជនទទួលបានគឺបាយលាយដំឡូងឬក្លូច ឬបបរវាវមួយចានចំនួនពីរដងក្នុងមួយថ្ងៃ ។ ជួនកាលចុងភៅបន្ស៊ាបក្លូចមិនអស់ជាតិពុលបណ្តាលឲ្យប្រជាជនពុលរាកក្អួតពេញភូមិ ។ ជារឿយៗ ខ្មែរក្រហមបានឆែកឆេរតាមផ្ទះរបស់ប្រជាជនក្រែងមានលាក់អង្ករ អំបិលត្រីងៀត ឬរបស់របរហូបចុកផ្សេងៗទៀតដែលអាចលាក់កំបាំងហូបក្បត់នឹងសមូហភាព ។ យាយបន្ថែមថា «នៅក្នុងរបប ប៉ុលពត ម្នាក់ៗមិនដែលបានហូបឆ្អែតទេកុំថាឡើយបានឆ្ងាញ់ ។ គេឲ្យយើងស៊ីនោះកុំឲ្យតែងាប់ទេ» ។ ប្រជាជនជាច្រើនជាពិសេសយុវជនពេញកម្លាំងបានស្លាប់ដោយអត់ឃ្លាន ។ អ្នកខ្លះឈឺរហូតដល់ស្លាប់តែម្នាក់ឯងគ្មានអ្នកមើល ។ យាយនិយាយទៀតថាមានតែម្តងគត់ដែលខ្មែរក្រហមធ្វើបុណ្យធំប្រមូលប្រជាជនច្រើនសហករណ៍មកជួបជុំគ្នា ហើយសម្លាប់ជ្រូកធ្វើគុយទាវឲ្យប្រជាជនហូប ។

កូនរបស់យាយដែលទៅរស់នៅកងចល័តឬកងកុមារបើចង់មកលេងឪពុកម្តាយបួនឬប្រាំថ្ងៃត្រូវតែមានរបស់សូកប្រធានកងដូចជានាឡិកាឬខោអាវល្អៗជាដើម ទើបបានច្បាប់អនុញ្ញាតមកលេងផ្ទះ ។ នៅចុងឆ្នាំ១៩៧៥ កូនប្រុសច្បងរបស់យាយឈ្មោះ គាន់ ត្រូវអង្គការតម្រូវឲ្យរៀបការ ។ ពិធីរៀបការប្រព្រឹត្តទៅនៅកងចល័តដោយមិនមានការចូលរួមពីឪពុកម្តាយឡើយ ។ យាយនិយាយថា «ខ្ញុំមិនបានដឹងថាកូនខ្ញុំរៀបការផង

*ទាល់តែគេនាំប្រពន្ធមកលេងហើយទើបខ្ញុំដឹង»* ។ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ គាត់ បានលែងលះប្រពន្ធដែលរៀបការក្នុងរបបខ្មែរក្រហម ហើយបានរៀបការប្រពន្ធម្នាក់ទៀត ។

នៅឆ្នាំ១៩៧៦ ពេលដែលទឹកចាប់ផ្តើមស្រក ប្តីរបស់យាយបានកើតជំងឺរាករូស ហើយមិនយូរប៉ុន្មានក៏ស្លាប់ទៅ ។ យាយបាននិយាយថា ប្រធានកងបានបញ្ជូនប្តីរបស់គាត់ទៅមន្ទីរពេទ្យ ប៉ុន្តែនៅទីនោះប្តីរបស់យាយបានត្រឹមតែឆ្លងជំងឺផ្សេងៗពីអ្នកជំងឺដទៃបន្ថែមទៀតប៉ុណ្ណោះ ព្រោះនៅមន្ទីរពេទ្យពោរពេញទៅដោយភាពស្មោកគ្រោកនិងគ្មានថ្នាំអ្វីសម្រាប់ព្យាបាលអ្នកជំងឺក្រៅពីថ្នាំអាចម៍ទន្សាយឡើយ ។ យាយបានសុំប្រធានកងមកមើលប្តីដែលឈឺ ប្រធានកងបានឆ្លើយថា *«យាយឯងមិនបាច់ទៅមើលទេ មានគេមើលហើយ យាយឯងមិនមែនពេទ្យទេ»* ។ យាយបានសុំយកប្តីចេញពីមន្ទីរពេទ្យមកថែទាំនៅផ្ទះ ប៉ុន្តែដោយគ្មានថ្នាំសង្កូវនិងកង្វះខាតចំណីអាហារ ប្តីរបស់យាយក៏ស្លាប់ទៅ ។ បន្ទាប់ពីប្តីរបស់យាយស្លាប់ មិនយូរប៉ុន្មានកូនស្រីទីបីរបស់យាយក៏ស្លាប់ដោយជំងឺរាកដែរ បន្ទាប់មកទៀតគឺចៅប្រុសរបស់យាយ ។ កូនទីពីររបស់យាយក៏មាន ជំងឺរាកធ្ងន់ធ្ងរ ប៉ុន្តែសំណាងល្អបានអ្នករួមការងារឲ្យថ្នាំពេទ្យមួយគ្រាប់លេបហើយបានជាសះស្បើយមានជីវិតរស់រានរហូតមក ។

មានម្តងនោះ កូនប្រុសពៅរបស់យាយកើតបូសធំមួយនៅសៀតផ្កា ហើយត្រូវទៅសម្រាកព្យាបាលនៅឯមន្ទីរពេទ្យ ។ យាយបានសុំមេកងទៅមើលកូនឈឺនិងសុំសម្រាកជាមួយកូនមួយយប់ ។ មេកងអនុញ្ញាតឲ្យយាយទៅប៉ុន្តែមិនអនុញ្ញាតឲ្យដេកនៅពេទ្យទេ ត្រូវត្រឡប់មកវិញនៅពេលល្ងាច ។ ដោយសារផ្លូវទៅមន្ទីរពេទ្យជាផ្លូវស្ងាត់កាត់ព្រៃនិងជួនកាលមានសត្វសាហាវផង យាយក៏សុំក្មេងម្នាក់ទៅជាមួយគ្រាន់បានជាគ្នា ប៉ុន្តែមេកងមិនអនុញ្ញាត ដោយសំអាងហេតុផលខាតការងារ ។ យាយប្រថុយដើរកាត់ព្រៃតែម្នាក់ឯងក្នុងចម្ងាយដីជាច្រើនគីឡូម៉ែត្រទាំងក្នុងចិត្តភ័យបារម្ភក្រែងសត្វសាហាវខាំដើម្បីទៅមើលកូនប្រុសដែលដេកឈឺនៅមន្ទីរពេទ្យ ។

យាយ ថេង បាននិយាយអំពីស្ត្រីមេម៉ាយម្នាក់នៅក្នុងសហករណ៍ជាមួយគាត់ ដែលបានហៅកម្មាភិបាលខ្មែរក្រហមថា *«ព្រះអង្គខ្មៅ»* ដោយសារតែឃើញកម្មាភិបាលទាំងនោះមានសម្បុរខ្មៅ ។ យប់ឡើងកម្មាភិបាលខ្មែរក្រហមមកប្រាប់ស្ត្រីនោះឲ្យរៀបចំខ្លួនព្រឹកស្អែកទៅដាំដំណាំនៅទួលខ្ពក ។ ស្ត្រីនោះមានកូនតូចៗពីរនាក់នៅជាមួយនិងកូនធំម្នាក់នៅកងកុមារ ។ ខ្មែរក្រហមបានសម្លាប់ទាំងម្តាយនិងកូនតូចៗទាំងពីរមុន ។ ពីរបីថ្ងៃ ក្រោយមកខ្មែរក្រហមបានបញ្ឆោតកូនច្បងដែលនៅក្នុងកងកុមារថាឲ្យមកលេងនឹងម្តាយ រួចក៏សម្លាប់ផ្តាច់ពូជតែម្តង ។ យាយបន្ថែមថា *«កាលហ្នឹងទោះស្រួលពិបាកអីក៏ត្រូវតែស្ងៀមដែរ អត់មាននិយាយបានទេ តែហ៊ាននិយាយងាប់ ។ គេម៉ាត់សម្បើមណាស់ថាម៉េចត្រូវតែអីចឹងហើយ បើមិនតាមគេមានទោសណា៎ ។ ធ្វើនេះធ្វើឲ្យយើងងាប់តែម្តងហើយ មិនមែនឲ្យរស់ទេ ។ អ្នកដែលរស់រានមានជីវិតមកនេះសុទ្ធតែធ្វើបុណ្យល្អហើយ ។ កាលនោះខ្ញុំខំប្រដៅកូនថា កូនអើយកុំធ្វើចិត្តអាក្រក់ ធ្វើតែចិត្តល្អទៅ កុំថាម៉េចឲ្យគេកុំរឹងទទឹងនឹងគេ គេឲ្យស៊ីប៉ុន្មានស៊ីប៉ុណ្ណឹងទៅក្រែងលោសល់ជីវិតរស់ត្រឡប់មកស្រុកយើងវិញ ។ មួយថ្ងៃៗខ្ញុំបួងសួងសូមឲ្យប្រជាជនខ្មែរចាកផុតពីទុក្ខវេទនាទាំងអស់នោះ ។ មួយជីវិតនេះខ្ញុំមិនដែលជួបរបបណាដែលពិបាកវេទនា ដូចជារបបប៉ុលពតនេះទេ ទើបតែជួបម្តងហ្នឹងរាងចាលហើយ ខ្ញុំស្គាល់ហើយរសជាតិវេទនា ខ្ញុំមិនចង់ជួប មិនចង់ចាំ មិនចង់ឲ្យធ្លាក់លើកូនចៅខ្ញុំទៀតទេ»* ។

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ យាយ ថេង នៅសល់កូន៤នាក់ ។ យាយនិងកូនៗបានធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញកសាងជីវភាពជាថ្មី ដោយចាប់ផ្តើមពីបាតដៃទទេ ។ បច្ចុប្បន្ន យាយ ថេង មិនចង់បានអ្វីឲ្យលើសពីជីវភាពដ៏ក្សេមក្សាន្តរបស់គាត់រាល់ថ្ងៃនេះទេ ។ យាយចង់ឲ្យតែប្រទេសកម្ពុជានិងប្រជាជនកម្ពុជាបានសុខជារៀងរហូត កុំឲ្យជួបនឹងទុក្ខលំបាកវេទនាដូចនៅក្នុងរបបខ្មែរក្រហមទៀត ។ យាយមិនចង់ឲ្យរបបខ្មែរក្រហមកើតមានជាថ្មីទៀតឡើយ ។ យាយនិយាយថា *«ដើម្បីកុំឲ្យរបបខ្មែរក្រហមកើតម្តងទៀត ទាល់តែខ្មែរយើងស្រុះស្រួលនឹងគ្នា ល្អនឹងគ្នាទៅកុំប្រកែកប្រកាន់គ្នា កុំប្រណាំងប្រជែងយកមុខមាត់ កុំចង់ឈ្នះចាញ់ កុំគុំកួននឹងគ្នា កុំក្បត់គ្នា បើមិនអីចឹងទេកូនចៅជំនាន់ក្រោយវេទនាទៀតហើយ ។ បើខ្មែរយើងស្រុះស្រួលគ្នាទៅយើងបានសុខរហូតហើយ»* ។ **សាន់ កល្យាណ**



«នេះគឺបន្ទប់សួរចម្លើយខ្ញុំ នៅមន្ទីរស-២១»
វិចិត្រករ ៖ ប៊ូ ម៉េង (អតីតជនរងគ្រោះនៅមន្ទីរស-២១)



# ឆ្លងកាត់បួនរបបដឹកនាំៈ ខ្ញុំចង់ឱ្យកម្ពុជាមានការអភិវឌ្ឍន៍


សៅ យ៉ុន

សៅ យ៉ុន ជាយុវជនក្លាហានម្នាក់បានសំពះលាឪពុកម្តាយបងប្អូន មិត្តភក្តិចាកចេញពីភូមិកំណើតមកស្វែងរកការងារធ្វើនៅរាជធានីភ្នំពេញ ។ ភាពក្លាហាននិងការតស៊ូរបស់ សៅ យ៉ុន បានធ្វើឲ្យគាត់សម្រេចបានការងារល្អៗជាច្រើនរហូតមក ។

នៅឆ្នាំ២០០៣នេះ សៅ យ៉ុន មានអាយុ៦១ឆ្នាំ ស្រុកកំណើតនៅភូមិពងទឹក ឃុំពងទឹក ស្រុករំដួល ខេត្តស្វាយរៀង ។ បច្ចុប្បន្ន យ៉ុន និងប្រពន្ធរស់នៅក្នុងស្រុកតាខ្មៅ ខេត្តកណ្តាល ។ ឪពុករបស់ យ៉ុន ឈ្មោះ សៅ មីង ម្តាយឈ្មោះ កែវ អឿន ។ លោកទាំងពីរអនិច្ចកម្មទៅហើយ ។

កាលពីកុមារភាព យ៉ុន រៀននៅវិទ្យាល័យសូរ្យវង្ស ខេត្តស្វាយរៀង ។ យ៉ុន បានបញ្ចប់ការសិក្សានៅត្រឹមថ្នាក់ទី៦ពីសង្គមចាស់ ។ ក្រោយមក ពូយ៉ុន បានមករកការងារធ្វើនៅភ្នំពេញ ។ នៅឆ្នាំ១៩៦៣ យ៉ុន បានក្លាយជាកីឡាករជម្រើសជាតិផ្នែកអត្តពលកម្មនៅក្រសួងសិក្សាធិការជាតិ ។ ឆ្នាំ១៩៦៤ យ៉ុន បានទៅហ្វឹកហាត់ផ្នែកអត្តពលកម្មនៅទីក្រុងសៀងហៃប្រទេសចិន ។ នៅពេលត្រឡប់មកវិញ យ៉ុន បានចូលរួមប្រកួតកីឡាជាលក្ខណៈអន្តរជាតិតំណាងឲ្យប្រទេសកម្ពុជាដែលមានប្រទេសប្រហែលមួយរយចូលរួម ។ នៅឆ្នាំ១៩៦៦ យ៉ុន បានសម្រេចចិត្តលាឈប់ពីកីឡាករ មករៀបការប្រពន្ធរស់នៅភូមិកំពង់សំណាញ់ ឃុំកំពង់សំណាញ់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ បន្ទាប់មកគាត់បានទៅបម្រើការនៅរោងចក្រមួយដែលផលិតកង់រថយន្តមានផ្លាកសញ្ញារូបអង្គរវត្ត នៅក្នុងស្រុកតាខ្មៅ ខេត្តកណ្តាល ។ ប្រធានរោងចក្រនេះឈ្មោះ ប៉ែក ឆាត និង ពិន ថុន (អ្នកបច្ចេកទេសដែលធ្លាប់បានសិក្សានៅប្រទេសឆេកូ រយៈពេល៦ឆ្នាំនិងសិក្សានៅប្រទេសបារាំងរយៈពេល៣ឆ្នាំ), ពិន ថា (ជាវិស្វករខាងគូរប្លង់) ឡាយ ងួន (វិស្វករខាងតម្លើងផលិតផល) និងកម្មករជាច្រើននាក់ទៀត ។ យ៉ុន មានតួនាទីជាអ្នកមើលការខុសត្រូវផ្នែកឃ្លាំង ផ្តល់សម្ភារនិងវត្ថុធាតុដើមសម្រាប់ដំណើរការផលិតសំបកកង់រថយន្ត ដូចជាអំបោះគីមីជាដើម ។ ដោយសារតែផលិតផលនេះមានគុណភាពល្អបានធ្វើឲ្យល្បីទូទាំងប្រទេសរហូតដល់នាំចេញទៅលក់នៅក្រៅប្រទេសទៀតផង ។ យ៉ុន និយាយថាកាលណោះ ឯកឧត្តម គាត ឈន់ ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្ម ។

នៅឆ្នាំ១៩៧០ របបសង្គមរាស្ត្រនិយមបានផ្លាស់ប្តូរទៅជារបបថ្មីមួយទៀតគឺរបបសាធារណរដ្ឋខ្មែរដែលដឹកនាំដោយលោកសេនាប្រមុខ លន់ ណុល ។ យ៉ុន មានប្រសាសន៍ថា ពេលនោះមានការផ្លាស់ប្តូរអ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវមួយចំនួននៅក្នុងរោងចក្រនោះជាបន្តបន្ទាប់ ។ យ៉ុន គ្រាន់តែចាំថាក្រោយមកមានមនុស្សម្នាក់ឈ្មោះលោក ឈាង ស៊ីអ៊ឹម ត្រូវជាកូនប្រសារបស់ ទុំ ងួន ជាអគ្គរដ្ឋទូតខ្មែរប្រចាំប្រទេសថៃ មកធ្វើជាប្រធានរោងចក្រនេះ ។ បំណែកអ្នកបច្ចេកទេសនិងកម្មករពុំមាន

ការផ្លាស់ប្តូរទេ ។

ដោយសារស្ថានភាពនយោបាយមិនល្អនិងមានខ្មែររំដោះបង្កប់ច្រើននៅក្នុងរោងចក្រ ទើបធ្វើឲ្យរោងចក្រមិនមានសូវមានការរីកចម្រើន។ មូលហេតុដែល យ៉ុន ហ៊ាននិយាយដូច្នេះគឺដោយសារខ្លួនគាត់ផ្ទាល់ជាកម្មករផងនិងជាសេ.អ៊ី.អាផង ។ ប៉ុន្តែ យ៉ុន មិនដឹងថានរណាមួយជាខ្មែររំដោះទេ ព្រោះសុទ្ធតែជាខ្មែរដូចគ្នា ។ យ៉ុន បានប្រាប់ឲ្យដឹងទៀតថា អ្នកដែលនាំគាត់ឲ្យចូលសេ.អ៊ី.អាឈ្មោះ ពិន ថា និង ពិន យ៉ាថៃ ហ៊ានៈជាភ្នាក់ងារសេ.អ៊ី.អា ជាអ្នកទទួលស្គាល់ ។

នៅឆ្នាំ១៩៧២ នៅវេលាម៉ោង១១:៤៥នាទីយប់មានការវាយឆ្មក់ពីកងកម្លាំងខ្មែររំដោះជាមួយកងកុម្មុ៉យដូរោងចក្រអស់រយៈពេល៣ម៉ោង ទើបខាងខ្មែររំដោះដកទ័ពថយទៅវិញដោយបន្សល់ទុកមនុស្សស្លាប់ចំនួន១៥នាក់ ។ ចំណែកខាងកងកុម្មុ៉យដូរោងចក្រក៏ស្លាប់និងរបួសច្រើនដែរ ។ ដំណឹងនេះបានលេចឮដល់លោកសេនាប្រមុខ លន់ ណុល ។ លោកសេនាប្រមុខ លន់ ណុល បាននាំឯកអគ្គរដ្ឋទូតអាមេរិកាំងប្រចាំប្រទេសកម្ពុជាមកពិនិត្យមើលរោងចក្រ ហើយបានប្រគល់ប័ណ្ណសរសើរនិងប្រាក់រង្វាន់ចំនួន៣លានរៀលព្រមទាំងតម្លើងឋានន្តរស័ក្តិឲ្យ យ៉ុន ធ្វើជាមេបញ្ជាការប្រចាំរោងចក្រទៀតផង ។

ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ព្រឹត្តិការណ៍គួរឲ្យរន្ធត់មួយទៀតបានកើតឡើង គឺខាងខ្មែររំដោះហៅថាខ្មែរក្រហមបានវាយកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុង រួចបង្ខំឲ្យប្រជាជនចេញពីទីក្រុងទៅកាន់ទីជនបទរយៈពេល៣ថ្ងៃ ។ បន្ទាប់មកខ្មែរក្រហមបានប្រកាសបង្កើតរដ្ឋាភិបាលថ្មីមួយឈ្មោះថាកម្ពុជាប្រជាធិបតេយ្យ ។ ក្រុមគ្រួសាររបស់ យ៉ុន និងក្រុមគ្រួសារកម្មករដែលធ្វើការជាមួយគ្នា ដូចជា សូ ប៉ូច, ជួន សារ៉េត, សឿង ឆាំ, តុប វិរៈ, អ៊ុន ប៊ិន និង គាំ កែក បានភៀសខ្លួនទៅស្រុកកោះធំទាំងអស់គ្នា ដោយហេតុថា តំបន់នេះមានទឹកទន្លេងាយស្រួលក្នុងការធ្វើដំណើរឆ្លងទៅប្រទេសវៀតណាមទៀត ។ ក្រោយពីភៀសខ្លួនរយៈពេលមួយខែ ខ្មែរក្រហមចាប់ផ្តើមប្រមូលនិងអំពាវនាវតាមវិទ្យុឲ្យកម្មករចាស់ៗដែលធ្លាប់ធ្វើការនៅតាមរោងចក្រត្រឡប់មកធ្វើការវិញ ព្រោះថាមានតែពួកគាត់ទេដែលអាចបញ្ជាគ្រឿងម៉ាស៊ីននិងជួយបង្រៀនកម្មករខ្មែរក្រហមឲ្យចេះបច្ចេកទេសនេះបាន ។ សមមិត្ត ខុន ជាកងទ័ពខ្មែរក្រហមមកពីឈើកាច់បាក្អំ ខេត្តព្រៃវែង តំបន់ ២៤


រោងជាងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ត្រូវអង្គការចាត់តាំងឲ្យធ្វើជាប្រធានរោងចក្រ ។ នៅឆ្នាំ១៩៧៧ ឈ្មោះនេះត្រូវអង្គការចាប់ខ្លួន ហើយតំណែងជាប្រធានត្រូវជំនួស ដោយសមមិត្ត វឿន មកពីស្រុកឈូក ខេត្តកំពតវិញ ។ រីឯកម្មករចាស់ៗមិនមានសិទ្ធិគ្រប់គ្រងទេ ទោះបីជាអ្នកនោះមានបច្ចេកទេសយ៉ាងណាក៏ដោយ ក៏មានសិទ្ធិត្រឹមតែផ្តល់យោបល់ប៉ុណ្ណោះ ។ នៅក្នុងឆ្នាំ១៩៧៧ដដែល អ្នកជំនាញការចិនបានមកត្រួតពិនិត្យមើលខាងបច្ចេកទេសក្នុងរោងចក្រ ក្នុងចំណោមនោះក៏មានអ្នកបច្ចេកទេសខ្មែរដែរ ដូចជាលោកវិស្វករ ពិន ជុន ជាដើម ។ ក្រោយមក ពិន ជុន បានត្រូវពួកខ្មែរក្រហមចាប់យកទៅសម្លាប់ចោល ដោយសារគាត់តវ៉ាប្រឆាំងនឹងទ្រឹស្តីរបស់អង្គការខ្លាំងពេក ដោយប្រៀបធៀបទ្រឹស្តីអង្គការទៅនឹងបណ្តាប្រទេសលោកខាងលិចមួយចំនួនថា ប្រទេសឆេកូជាប្រទេសសង្គមនិយមដែរ ចុះហេតុអ្វីការដឹកនាំនៅប្រទេសកម្ពុជាខុសគេយ៉ាងនេះ? ចំណែក យ៉ុន ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើជាប្រធានក្រុមនេសាទគ្រប់គ្រងកម្មករចំនួន៣២នាក់ ។ យ៉ុន តែងតែដឹកនាំសមាជិកទៅរកត្រីនៅតាមដងទន្លេសាបម្តុំគីឡូម៉ែត្រលេខ១០ក្បែរព្រែកព្នៅក្នុងខេត្តកណ្តាល ។ កាលនោះត្រីសម្បូរណ៍ណាស់ ។ ក្រុមរបស់គាត់អាចរកត្រីបានក្នុងមួយថ្ងៃរាប់រយតោនឯណោះ ។ ត្រីដែលរកបានត្រូវបែងចែកទៅតាមរោងចក្រនៅទីក្រុងភ្នំពេញ និងតាមភូមិភាគដោយមធ្យោបាយដឹកជញ្ជូនឡាននិងម៉ូតូ ។ យ៉ុន បានឲ្យដឹងថា ប្រធានឧស្សាហកម្មគឺសមមិត្ត ចេង អន, វ៉ន វ៉េត ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការអ្នកទាំងអស់នេះត្រូវអង្គការចាប់ខ្លួនយកទៅសួរចម្លើយរួចសម្លាប់ចោល ដោយចោទថា ជាសេ.អ៊ី.អាបង្កប់ ។

នៅឆ្នាំ១៩៧៨ យ៉ុន ត្រូវអង្គការដកចេញពីកងនេសាទ ហើយចាត់តាំងឲ្យទៅធ្វើការនៅរោងចក្រក្តារបន្ទះ ដែលស្ថិតនៅក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល ។ យ៉ុន បានអះអាងថា នៅទីនោះ គាត់ក៏ឃើញមានជំនាញការចិនដែរ ហើយគាត់ថែមទាំងធ្លាប់បាននិយាយលេងជាភាសាចិនជាមួយជនជាតិចិនម្នាក់ឈ្មោះ ហុង ទៀតផង ។ នៅរោងចក្រក្តារបន្ទះបានតែប៉ុន្មានខែ យ៉ុន ត្រូវអង្គការចាត់តាំងឲ្យមករោងចក្រនៅកង់ឡានវិញ ។

ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ យ៉ុន ធ្លាប់បានចូលរួមមហាសន្និបាតបក្សនៅបូរីកីឡាជាមួយកម្មកររាប់ពាន់នាក់ និងខ្មែរក្រហមជាច្រើនរូបទៀតដែលមកពីភូមិភាគនានាទូទាំងប្រទេស ក្រោមអធិបតីភាពរបស់ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងអង្គមហាសន្និបាត ខៀវ សំផន មានប្រសាសន៍ថា “យើងរំដោះប្រជាជនឲ្យរួចផុតពីនឹមខ្នោះឃ្នាងសក្តិភូមិ យើងចង់ឲ្យការហូបចុកពីមូលដ្ឋានមួយទៅមូលដ្ឋានមួយមានភាពស្មើៗគ្នា ។ ក្រោមពាក្យស្លោកមួយពោលថា យើងធ្វើបដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ” ។ សំឡេងទះដៃបានលាន់ឮយ៉ាងខ្លាំង បន្ទាប់ពី ខៀវ សំផន ថ្លែងសុន្ទរកថាចប់ ។ ពូយ៉ុនបន្តថា នៅជំនាន់ខ្មែរក្រហមមានចែកជាបីក្រុម÷ទី១) គឺក្រុម ប៉ុល ពត, អៀង សារី ទី២) ក្រុមរបស់សម្តេចព្រះនរោត្តម សីហនុ និងទី៣) ក្រុម អ៊ិត សួង ខាងខ្មែរវៀតណាម ។ ក្រុមទី២និងក្រុមទី៣ត្រូវខ្មែរក្រហមសម្លាប់ចោលអស់នៅសល់តែខ្មែរខាង ប៉ុល ពត និង អៀង សារី ។

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ១៩៧៩ យ៉ុន បានត្រឡប់មកធ្វើការនៅរោងចក្រកង់ឡានស្រុកតាខ្មៅ ខេត្តកណ្តាលវិញ ។ យ៉ុន មានតួនាទីជាអនុប្រធានរោងចក្រ ។ បច្ចុប្បន្ន យ៉ុនចូលនិវត្តន៍ហើយ ។

តាមបទពិសោធន៍ដែលបានឆ្លងកាត់បួនរបបកន្លងមក យ៉ុនយល់ឃើញថា មានតែរបបខ្មែរក្រហមមួយទេដែលសាហាវឃោរឃៅព្រៃផ្សៃ ហើយគឺជារបបមួយដែលសម្លាប់ជាតិឯងសម្លាប់ប្រជាជនឯង មិនគោរពព្រះពុទ្ធសាសនាយកវត្តអារាមធ្វើជាគុកនិងជាកន្លែងចិញ្ចឹមសត្វ ។

យ៉ុន សំណូមពរឲ្យយើងទាំងអស់គ្នានិងរដ្ឋាភិបាលគិតយ៉ាងណាជួយថែរក្សាអដ្ឋិធាតុនៅតាមបណ្តាខេត្តក្រុងទាំងអស់ទុកជាសារមន្ទីរ ព្រោះនេះជាព្រលឹងខ្មែរដ៏ស្លូតត្រង់ដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។

យ៉ុន ចង់ឃើញប្រទេសកម្ពុជាមានការអភិវឌ្ឍន៍ធនធានមនុស្សឲ្យបានច្រើនដូចប្រទេសជឿនលឿនមួយចំនួន និងសូមឲ្យរាជរដ្ឋាភិបាលឬអង្គការនានាចូលមកជួយប្រទេសកម្ពុជាក្នុងនាមជាមិត្តផងដែរ ។

**សុខ ខណ្ណៈ**

# ខ្មែរក្រហមបានរំលោភសិទ្ធិកុមារយ៉ាងព្រៃផ្សៃបំផុត

រឿងនៃការរំលោភលើសិទ្ធិកុមារនេះបានកើតឡើងនៅក្នុងស្រុកបរិបូរនិងមូលដ្ឋានឃុំពេជចង្វារ ខេត្តកំពង់ឆ្នាំង ដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមក្រោមការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។

កែវ យិន អាយុ៤០ឆ្នាំ បច្ចុប្បន្នជាស្មៀនឃុំពេជចង្វារ ស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង ។ ក្នុងរបបខ្មែរក្រហម គាត់ស្ថិតនៅក្នុងកងកុមារនៅជំរំអូរអំពិល ក្រោយមកបានផ្លាស់មកនៅកងចល័តក្នុងឃុំពេជចង្វារវិញ ។ កែវ យិន គឺជាអ្នកដឹងរឿងរ៉ាវច្រើនទាក់ទងទៅនឹងអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនៅទូទាំងឃុំពេជចង្វារនេះ ដូចជា ទីតាំងរណ្តៅសាកសពដែលខ្មែរក្រហមបានសម្លាប់ មន្ទីរសន្តិសុខ-គុក និងសកម្មភាពផ្សេងៗរបស់ខ្មែរក្រហមជាដើម ។ នៅក្នុងមូលដ្ឋានឃុំពេជចង្វារនេះលោកបាននិយាយឲ្យដឹងថា មានទំនប់ទប់ទឹកមួយឈ្មោះទំនប់ទឹកអូរអំពិល ដែលជាស្នាដៃរបស់កងកុមារចំនួន២០០នាក់ កសាងនៅក្នុងរបបខ្មែរក្រហម ។

ទំនប់ទឹកអូរអំពិលមានបណ្តោយពាគីឡូម៉ែត្រ កម្ពស់៥ម៉ែត្រ ទទឹង៧ម៉ែត្រ ។ ទំនប់នេះបានកសាងអស់រយៈពេលមួយឆ្នាំគត់គឺចាប់ពីឆ្នាំ១៩៧៦ដល់ឆ្នាំ១៩៧៧ ទើបរួចរាល់ជាស្ថាពរ ។ តាមប្រសាសន៍របស់ កែវ យិន បានឲ្យដឹងថា អូរអំពិលគឺជាអូរធម្មជាតិមួយដែលមានតាំងពីយូរណាស់មកហើយៗពុំដែលមាននរណាម្នាក់ទៅប៉ះពាល់ឡើយ ។ អូរនេះបាននាំទឹកពីបណ្តាភ្នំខាងលើហូរចុះមកក្រោមឆ្លងកាត់ឃុំពេជចង្វារនិងឃុំត្រពាំងចាន់ រួចបន្តហូរចាក់ទៅទន្លេមេគង្គទៀត ។ ប៉ុន្តែមកដល់សម័យខ្មែរក្រហម អូរនេះត្រូវបានខ្មែរក្រហមបញ្ជូនកុមារមួយកង ដែលមានទាំងកុមារា កុមារី អាយុក្រោម១០ឆ្នាំចំនួន២០០នាក់ ឲ្យមកជីកដីលើកជាទំនប់យ៉ាងខ្ពស់ទប់ទឹកកុំឲ្យហូរ ។ កងកុមារទាំងនោះមានរហស្សនាមថា “កងកុមារគំរូឈានមុខ” ។ ទឹកដែលបានមកពីការទប់នេះត្រូវបានយកមកប្រើប្រាស់នៅក្នុងវិស័យកសិកម្មដូចជាធ្វើស្រែចម្ការជាដើម ។

ដោយសារការកសាងមិនបានធ្វើឡើងតាមលក្ខណៈបច្ចេកទេស ពោលគឺពុំបានធ្វើទ្វារទឹកបើក-បិទសម្រាប់ពេលទឹកជន់ម្តងៗ ទើបបណ្តាលឲ្យទំនប់ទឹកនេះបាក់ស្រុតអស់គ្មាននៅសល់ទ្រង់ទ្រាយបច្ចុប្បន្នទំនប់អូរអំពិលនេះបានក្លាយទៅជាអូរធម្មជាតិដូចពីមុនដដែល ។

កែវ យិន បានប្រាប់យើងថា កុមារាកុមារីដែលមានអាយុក្រោម១០ឆ្នាំ ត្រូវបានជ្រើសយកមកពីគ្រប់សហករណ៍ក្នុងឃុំពេជចង្វារ ហើយអ្នកគ្រប់គ្រងជំរំនេះគឺសុទ្ធតែយុវនារីក្មេងៗដែលខ្មែរក្រហមឲ្យឈ្មោះថាអ្នកគ្រូ ប៉ុន្តែកុមារដែលរស់នៅក្នុងជំរំប្រមូលផ្តុំនោះគ្មានចេះអក្សរមួយតួណាឡើយ ។ ពាក្យថាអ្នកគ្រូគ្រាន់តែជារនាំងបិទបាំងកុំឲ្យឪពុកម្តាយរបស់កុមារដឹងពីកលល្បិចរបស់ខ្លួនប៉ុណ្ណោះ ធាតុពិតកុមារទាំងអស់គិតតែពីនាំគ្នាលើកទំនប់ទប់ទឹក ជីកដី រែកដី សែងដី តាមកម្រិតដែលអ្នកគ្រូដាក់ឲ្យធ្វើតាំងពីព្រលឹមទល់ព្រលប់ គ្មានពេលវេលាសម្រាកទេ តើកុមារទាំងអស់នោះ មានពេលឯណារៀនសូត្រ? ។ សូម្បីតែរបបអាហាររបស់កុមារក៏ទទួលមិនបានគ្រប់គ្រាន់ដែរ សម្រាប់កុមារ២០០នាក់ទទួលបានរបបអង្ករតែ២០កំប៉ុងសម្រាប់មួយខ្ទះគ្នោត ដោយកុមារម្នាក់ៗបានចំណែកតែមួយវែកសម្ល និង៥នាក់សម្លមួយចានប៉ុណ្ណោះ ។ កុមារទាំងអស់ត្រូវដេករួមគ្នានៅក្នុងរោងមួយដែលមានបណ្តោយ ៥០ម៉ែត្រ ទទឹង៤ម៉ែត្រ ដំបូលប្រក់ស្លឹកនិងគ្រែរនាបកម្ពស់កន្លះម៉ែត្រ ដែលកុមារត្រូវដេកជាពីរជួរក្បាលចេញក្រៅជើងទល់គ្នា ហើយនៅចន្លោះកណ្តាលជាផ្លូវសម្រាប់អ្នកគ្រូដើរយាមល្បាតពេលយប់ ខ្លាចក្រែងកុមារលួចរត់ចេញពីជំរំ ។ ប្រសិនបើកុមារណាលួចរត់ចេញពីជំរំទៅផ្ទះ អ្នកគ្រូៗនឹងទៅចាប់យកពីឪពុកម្តាយមកដាក់នៅជំរំវិញ ហើយធ្វើទារុណកម្មវាយដំប្រចំធាក់នៅចំពោះមុខកុមារដទៃទៀតដោយឲ្យកុមារនោះស្រែកថា “សូមពួកមិត្តកុំយកតម្រាប់តាមខ្ញុំ ខ្ញុំសូមប្តេជ្ញាថាឈប់ប្រព្រឹត្តខុសតទៅទៀតហើយ បើសិនជាខ្ញុំនៅតែប្រព្រឹត្តខុសទៀត

សូមឲ្យអង្គការធ្វើទារុណកម្មខ្ញុំចុះ» ។ កុមារមួយចំនួនទៀតអនុវត្តមិនគ្រប់ផែនការនិងគេចវេះពីការងារក៏ត្រូវអ្នកគ្រូធ្វើទារុណកម្មវាយដំប្រំផាត់គ្មានប្រណីដែរ ។ កុមារដែលស្ថិតនៅក្នុងជំរំប្រមូលផ្ដុំមិនត្រូវបានអនុញ្ញាតឲ្យទៅជួបឪពុកម្ដាយជាដាច់ខាតហើយឪពុកម្ដាយរបស់កុមារទាំងអស់ ក៏មិនត្រូវបានអនុញ្ញាតឲ្យមកសួរសុខទុក្ខកូនដែរ ។

ចំណែកផ្នែកអនាម័យសុខភាពកុមារទាំងអស់គ្មានបានទទួលការមើលថែទាំទេ ហើយការស្លៀកពាក់ក៏ដូច្នោះដែរ ។ កុមារទាំងអស់មានសម្លៀកបំពាក់រហែករយ៉ីរយៃ គ្មានក្រមា គ្មានខោអាវផ្លាស់ប្ដូរ គ្មានភួយសម្រាប់ដណ្ដប់កាយ ឬមុងការពារកុំឲ្យមូសខាំនៅពេលយប់ឡើយ ។ កុមារភាគច្រើនមួយខែមិនទាន់បានងូតទឹកម្ដងផង ខ្លួនប្រាណរបស់គេម្នាក់ដណ្ដប់ទៅដោយក្អែលឡើងខ្មៅ បណ្ដាលឲ្យកើតកមរមាស់ក្បាលជាដំបៅរលួយរលេះខ្លះឈឺគ្រុនក្ដៅ ខ្លះទៀតកើតជំងឺហើម ។ ចំពោះកុមារដែលមានជំងឺ អ្នកគ្រូៗមិនអនុញ្ញាតឲ្យសម្រាកពេទ្យព្យាបាលជំងឺឡើយ គឺកុមារត្រូវបង្ខំឲ្យធ្វើការបណ្ដើរ ព្យាបាលបណ្ដើរជាមួយនឹងប្រភេទថ្នាំគ្រាប់ម្យ៉ាងដែលផលិតដោយគ្រូពេទ្យបូរាណរបស់អង្គការហើយដែលប្រជាជនឲ្យឈ្មោះថា ថ្នាំអាចម៍ទន្សាយ ។ ដូច្នេះជំងឺរបស់កុមារមិនអាចធូរស្បើយបានឡើយ បណ្ដាលកុមារាកុមារីស្លាប់ជារៀងរាល់ថ្ងៃ ។ បើកុមារស្លាប់ត្រឹមម្នាក់ឬពីរនាក់ កុមារដែលនៅក្នុងកងជាមួយគ្នាត្រូវសែងសាកសពយកទៅគ្រវាត់ចោល បើស្លាប់ច្រើនអ្នកគ្រូៗត្រូវទៅសុំកម្លាំងមនុស្សចាស់ពីសហករណ៍មកសែងយកទៅចោលនៅព្រៃត្រពាំងល្ពាក់ ដែលស្ថិតនៅឆ្ងាយពីជំរំនិងផ្ទះប្រជាជនប្រហែលមួយគីឡូម៉ែត្រ ។

កែវ យិន បានប្រាប់យើងបន្តថា នៅក្នុងជំរំប្រមូលផ្ដុំកុមារនោះមានបទបញ្ជាតឹងរ៉ឹងណាស់ ។ អ្នកគ្រប់គ្រងយកតែនារីក្មេងៗដែលមានប្រវត្តិរូបជាប្រជាជនមូលដ្ឋាននិងមានចិត្តស្មោះត្រង់ដាច់ខាតជាមួយអង្គការបដិវត្តន៍មកដឹកនាំកុមារប៉ុណ្ណោះ ។ នារីក្មេងៗទាំងនោះមានចិត្តកាចសាហាវជាទីបំផុត ដែលជាហេតុធ្វើឲ្យកុមារតូចៗខ្លាចរំពាត់ និងការធ្វើទារុណកម្មផ្សេងៗយ៉ាងខ្លាំង ។ កុមារទាំងអស់ខិតខំធ្វើការតាមបញ្ជាទាំងត្រជាក់ត្រដួស ទោះបីឈឺហេវហត់និងទទួលរបបហូបចុកមិនគ្រប់គ្រាន់ក៏ដោយក៏គ្មានហ៊ានប្រកែកជជែកតវ៉ាសោះឡើយ ។ ប្រសិនបើមានកុមារស្លាប់ជាបន្តបន្ទាប់អស់១០ឬ២០នាក់ អ្នកគ្រូៗចាប់ផ្ដើមដើរជ្រើសរើសកុមារនៅតាមសហករណ៍ភូមិ-ឃុំនានាមកបង្គ្រប់វិញតាមចំនួនដែលស្លាប់ ហើយនៅក្នុងកង បើកុមារមួយចំនួនមានអាយុលើសពី១០ឆ្នាំត្រូវបានអ្នកគ្រូដកចេញហើយបញ្ជូលទៅក្នុងកងចល័តរបស់ឃុំពេជចង្វា រួចជ្រើសរើសកុមារដែលមានអាយុក្រោម១០ឆ្នាំមកបង្គ្រប់ក្នុងជំរំប្រមូលផ្ដុំឲ្យគ្រប់ចំនួន២០០នាក់វិញ ។ វិធីនេះប្រព្រឹត្តទៅរហូតដល់ចុងឆ្នាំ១៩៧៨ ។ ដើមឆ្នាំ១៩៧៩ កុមារដែលនៅសេសសល់ពីសេចក្ដីស្លាប់ ត្រូវអ្នកគ្រូៗបញ្ជាឲ្យទៅតាមខ្លួនទៅរស់នៅតាមព្រៃភ្នំ បណ្ដាលឲ្យកុមារទាំងនោះស្លាប់បាត់បង់ជីវិតដោយសារជំងឺគ្រុនចាញ់និងអត់អាហារអស់ជាច្រើននាក់ ។

កែវ យិន បន្តថា កុមារតិចណាស់ ដែលនៅរស់រានមានជីវិតហើយត្រូវបានអ្នកស្រុករើសយកមកចិញ្ចឹម ។ មួយរយៈក្រោយមកទើបឃើញឪពុកម្ដាយបងប្អូនកុមារទាំងនោះមកសុំយកទៅវិញ ។ បច្ចុប្បន្ន នៅក្នុងឃុំពេជចង្វាទាំងមូល ពុំមានលេចឮថាមានកុមារាកុមារីជំរំអូរអំពិលណាម្នាក់រស់នៅក្នុងឃុំនេះទេ ។

**ធុម ធិទា**

## ពាក្យស្លោកខ្មែរក្រហម

- ពួកប្រតិកិរិយាសុទ្ធតែជាខ្លាក្រដាស បើតាមរូបភាពខាងក្រៅគួរឱ្យញញើត តែបើតាមការពិត វាគ្មានកម្លាំងខ្លាំងក្លាសោះ បើធ្វើវស្សានៈត្រូវវែងឆ្ងាយ កម្លាំងខ្លាំងក្លាពិតប្រាកដ គឺស្ថិតស្ថិតនៅលើប្រជាជន មិនមែនលើពួកប្រតិកិរិយាទេ។
- ក្នុងប្រវត្តិសាស្ត្រពិភពលោក ឱ្យតែពួកប្រតិកិរិយា សុទ្ធតែពួកប្រតិកិរិយា សុទ្ធតែខិតវិនាស ហើយវាតែងតែធ្វើការនរនៀលបម្រះ ចំពោះកម្លាំងបដិវត្តន៍ ជាចុងក្រោយបំផុតវាពង្វក់ស្មារតីរបស់យើងអស់មួយរយៈ ពេលនឹកឃើញធាតុពិតប្រាកដថាខ្លួនយើងខិតមានជ័យជម្នះហើយ ហើយសត្រូវខិតវិនាស។

(ដកស្រង់ចេញពីសៀវភៅញ៉ុក)

# តើអ្នកណាជាម្ចាស់នៃច្បាប់សង្គ្រាម?

នៅអំឡុងពេលនៃការបើកការវាយលុកតាមផ្លូវអាកាសទៅលើទីក្រុងបាដាដ បទអត្ថាធិប្បាយពោរពេញទៅដោយវោហារស័ព្ទជ័យជម្នះរាយការណ៍ថាបានវាយចំ«គោលដៅយោធាស្របច្បាប់» ដោយបណ្តាលឲ្យមានបាត់បង់បន្តិចបន្តួចទៅលើជីវិតជនស៊ីវិលប៉ុក៏គ្មានដែរ ។ មិនយូរប៉ុន្មាន សង្គ្រាមតាមផ្លូវអាកាសបានកម្ទេចលើសពីនិមិត្តសញ្ញានៃរបបនោះទៅទៀត ។ ចំណែកឯសង្គ្រាមនៅលើដីវិញក្លាយជាសង្គ្រាមពិតៗតែម្តង ។ សេចក្តីសង្ខេបព្រឹត្តិការណ៍ប្អូកិច្ចសម្ភាសន៍មិនបាននិយាយអំពីច្បាប់សង្គ្រាមទេ ។ របបអ៊ីរ៉ាក់បានប្រកាសជាឱឡារិកមិនយល់ព្រមចំពោះការវាយប្រហាររបស់អាមេរិកដែលពោរពេញទៅដោយរូបភាពសាកសពនិងជនស៊ីវិលដែលរងរបួសនៅក្នុងមន្ទីរពេទ្យឡើយ ។ សហរដ្ឋអាមេរិកបានឆ្លើយតបវិញថា ប្រទេសអ៊ីរ៉ាក់បានបោះទីតាំង និងសម្ភារយោធាដោយចេតនានៅក្នុងបណ្តាទីប្រជុំជន ។ ការនិយាយពីគ្រប់ភាគីទាំងអស់ហាក់ដូចជាធ្វើឲ្យមហាជនយល់ខុសថា ពេលមានសង្គ្រាមច្បាប់បែរជានៅស្ងៀមទៅវិញ ។

ប្រជាជនទូទាំងពិភពលោកយកចិត្តទុកដាក់ណាស់ចំពោះអ្វីដែលហៅថា *Jus in bello* ដែលជាច្បាប់គ្រប់គ្រងទៅលើការប្រព្រឹត្តិនៅអំឡុងពេលសង្គ្រាម ។ វាមានលក្ខណៈដូចគ្នាណាស់ប្រសិនបើប្រជាជនទូទាំងពិភពលោកមានការខ្វែងគំនិតគ្នាទៅលើច្បាប់ *jus ad bellum* ដែលជាច្បាប់មិនគ្រប់គ្រងការប្រព្រឹត្តិនៅក្នុងពេលសង្គ្រាម ប៉ុន្តែជាការប្រើកម្លាំងយោធាដើម្បីដោះស្រាយបញ្ហា ។ ប៉ុន្តែទោះបីជាមានការព្រមព្រៀងគ្នាទៅលើសេចក្តីចាំបាច់ឲ្យមានវិធានជាគោលការណ៍សំខាន់គ្រប់គ្រងការប្រព្រឹត្តិនៅពេលមានសង្គ្រាមក៏ដោយ ក៏មានការមិនព្រមព្រៀងគ្នាដ៏ជ្រាលជ្រៅទៅលើបញ្ហាថាតើអ្នកណាមានសមត្ថកិច្ចក្នុងការប្រកាស បកស្រាយ និងអនុវត្តវិធានទាំងនេះ ក៏ដូចជាថាតើអ្នកណា ហើយត្រូវអភិវឌ្ឍអ្វីខ្លះនៅក្នុងអ្វីដែលហៅថាសិល្បៈនៃការធ្វើសង្គ្រាមដែលនឹងរៀបចំនៅពេលបច្ចុប្បន្ន និងនៅពេលអនាគត ។ និយាយឲ្យខ្លីគឺថា អ្នកណា«ជាម្ចាស់នៃសង្គ្រាម?» ។

### ប្រភពដើមនៃច្បាប់សង្គ្រាមសម័យទំនើប

ប្រពៃណីតាមសាសនានិងសីលធម៌របស់ពិភពលោកនិយាយអំពីអ្វីដែលជាការប្រព្រឹត្តិទៅតាមការអនុញ្ញាតនៅពេលសង្គ្រាមនោះ ។ ប៉ុន្តែច្បាប់សង្គ្រាមសម័យទំនើបគឺកើតចេញមកជាលក្ខណៈប្រវត្តិសាស្ត្រជាគោលការណ៍សំខាន់នៃទ្រឹស្តីយុត្តិធម៌សង្គ្រាម ។ ប៉ុន្តែការស្តែងចេញជាក់លាក់នៃច្បាប់នេះចាប់ផ្តើមជាមួយនឹងការបង្កើតឡើងនូវគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិនៅឆ្នាំ១៨៦៣ ។ កម្លាំងជំរុញឲ្យមានការបង្កើតឡើងនូវកាកបាទក្រហមគឺលោក ហេនរី ឌូនិន ដែលបានឃើញផ្ទាល់ភ្នែក ហើយក្រោយមកបានសរសេរនូវដំណើររឿងនៃការវាយប្រយុទ្ធគ្នាដែលពេញនិយមពីសំណាក់អ្នកអានជាច្រើន ។ សមរភូមិក្តៅនោះគឺស្ថិតនៅសូលហ្វ៊ើរីណូ កាលពីឆ្នាំ១៨៥៩ រវាងប្រទេសអូទ្រីសនិងប្រទេសបារាំង ។ ឌូនិន ព្រមទាំងអ្នកភូមិមួយនៅជិតសមរភូមិនោះ បានបំពេញកិច្ចការយ៉ាងសំខាន់គួរឲ្យរន្ធត់ក្នុងការព្យាយាមប្រមូលអ្នករងរបួសរាប់ពាន់នាក់ដែលគេទុកចោលឲ្យស្លាប់ ។

ដោយគ្មានបង់រុំរបួស គ្មានស្នែងសម្រាប់សែងអ្នករបួស គ្មានគ្រូពេទ្យ គ្មានថ្នាំសង្កូវ ហើយជាពិសេសរដ្ឋាភិបាលគ្មានការចាប់អារម្មណ៍ទៅលើអ្នករងរបួសនោះ គ្មានអ្វីអាចជួយដល់អ្នកទាំងនោះបានទេ មានតែទឹកហូប និងការសូត្រធម៌ប៉ុណ្ណោះ ។ ក្រោយសង្គ្រាមចប់ទៅ កាកបាទក្រហមអន្តរជាតិដែលរៀបចំឡើងដើម្បីធ្វើអ្វីដែលគេរាល់គ្នាខកខានមិនបានធ្វើនៅសូលហ្វ៊ើរីណូនោះ ក៏ក្លាយទៅជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដែលធំជាងគេបង្អស់នៅលើពិភពលោក ។ គោលដៅទីមួយរបស់អង្គការនេះមានលក្ខណៈផ្ទុយជាមួយខ្លួនឯង ហើយស្តាប់ទៅគួរឲ្យចង់សើចទៀតផង ពោលគឺ «នាំមនុស្សជាតិទៅសមរភូមិ» ។ ប៉ុន្តែគោលគំនិតនេះអំពាវនាវឲ្យមានការកែទម្រង់ទាំងស្រុងនៅក្នុង

ចំណោមវណ្ណៈកណ្តាលនៅទ្វីបអឺរ៉ុបនិងអាមេរិកនៅចុងសតវត្សរ៍ទី១៩ ដែលនៅទីនោះ ចលនាមនុស្សធម៌របស់ជនជាតិដើមដើម្បីឲ្យមានការថែទាំយកចិត្តទុកដាក់ចំពោះយោធិនបានចាក់ឫស ជាលើកដំបូងនៅក្នុងអំឡុងសង្គ្រាមស៊ីវិល ។

នៅទ្វីបអឺរ៉ុប ស្មារតីកែទម្រង់នេះធ្វើឲ្យរដ្ឋាភិបាលនិងព្រះរាជវាំងនិងព្រះរាជបរិពារជាន់ខ្ពស់ រៀបចំសន្និសីទជាលក្ខណៈផ្លូវទូតជាបន្តបន្ទាប់ដែលរៀបចំឡើងដើម្បីគិតគូរពិចារណាទៅលើការបង្កើតនូវ "ច្បាប់និងទំនៀមទម្លាប់សង្គ្រាម" ដែលមានជាប្រពៃណីយូរលង់ណាស់មកហើយ ។ លទ្ធផលដ៏សំខាន់បំផុតគឺអនុសញ្ញាទីក្រុងឡាអេនៅឆ្នាំ១៩០៧ ដែលក្នុងមាត្រាខ្លីៗចំនួន៥៦នោះចែងអំពីវិស័យយោធាតាមមូលដ្ឋានគតិយុត្តិទៅលើការប្រតិបត្តិនៅក្នុងពេលសង្គ្រាម ក្នុងនោះរួមមានការចុះចាញ់ ការផ្អាកសង្គ្រាម កាតព្វកិច្ចតម្រូវឲ្យមានសម្លៀកបំពាក់ឯកសណ្ឋាន ការប្រព្រឹត្តិមកលើឈ្លើយសង្គ្រាម ការឡោមព័ទ្ធនិងការប្រយុទ្ធ ការការពារទ្រព្យសម្បត្តិវប្បធម៌ ការហាមប្រាមមិនឲ្យមានការលួចប្លន់ និងលក្ខខណ្ឌនៃការចូលកាន់កាប់ទឹកដី ។

វិធានទូទៅរបស់អនុសញ្ញានេះនៅតែមានអានុភាពនៅឡើយមកទល់សព្វថ្ងៃនេះ ដែលយ៉ាងហោចណាស់ក៏មានលក្ខណៈជាគោលការណ៍ដែរ ។ មិនតែប៉ុណ្ណោះ បញ្ហាភាគច្រើនដែលកងកម្លាំងសម្ព័ន្ធមិត្តបានលើកឡើងថាជាការរំលោភលើច្បាប់សង្គ្រាមពីសំណាក់កងទ័ពអ៊ីរ៉ាក់នោះ អាចឃើញនៅក្នុងបញ្ញត្តិមួយចំនួនចែងនៅក្នុងអនុសញ្ញាទីក្រុងឡាអេ ដូចជាការចុះចាញ់ដោយទុច្ចរិត ការវាយប្រយុទ្ធគ្មានឯកសណ្ឋាន ឬការប្រព្រឹត្តិមិនគប្បីចំពោះឈ្លើយសង្គ្រាម ។

ក៏ប៉ុន្តែ សុទិដ្ឋិនិយមត្រូវបានផាត់ចេញយ៉ាងឆាប់រហ័សប៉ុន្មានឆ្នាំក្រោយមក ដោយសារស្គរកាំភ្លើងនាខែសីហា ។ នៅអំឡុងសង្គ្រាមលោកលើកទី១ ខ្សែទ័ពណ៍លឿង សង្គ្រាមតាមផ្លូវអាកាស រថក្រោះ ហើយជាពិសេសកាំភ្លើងយន្ត ត្រូវបានយកមកប្រើ ច្បាប់ចាស់ៗលែងមានគ្រប់គ្រាន់ ចំណែកឯអង្គការមនុស្សធម៌គ្មានលទ្ធភាពដោះស្រាយចំពោះការឈឺចាប់ក្នុងកម្រិតមួយធ្ងន់ធ្ងរមិនដែលមានពីមុនមក ។ បន្ទាប់ពីមហាសង្គ្រាមនេះទៅ មានការចាប់អារម្មណ៍ទៅលើគោលការណ៍ច្បាប់ *jus ad bellum* និង *jus in bello* ។ កាកបាទក្រហមបានបន្ថែមកិច្ចការទៅលើកិច្ចការពីមុនរបស់ខ្លួន ក្នុងការជំរុញសន្ធិសញ្ញាទាក់ទងនឹងយុទ្ធជនមានជំងឺនិងរបួស ព្រមទាំងលើកកម្ពស់គំនិតមនុស្សធម៌នៅពេលសង្គ្រាមតាមរយៈវិធានគតិយុត្តិ ដោយរៀបចំជាកិច្ចប្រជុំរវាងរដ្ឋនិងរដ្ឋ ហើយចុងបញ្ចប់នាំទៅដល់អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩២៩ ។ អនុសញ្ញាទាំងនេះ រួមជាមួយនឹងអនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩០៧ ត្រូវបានបង្កើតជាច្បាប់សង្គ្រាមដែលចូលជាធរមាននៅពេលផ្ទុះសង្គ្រាមលោកលើកទី២ ។ មិនតែប៉ុណ្ណោះ រដ្ឋនានាបានចរចាទៅលើពិធីសារទីក្រុងហ្សឺណែវឆ្នាំ១៩២៥ ដែលហាមឃាត់អាវុធឧស្ម័ន ពោលគឺជាការហាមប្រាមមួយដែលមានករណីលើកលែងមួយចំនួនតូចអស់រយៈពេល៦០ឆ្នាំ ទោះបីជានៅអំឡុងសង្គ្រាមលោកលើកទី២ រហូតដល់ សាដាម ហ៊ូសេន សង្គ្រាមអ៊ីរ៉ង់-អ៊ីរ៉ាក់ ហើយជាថ្មីម្តងទៀតនៅក្នុងយុទ្ធនាការប្រល័យពូជសាសន៍ឆ្នាំ១៩៨៨ ប្រឆាំងនឹងជនជាតិឃើត ។

## សង្គ្រាមលោកលើកទី២និងលទ្ធផលរបស់វា

សង្គ្រាមលោកលើកទី២នាំមកនូវការរំលោភបំពានថ្មីដែលមួយផ្នែកគឺដោយសារបច្ចេកវិទ្យាថ្មីនៃសង្គ្រាមផ្លូវអាកាសមកលើជនស៊ីវិល ។ ឧទាហរណ៍ការទម្លាក់គ្រាប់បែកដូចកម្រាលព្រំមកលើទីក្រុងដ្រេសដិន បានកៀងគរជនស៊ីវិលឲ្យចូលជាមួយកងទ័ពដែលជាមុខសញ្ញានៃការវាយប្រហារ ។ ការបញ្ចប់សង្គ្រាមលោកលើកទី២នាំមកនូវការវិវឌ្ឍន៍ពីរសំខាន់គួរឲ្យកត់សម្គាល់នៅក្នុងច្បាប់សង្គ្រាម ។ ការវិវឌ្ឍន៍ទីមួយគឺការរៀបចំអង្គជំនុំជម្រះឧក្រិដ្ឋជនពីសំណាក់អ្នកដែលទទួលបានជោគជ័យទៅលើអ្នកដែលត្រូវគេចាត់ទុកថាមានការទទួលខុសត្រូវខ្ពស់បំផុតទៅលើសង្គ្រាម ។ យើងចង់គិតអំពីការកាត់សេចក្តីនៅនូរិមប៊ឺកដែលជាតុលាការឧក្រិដ្ឋសង្គ្រាម ប៉ុន្តែតាមការពិត នូរិមប៊ឺកមានបញ្ហាជាគោលសំខាន់អំពីការកាត់សេចក្តីមេដឹកនាំអាល្លឺម៉ង់អំពីការធ្វើសង្គ្រាមឈ្លានពាន អំពីការធ្វើសង្គ្រាមតែម្តង ពោលគឺឧក្រិដ្ឋកម្មតាមគោលការណ៍ច្បាប់ *jus ad bellum* ជាជាងអំពីរបៀបរបបនៃការប្រព្រឹត្តិក្នុងសង្គ្រាម ។ រដ្ឋអាជ្ញាអាមេរិកាំង រ៉ូបឺត ជែកសុន ពេញចិត្តក្នុងការបន្សល់ទុកនូវអ្វីដែលលោក

ចាត់ទុកថាបញ្ហាមិនសូវទំនើបតាមមូលដ្ឋានគតិយុត្តិ ដែលជាអំពើឃោរឃៅសង្គ្រាម សម្រាប់រដ្ឋអាជ្ញាមកពីប្រទេសផ្សេងៗទៀត ។

ប៉ុន្តែជោគជ័យរបស់ ដែកសុន ដែលបង្ហាញឲ្យឃើញនៅនូរិមប៊ឺក ដែលជាការកំណត់ថាចៅក្រមអន្តរជាតិអាចកាត់សេចក្តីនិងចេញដីកាចោទប្រកាន់មេដឹកនាំជាតិមួយអំពីឧក្រិដ្ឋកម្មឈ្លានពាននោះ មិនបានចៀសផុតពីការបង្កើតនូវអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខឡើយ ។ បញ្ហានៃការកំណត់អំពីការឈ្លានពាន និងថែរក្សាសន្តិភាពអន្តរជាតិត្រូវបានច្បិចយកមកពីនីតិវិទូអន្តរជាតិ ហើយបញ្ចូលទៅក្នុងដៃនៃសមាជិកអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាសន្តិសុខ ពោលគឺជ័យលាភីនៃសង្គ្រាមលោកលើកទី២ ។

យ៉ាងហ្នឹងហើយ បានជាក្រៅតែពីមិនបានថែរក្សាសន្តិភាពនិងសន្តិសុខ ក្រុមប្រឹក្សាសន្តិសុខបានត្រឹមតែធ្វើលើសតែបន្តិចប៉ុណ្ណោះទៅលើការនិយាយអំពីការកាន់កាប់ទឹកដីស្ទើរតែពេញមួយប្រវត្តិរបស់ខ្លួនទៅហើយ ។ ឆន្ទៈរបស់សមាជិកមួយនៃសមាជិកអចិន្ត្រៃយ៍ទាំងប្រាំក្នុងការទាត់ចោលក្រុមប្រឹក្សាសន្តិសុខនៅពេលដែលផលប្រយោជន៍ជាតិរបស់ខ្លួនត្រូវបានគំរាមកំហែងដូចដែលសហរដ្ឋអាមេរិកនិងចក្រភពអង់គ្លេសបានធ្វើពាក់ព័ន្ធនឹងប្រទេសអ៊ីរ៉ាក់នោះ គឺជានិយាមរបស់ក្រុមប្រឹក្សាសន្តិសុខ មិនមែនជាការផ្ទុកចេញពីនិយាមនេះទេ ។ គ្រប់សមាជិកអចិន្ត្រៃយ៍ទាំងអស់ម្នាក់ៗសុទ្ធតែមានផលប្រយោជន៍បែបនេះដែលមិនមែនជាបញ្ហាសន្តិសុខជាតិទេ ប៉ុន្តែជាបញ្ហាទាក់ទងទៅនឹងមហិច្ឆតាឬការទាក់ទិនទៅនឹងមនោសញ្ចេតនា ។ បញ្ហាផលប្រយោជន៍ទាំងនេះរួមមានទីបេនិងតៃវ៉ាន់សម្រាប់ប្រទេសចិន ឆេកឈិន និងស៊ែប៊ី កាលពីឆ្នាំ១៩៩៩សម្រាប់ប្រទេសរុស្ស៊ីនិងប្រទេសនៅក្នុងទ្វីបអាហ្វ្រិកដែលនិយាយភាសាបារាំងសម្រាប់ប្រទេសបារាំង ។

ដូចនេះ ច្បាប់ដែលនៅស្ថិតស្ថេរនៅឡើយចេញពីសាលក្រមតុលាការនូរិមប៊ឺក បានប្រែក្លាយមិនមែនទៅជា«ឧក្រិដ្ឋកម្មនៃការឈ្លានពាន»ទេ ប៉ុន្តែទៅជាការបញ្ជាក់សាជាថ្មីអំពីឧក្រិដ្ឋសង្គ្រាមថាជាឧក្រិដ្ឋកម្មដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិដែលមានការបញ្ចូលរបៀបថ្មីៗសំខាន់ៗពីរដែលបង្កើតឡើងទៅតាមតម្រូវការចាំបាច់ដោយជរំមរណៈណាហ្ស៊ី ពោលគឺអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ នូរិមប៊ឺកក៏មានចន្លោះប្រហោងធំដុំដែរ ។ សំខាន់បំផុតគឺវាមិនបានដោះស្រាយនូវការទម្លាក់គ្រាប់បែកភេរវកម្មមកលើជនស៊ីវិលនិងធ្វើឲ្យមានភ្លើងឆេះសន្ធោសន្ធៅនៅទីក្រុងឌ្រេសដិន និងតូក្យូទាំងមូលដែលអ្នកអនុវត្តដោយសប្បាយបំផុតនោះគឺក្រុមសម្ព័ន្ធមិត្ត ។

ការខកខានក្នុងការកាត់សេចក្តីទៅលើក្រុមសម្ព័ន្ធមិត្តអំពីបទទម្លាក់គ្រាប់បែកភ្លើងមកលើទីក្រុង គឺជាទស្សីករណ៍ដ៏មានទម្ងន់បំផុតសម្រាប់បច្ចុប្បន្ននេះដែលបញ្ជាក់អំពីមូលហេតុអ្វីបានជាតុលាការឧក្រិដ្ឋសង្គ្រាមមិនគួរត្រូវបានបង្កើតឡើងដោយប្រទេសឈ្នះសង្គ្រាម ។ មានមនុស្សជាច្រើនចាត់ទុកទស្សីករណ៍នេះថាមានលក្ខណៈគួរឲ្យជឿរហូតទៅដល់កម្រិតថាគ្រាន់តែការចោទប្រកាន់ទៅលើ«យុត្តិធម៌របស់អ្នកឈ្នះ» វាគ្រប់គ្រាន់សម្រាប់បញ្ចប់ការពិភាក្សាទៅហើយ ។ ប៉ុន្តែចំពោះខ្ញុំវាខុសពីភាពជាក់ស្តែងដែលថា «ភាគីដែលមិនលម្អៀង» មិនមានការពាក់ព័ន្ធមានសមត្ថកិច្ចជាស្វ័យប្រវត្តិខាងសីលធម៌ខ្លាំងជាងប្រទេសឈ្នះសង្គ្រាម ។ តួយ៉ាងប្រសិនបើមានលក្ខណៈសីលធម៌ប្រសើរជាងសម្រាប់ប្រទេសឈ្នះសង្គ្រាមលោកលើកទី២ តើអ្នកណាជាអ្នកចំណាយឈាមស្រស់ដើម្បីឲ្យមានយុត្តិធម៌សម្រាប់ប្រទេសដែលនៅតែរក្សាភាពអព្យាក្រឹត ហើយបដិសេធមិនចូលរួម? អ្វីដែលមានបញ្ហាជាងភាពមិនលម្អៀង ប្រកបដោយគុណធម៌ដែលចេញមកពីអព្យាក្រឹតភាពនោះគឺគុណភាពនៃយុត្តិធម៌នៅក្នុងករណីនីមួយៗ ។

## អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩

ការវិវត្តន៍មួយទៀតនៅក្នុងច្បាប់សង្គ្រាមក្រោយសង្គ្រាមលោកលើកទី២គឺអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ទាំងបួន ។ អនុសញ្ញាទីមួយចែងអំពីយោធិនរងរបួសឬមានជំងឺ ។ អនុសញ្ញាទីពីរចែងអំពីពលទាហានជើងទឹកដែលត្រូវលិចនាវា ។ អនុសញ្ញាទីបីចែងអំពីឈ្លើយសង្គ្រាម ហើយអនុសញ្ញាទីបួនចែងអំពីជនស៊ីវិលនិងការចូលកាន់កាប់ទឹកដី ។ អនុសញ្ញាទីក្រុងហ្សឺណែវក៏បានបង្ហាញជាលើកដំបូងនូវគោលការណ៍សន្ធិសញ្ញាច្បាប់សង្គ្រាមការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលព្រមទាំង

“យុត្តាធិការសាកល” ពោលគឺសមត្ថភាព (មិនតែប៉ុណ្ណោះគឺកាតព្វកិច្ច) របស់រដ្ឋមួយ ឬរដ្ឋនីមួយៗក្នុងការកាត់សេចក្តីបុគ្គលនានា (ឬបញ្ជូនបុគ្គលនោះទៅកាន់រដ្ឋណាមួយដែលអាច) មានភ័ស្តុតាងនៃ“ការរំលោភធ្ងន់ធ្ងរ”ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ។

ចំពោះបញ្ហាថាតើអ្នកណាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការអះអាងអំពីយុត្តាធិការរួចហើយកាត់សេចក្តីពីបទឧក្រិដ្ឋសង្គ្រាម គឺមានសារសំខាន់ណាស់ក្នុងការកំណត់ថាតើអ្នកណាជាម្ចាស់នៃច្បាប់សង្គ្រាម ។ យុត្តាធិការសាកលបញ្ជាក់ថាមានមនុស្សជាច្រើនជាម្ចាស់នៃច្បាប់នោះ ប៉ុន្តែមិននិយាយអំពីលទ្ធភាពនៃការបកស្រាយដែលមានលក្ខណៈខុសប្លែកគ្នាយ៉ាងឆ្ងាយនោះទេ ។ ករណីជាក់ស្តែងគឺទឡ្ហីករណ៍ដែលកំពុងតែមានទំនាក់ទំនងទៅនឹងបញ្ហាថាតើជនជាប់ឃុំនៅឯហ្គាន់តាណាម៉ូ ដែលកំពុងតែទទួលរងនូវការប្រព្រឹត្តិមិនសមរម្យ ពិតជាឈ្លើយ សង្គ្រាមសុទ្ធចិត្តឬក៏យ៉ាងណា បើតាមអនុសញ្ញាទីក្រុងហ្សឺណែវទីបីក៏ដូចជាអង្គការ អាមណេស្ទី អ៊ិនធើណាស្យូណាល់ បានលើកឡើងជាទឡ្ហីករណ៍ដែរនោះ ។ ឬថាតើក្នុងចំណោមពួកតាលីបង់ជាឈ្លើយសឹក ចំណែកឯសមាជិកមួយចំនួននៃបណ្តាញអាល់កៃដាមិនមែនជាឈ្លើយសឹកដូចដែលអង្គការឃ្លាំមើលសិទ្ធិមនុស្សលើកឡើងឬក៏ថាតើគ្មានបុគ្គលណាម្នាក់នៅក្នុងបណ្តាញនេះជាឈ្លើយសឹកទេដូចដែលរដ្ឋការលោកប្រធានាធិបតី ប៊ូស បានទទូច ។ ទាក់ទងនឹងបញ្ហានេះគឺថាតើជនជាប់ឃុំអាចត្រូវកំណត់ថាមិនមែនជាឈ្លើយសឹកតាមរយៈមធ្យោបាយនានាក្រៅអំពីសវនាការជាលក្ខណៈបុគ្គលដែរឬទេ? មេធាវីសិទ្ធិមនុស្សជាច្រើនសន្មតថាការកំណត់ថាតើជនជាប់ឃុំជាឈ្លើយសឹកនោះ ត្រូវតែសម្រេចដោយសវនាការជាលក្ខណៈបុគ្គល ។ នេះគឺជាការអានសន្និសញ្ញាដែលសូម្បីតែអ្នកអភិរក្សជាច្រើនក៏យល់ស្របដែរ ។ (ម្យ៉ាងវិញទៀតវាគឺជាការអានដែលសន្មតកាលពីឆ្នាំ១៩៩៧ នៅក្នុងបទវិន័យយោធាសហរដ្ឋអាមេរិកដែលមានតាំងពីយូរមុនថ្ងៃទី១១ ខែកញ្ញាមកម្ល៉េះ) ។ ប៉ុន្តែខណៈដែលវាជាការបកស្រាយដ៏ប្រពៃទៅលើអនុសញ្ញាទីក្រុងហ្សឺណែវទីបីនោះ វាលែងជាវិធីម្យ៉ាងដែលអ្នកអានត្រង់ៗតាមន័យពាក្យអាចបកស្រាយភាសាឃ្លានានានៅក្នុងភាសាបែងក្នុងមាត្រា៥ដូចជា “តុលាការមានសមត្ថកិច្ច” និង “ប្រសិនបើមានមន្ទិលសង្ស័យកើតឡើង” ទៀតហើយ ។ ជាគោលប៉ុន្តែតាមន័យត្រង់ៗការអាននេះរដ្ឋការ ប៊ូស ក៏ប្រើប្រាស់ដែរសម្រាប់អះអាងថា ក) គ្មានមន្ទិលសង្ស័យកើតឡើងទាក់ទងទៅនឹងស្ថានភាពរបស់អ្នកទោសនៅហ្គាន់តាណាម៉ូ ហើយខ) ការកំណត់ថាតើមន្ទិលសង្ស័យណាមួយបានកើតឡើងឬអត់នោះមិនតម្រូវឲ្យមានសវនាការដោយ“តុលាការមានសមត្ថកិច្ច”ឡើយ ប៉ុន្តែគ្រាន់តែតាមរយៈការរកឃើញពីសំណាក់រដ្ឋមន្ត្រីក្រសួងការពារជាតិឬប្រធានាធិបតីតែប៉ុណ្ណោះ ។

បញ្ហាច្បាប់ដែលមានតែមនុស្សមួយចំនួនតូចយល់បាននេះបង្ហាញឲ្យឃើញថា វាមានសារសំខាន់ណាស់ទាក់ទងទៅនឹងបច្ចេកទេសដ៏លម្អិត ។ ហេតុអ្វី? មិនមែនដោយសារវាការពារបុគ្គលណាម្នាក់ឲ្យរួចផុតពីការចោទប្រកាន់អំពីឧក្រិដ្ឋសង្គ្រាមនោះទេ (អ្នកដែលអាចទទួលការចោទប្រកាន់ពីបទឧក្រិដ្ឋសង្គ្រាម) ប៉ុន្តែដោយសារអ្នកដែលត្រូវកំណត់ថាមិនមែនឈ្លើយសឹក សុទ្ធចិត្តមានសិទ្ធិតិចតួចណាស់ទាក់ទងនឹងនីតិវិធីក្នុងពេលជំនុំជម្រះក្តី ។ ឈ្លើយសឹកសុទ្ធចិត្ត (ទោះបីជាជនដែលជាប់ចោទពីបទឧក្រិដ្ឋសង្គ្រាមក្តី) ត្រូវតែទទួលបាននូវការគាំពារតាមផ្លូវច្បាប់នៅក្នុងពេលសវនាការដែលកងទ័ពអាមេរិកាំងដែលទទួលការចោទប្រកាន់ពីបទឧក្រិដ្ឋដូចគ្នានេះអាចទទួលបាន (ហើយប្រការទាំងនេះគួរតែយកមកថ្លឹងមើល) ដែល “យុទ្ធជនគ្មានឯកសិទ្ធិ” ទទួលបានតែការគាំពារតាមផ្លូវច្បាប់បន្តិចបន្តួចប៉ុណ្ណោះ ។ បញ្ហាហៀបនឹងកើតឡើងម្តងទៀត ពេលនេះគឺទាក់ទងនឹងខ្មាន់កាំភ្លើងក្រុមកុម្ម៉ង់ដូរបស់អ៊ីរ៉ាក់ដែលមិនស្លៀកពាក់ឯកសណ្ឋាន ដូចនេះមិនអាចចូលជាឈ្លើយសឹកសុទ្ធចិត្តបានទេដែលកាំភ្លើងទាំងនេះមួយចំនួនប្រហែលជាត្រូវបានផ្ទេរឆាប់ៗទៅហ្គាន់តាណាម៉ូ ។

ម្យ៉ាងវិញទៀត បញ្ហានេះបង្ហាញឲ្យឃើញនូវលក្ខណៈដែលមិនទាន់ដាច់ស្រឡះអំពីការតស៊ូមតិដើម្បីកំណត់ថាតើអ្នកណា “ជាម្ចាស់នៃច្បាប់សង្គ្រាម” ។ អង្គជ្រើសរើសតំណាងរាស្ត្រនានាដែលជឿថាខ្លួនជាម្ចាស់នៃច្បាប់សង្គ្រាមនោះ (ក្នុងករណីនេះ រដ្ឋាភិបាលសហរដ្ឋអាមេរិកនៅម្ខាង និងអង្គការសិទ្ធិមនុស្សនៅម្ខាង) មានអារម្មណ៍ថាខ្លួនមានកាតព្វកិច្ចបន្តិចបន្តួចក្នុងការទទួលស្គាល់ដោយស្មោះត្រង់ចំពោះទឡ្ហីករណ៍ប្រឆាំងនឹងការបក

ស្រាយច្បាប់របស់ខ្លួន ។

## គោលការណ៍ជាគ្រឹះ និង ការត្រិះរិះផ្នែកសីលធម៌

ទោះជាមានការតស៊ូមតិទៅលើអំណាចក្នុងការបកស្រាយអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ យ៉ាងណាក៏ដោយ ក៏អនុសញ្ញាទាំងនេះត្រូវបានទទួលយកជាសាកលថាជាច្បាប់ចាប់បង្ខំឲ្យមានការប្រព្រឹត្តិចំពោះមនុស្សស្ថិតនៅក្រោមស្ថានភាពពិសេសយ៉ាងដូចម្ដេច មានដូចជាយោធិន ពលទាហានជើងទឹក ឈ្លើយសឹក ជនស៊ីវិល ។ គោលការណ៍គ្រឹះទាក់ទងនឹងសីលធម៌ និងផ្លូវច្បាប់មានលក្ខណៈច្បាស់ណាស់ ។ ទីមួយ អយុទ្ធជនអាចនឹងមិនត្រូវបានយកធ្វើជាកម្មវត្ថុឬមុខសញ្ញានៃការវាយប្រហារ ហើយក៏មិនត្រូវប្រើជាអ្នកការពារឲ្យគោលដៅយោធាស្របច្បាប់រួចផុតពីការវាយប្រហារដែរ ។ ទីពីរ ប្រតិបត្តិការយោធា ទោះជាដោយអ្នកវាយប្រហារ ឬដោយអ្នកការពារ ត្រូវតែធ្វើដោយយកចិត្តទុកដាក់ដើម្បីបែកឲ្យដាច់រវាងអយុទ្ធជននិងយុទ្ធជន ។ ជាងនេះទៀត មន្ត្រីយោធាត្រូវបញ្ចៀសប្រតិបត្តិការសឹកដែលទំនងជាបង្កឲ្យមានការខូចខាតដល់ជនស៊ីវិល ដែលហួសពីផលប្រយោជន៍ខាងយោធា ។ គួយ៉ាង ប្រសិនបើឆ្នាំសាធារណរដ្ឋអ៊ីរ៉ាក់បានតាំងមូលដ្ឋាននៅក្នុងមជ្ឈដ្ឋានទីប្រជុំជន (ហើយទោះជាអំពើនេះត្រូវបានប្រព្រឹត្តទាំងខុសច្បាប់រួចទៅហើយក្ដី) តាមរយៈការបដិសេធមិនចេញបញ្ជា ឬមិនអនុញ្ញាតឲ្យមានការជម្លៀសជនស៊ីវិលដើម្បីយកធ្វើជាខែលក្ដី សហរដ្ឋអាមេរិកត្រូវតែថ្លឹងថ្លែងឲ្យបានត្រឹមត្រូវរវាងផលប្រយោជន៍នៃការវាយប្រហារការបាត់បង់ជីវិតនិងការបង្កឲ្យមានរបួសទៅលើជនស៊ីវិល ។

គោលការណ៍ទីមួយមានលក្ខណៈដាច់ខាត មិនអនុញ្ញាតឲ្យមានការលើកលែងទេ ។ វានាំឲ្យមានបណ្ដុំនៃតម្រូវការដាក់លាក់នានាសំដៅធានាថា អយុទ្ធជនឬយោធិនដែលឈប់ប្រយុទ្ធដូចជាឈ្លើយសង្គ្រាម មិនត្រូវរងការវាយប្រហារឡើយ គួយ៉ាងដូចជាតម្រូវការដែលថាយុទ្ធជនត្រូវស្លៀកពាក់ជាឯកសណ្ឋានឬសញ្ញាសំគាល់ផ្សេងៗ ហើយស្ពាយកាំភ្លើងជាចំហ ។ ទោះបីជាកាតព្វកិច្ចដាច់ខាតទាំងនេះមានន័យមិនពិតប្រាកដ (ដូចជាអ្វីទើបហៅថាឯកសណ្ឋាន) ហើយទោះបីជាភ័ស្តុតាង ការបកស្រាយនិងចេតនា អាចធ្វើឲ្យមានបញ្ហាស្មុគស្មាញក៏ដោយ ជាគោលការណ៍ប្រការទាំងនេះត្រូវបានអនុវត្តឬក៏មិនអនុវត្តឡើយ ។

ផ្ទុយមកវិញ គោលការណ៍ទីពីរ (បញ្ចៀសការបង្កឲ្យមានការខូចខាតជ្រុលហួសទៅលើជនស៊ីវិល) ទាក់ទងនឹងការថ្លឹងថ្លែងអំពីតម្លៃនិងផលប្រយោជន៍ ហើយធ្វើឲ្យបញ្ហានានាកាន់តែមានលក្ខណៈពិបាកដែលនឹងកើនឡើងនៅពេលអនាគត ។ ថ្លឹងថ្លែងរាល់ថ្ងៃរាល់យប់នូវអ្វីដែលគេគិតថាតម្លៃខាងយោធានេះអាចមានកម្រិតណានៅក្នុងដំណើរការសង្គ្រាមនៅពេលខាងមុខថ្លឹងជាមួយនឹងទិន្នន័យនៃការស៊ើបការណ៍សម្ងាត់ទៅលើចំនួនជនស៊ីវិលស្លាប់ឬរងរបួស ឬថាតើទ្រព្យសម្បត្តិជនស៊ីវិលត្រូវបំផ្លាញដល់កម្រិតណា ។ ការប៉ាន់ស្មានគឺជាល្បែងមួយដែលគេមិនទទួលស្គាល់ឬត្រេកអរឡើយ ។ ការវិនិច្ឆ័យបែបនេះតម្រូវឲ្យមានការវាយតម្លៃតាមការពិតជាក់ស្ដែងនិងការប៉ាន់ស្មានដែលមិនអាចផ្ទាញ់តបតាមផ្លូវច្បាប់បាន វៀរលែងតែមានការបង្ហាញឲ្យឃើញថាមានការធ្វេសប្រហែសដោយឆន្ទៈនិងចេតនា ។ ការធ្វេសប្រហែសធំដុំត្រូវតែមានលក្ខណៈជាការខូចខាតខុសពីធម្មតា ក្នុងនោះរួមទាំងការស្លាប់និងរងរបួសរបស់ជនស៊ីវិលក្នុងកម្រិតមួយគួរឲ្យខ្ញឹមរអើម គួយ៉ាងដូចជាការបាញ់កាំជ្រួចគួសខុសទិសដៅជាដើម ។ ការទទួលខុសត្រូវតាមផ្លូវច្បាប់មិនអាចកំណត់បានដោយគ្រាន់តែមើលទៅលើកម្រិតនៃការខូចខាតព្រមទាំងការបាត់បង់ជីវិតនិងការរងរបួសប៉ុណ្ណោះ ។ មិនមានភាពសមមូលនឹងគ្នាសោះរវាងការតម្រង់កាំជ្រួចខុសគោលដៅដែលតម្រង់ទៅរកដោយប្រើបច្ចេកវិទ្យាល្អបំផុតជាមួយនឹងការរំលោភដោយចេតនាទៅលើច្បាប់សង្គ្រាម ដូចជាការយកមនុស្សធ្វើជារនាំងបាញ់ផ្ដក់មកលើជនស៊ីវិលកុំឲ្យភៀសខ្លួនចេញពីបាស្រា ព្រមទាំងការរំលោភឬសម្លាប់ដោយគ្មានការជំនុំជម្រះទោសមកលើអ្នកទោស ។ គ្មានធាតុផ្សំសម្រាប់វិនិច្ឆ័យសេចក្ដីនេះទេ ឬគ្មានធាតុផ្សំសម្រាប់ថ្លឹងទៅលើតម្លៃនិងផលប្រយោជន៍ក្នុងការសម្រេចថាតើវាជាការកំណត់មុខសញ្ញាមកលើជនស៊ីវិលឬក៏យ៉ាងណា ឬក៏តើវាជាការចាប់ជនស៊ីវិលទាំងនោះជាចំណាប់ខ្មាំង ។ ចំណុចនេះតែងតែមានកំហុសជានិច្ច ។

ប៉ុន្តែ ចំពោះមនុស្សជាច្រើនយល់ថា ការពិត ភាពខុសគ្នាខាងសីលធម៌នេះមានលក្ខណៈជាទឡ្ហីករណ៍សិប្បនិម្មិត ។ ថាវាជា

ទន្ទឹករណ៍ពិតម្ដេចនឹងកើតបើយើងឃើញនៅលើកញ្ចក់ទូរទស្សន៍ និងលើទំព័រកាសែតជារៀងរាល់ថ្ងៃនូវការបាត់បង់ជីវិត និងការរងរបួសមកលើជនស៊ីវិលច្រើនយ៉ាងនេះទៅហើយ (ភាគច្រើនមិនមែនជាជនជាតិអាមេរិកាំង)? និយាយអំពី “ការតម្រង់” ទៅលើបញ្ហាមួយដែលដឹងមុននៅក្នុងករណីជាច្រើននោះ លោកអ្នកអាចនឹងប៉ះជាមួយបញ្ហាមួយទៀត “ដោយចៃដន្យ” មានន័យថាប្រសិនបើប្រការនេះគឺជាអ្វីដែល “ច្បាប់” សង្គ្រាមបានចែងនោះ វាគ្មានអ្វីក្រៅពីឱសថប្រេងលាបបន្ថយការឈឺចាប់ទៅលើសម្បជញ្ញៈរបស់យុទ្ធជនឡើយ ។

មិនតែប៉ុណ្ណោះ ចំពោះមនុស្សរាប់លាននាក់ទូទាំងពិភពលោកយល់ថា តាមពិតមានភាពសមមូលរវាងកលយុទ្ធរបស់អាមេរិកាំង ពោលគឺការវាយប្រហារមកពីលើអាកាស ហើយជជែកការពារថាខ្លួនមិនមានការទទួលខុសត្រូវចំពោះការខូចខាតជាមួយនឹងកលយុទ្ធរបស់អ៊ីរ៉ាក់ដែលខ្វះមធ្យោបាយវាយប្រហារប្រើជនស៊ីវិលរបស់ខ្លួនជាប្រភពសម្ភារនិងសីលធម៌ ដោយមិនគិតថាតើខ្លួនត្រូវរំលោភច្បាប់សង្គ្រាមដូចម្ដេចខ្លះទេ ។ គួរនិយាយបានថា នេះគឺជាជំហររបស់ ឆឺឃីល ដែលមានចេតនាចង់ប្រើវិធីការពារចំពោះការកម្ទេចចោលនូវអ្វីដែលអង់គ្លេសយកមកប្រើ ក្នុងនោះមានការប្រើខ្សែទពុលផងដែរ ដោយគ្មានការគោរពចំពោះជីវិតរបស់ជនស៊ីវិលអង់គ្លេសឡើយ ឲ្យតែ


កងទ័ពខ្មែរក្រហម

ឃើញអ្នកលុកលុយឈានជើងចូលមក ។

ខ្ញុំគិតថាមានវិធីតែមួយគត់ក្នុងការវាយតម្លៃទៅលើការអះអាងប្រកបដោយភាពប្រទាំងប្រទើសទាំងនេះ ។ គំនិតអំពីការខូចខាតដែល"អាចទទួលយកបាន"គឺជាប់នៅក្នុងគំនិតផ្នែកច្បាប់និងសីលធម៌របស់លោកខាងលិច ។ ប៉ុន្តែតាមការពិតវាគឺជាផលិតផលកើតចេញពីការគិតអំពីសីលធម៌តាមបែបគ្រិស្តសាសនាជាជាងអ្វីដែលយើងភាគច្រើនទទួលយកស្រេចទៅហើយតាមលក្ខណៈប្រពៃណី ។ "គោលការណ៍អានុភាពមុខពីរ" បើបែរមកនិយាយអំពីភាពផ្សេងគ្នាផ្នែកសីលធម៌ទៅតាមការសន្មតរវាងផលវិបាកដែលអាចមើលឃើញនៅពេលខាងមុខ



ដោយចេតនានិងអចេតនានោះ គឺគ្មានលក្ខណៈជាក់ស្តែងឡើយ ។ ប៉ុន្តែអាចការពារបានថាជាគោលការណ៍សីលធម៌ ប្រសិនបើយើងគិតពិចារណាទៅលើជម្រើសផ្សេងៗទៀត ។ បដិសេធភាពខុសគ្នាមានន័យថា លោកអ្នកក៏ទទួលយកនូវអហិង្សាជាក់ស្តែង ឬលោកអ្នកមិនទទួលស្គាល់ជីវិតរបស់ជនស៊ីវិល ដោយសារថាលោកអ្នកមានកំហុសចំពោះអ្វីដែលបានកើតឡើង ហើយនៅក្នុងករណីនេះអ្វីមួយនោះក្លាយទៅជាមុខសញ្ញា ។ ការឲ្យហេតុផលចំពោះគោលការណ៍អានុភាពមុខពីរគឺថាវាហាក់ដូចជាថា មានផ្លូវតែមួយគត់សម្រាប់ដើររវាងសន្តិភាពនិយមដែលក្នុងចំណោមពួកយើងភាគតិចអាចទទួលយកនៅក្នុងជីវិតពិតជាមួយនឹងអំពើហិង្សាជាក់ស្តែងដែលបដិសេធនូវភាពចាំបាច់ខាងសីលធម៌ ឬរហូតទៅដល់ព្យាយាមបែងចែករវាងយុទ្ធជននិងអយុទ្ធជនទៀតផង ។

ប៉ុន្តែប្រសិនបើលោកអ្នកទទួលយកនូវគោលការណ៍នៃការបែងចែកច្បាស់ជាមួយគំនិតដែលថាវាជាកិច្ចការសម្របសម្រួលមួយហើយ ។ ហេតុដូចនេះ វាបន្ថែមបន្ទុកខាងសីលធម៌យ៉ាងខ្លាំងមកលើអ្នកដែលពុះពារចង់រកវិធីប្រសើរជាងនេះក្នុងការដាក់ឲ្យជនស៊ីវិលដាច់ពីអ្នកប្រយុទ្ធ ព្រមទាំងក្នុងការអភិវឌ្ឍន៍សមត្ថភាពតាមរយៈបច្ចេកវិទ្យាឬមធ្យោបាយផ្សេងៗទៀត ដើម្បីតម្រង់ឲ្យចំនិងវាយប្រហារចំមុខសញ្ញាយោធា ។ ប្រសិនបើដូចដែលលោកវ៉ៃនី ឆា បានសរសេរថា "ពេលនេះគណនាតាម ពិជគណិតខុស" មិនចេះចប់មិនចេះហើយ ម្តងហើយម្តងទៀតយ៉ាងនេះច្បាប់សង្គ្រាមត្រូវតែគិតពិចារណាអំពីបញ្ហានេះ ។ ម្យ៉ាងវាមានតម្រូវការដាច់ខាតនិងបម្រាមនានា ម្យ៉ាងទៀតការវាយតម្លៃទៅលើតម្លៃនិងផលប្រយោជន៍ ការបាត់បង់ជីវិត និងផលប្រយោជន៍យោធា ពោលគឺការវាយតម្លៃទាំងនេះតែងតែមានការប្រែប្រួលជានិច្ច ។

## សន្ធិសញ្ញាថ្មី និង ការពិភាក្សាថ្មីៗ

ការព្យាយាមដោះស្រាយបញ្ហាស្មុគស្មាញទាំងនេះព្រមទាំងតាក់តែងច្បាប់អំពីបញ្ហាទាំងនេះត្រូវបានធ្វើឡើងដោយការចរចារបស់អង្គការសហប្រជាជាតិនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ។ ពិធីសារបន្ថែមទី១កើតចេញពីការចរចាទាំងនេះ ។ ទោះបីជាសព្វថ្ងៃនេះមានការផ្តល់សច្ចាប័នចំនួន១៦០ប្រទេសដោយមាន "លក្ខខណ្ឌ

បម្រុងផ្សេងៗគ្នាក៏ដោយ ប៉ុន្តែសហរដ្ឋអាមេរិកមិនដែលផ្តល់សច្ចាប័នឡើយ (គួរកត់សម្គាល់ដែរថា អ៊ីរ៉ាក់ក៏មិនបានផ្តល់សច្ចាប័នដែរ)» ។ ប៉ុន្តែប្រការដែលមិនបានទទួលយកនូវសន្ធិសញ្ញាបែបនេះ មន្ត្រីសហរដ្ឋអាមេរិកកាលពី២០ឆ្នាំមុនបានគូសបញ្ជាក់ថា សហរដ្ឋអាមេរិកទទួលយកនូវសន្ធិសញ្ញាទាំងនេះភាគច្រើនដោយមិនទទួលយកទាំងស្រុងឡើយ ។ វានៅតែមានភាពខកចិត្តនិងមន្ទិលសង្ស័យថាក្រសួងការពារជាតិសហរដ្ឋអាមេរិកមិនដែលមានឆន្ទៈចង់ប្រកាសជាសាធារណៈ និងច្បាស់លាស់នូវផ្នែកណាខ្លះដែលខ្លួនទទួលយក ហើយផ្នែកណាខ្លះដែលខ្លួនមិនទទួលយក ព្រមទាំងដោយមូលហេតុអ្វីខ្លះនោះឡើយ ។

ប៉ុន្តែបញ្ហាអាមេរិកចំពោះពិធីសារទី១ ជាទូទៅចែកចេញជាបីផ្នែកសំខាន់ៗ ។ ទីមួយ បទបញ្ញត្តិមួយចំនួនមិនអាចទទួលយកបានជាលក្ខណៈនយោបាយ ។ គោលការណ៍ច្បាប់ *Jus in bello* តែងតែទទូចចង់ឲ្យមានការប្រព្រឹត្តិដូចៗគ្នាពីសំណាក់ភាគីទាំងអស់នៅក្នុងសមរភូមិប្រយុទ្ធ វិធានដូចៗគ្នាទោះជាសម្រាប់សម្ព័ន្ធមិត្តឬក៏សម្រាប់ជនជាតិអាល្លឺម៉ង់ ឬពួកកុម្មុយនិស្តឬមូលធន ។ ប៉ុន្តែពិធីសារទី១ផ្តល់នូវសិទ្ធិដល់យុទ្ធជន ក្នុងនោះមានសិទ្ធិសំខាន់ទទួលបាននូវការប្រព្រឹត្តិត្រឹមត្រូវក្នុងឋានៈជាឈ្លើយសឹក ដោយផ្អែកលើហេតុផលជាក់ស្តែងចំពោះការចូលមកប្រយុទ្ធគ្នា ដោយនិយាយយោងជាពិសេសទៅដល់អ្នកដែលប្រយុទ្ធប្រឆាំងនឹង«របបរើសអើងពូជសាសន៍»ដូចជានៅអាហ្វ្រិកខាងត្បូងក្រោមរបបអាប៉ាថេត ឬការចូលកាន់កាប់របស់ជនបរទេសដូចជានៅអ៊ីស្រាអែលជាដើម ។

ទីពីរ បទបញ្ញត្តិមួយចំនួនចំពោះសហរដ្ឋអាមេរិកហាក់ដូចជាការរឹតត្បិតនូវវិធីសាស្ត្រនិងមធ្យោបាយក្នុងការធ្វើសង្គ្រាមដែលខ្លួនជឿថាមានលក្ខណៈធម្មានុរូប ។ ដូចជា ពិធីសារទី១គ្មានអញ្ញត្រកម្មនៅក្នុងច្បាប់អាវុធនុយក្លេអ៊ែរឡើយ ទន្ទឹមគ្នានេះដែរ ពិធីសារនេះហាមប្រាមការផ្ចាញ់តបមកលើជនស៊ីវិលរួមទាំងការប្រើអាវុធនុយក្លេអ៊ែរតបជាមួយនឹងការវាយប្រហារដោយអាវុធនុយក្លេអ៊ែរ ដែលជាមូលដ្ឋាននៃការធ្វើឲ្យមានការញញើតចំពោះអាវុធនុយក្លេអ៊ែរ ។

ការជំទាស់ទីបីរបស់សហរដ្ឋអាមេរិកទាក់ទងនឹងវិធាននានានៅក្នុងពិធីសារទី១ ដែលសំដៅតម្រូវចិត្តពួកខ្មាំងនិងយុទ្ធជនធម្មតា ដូចជានៅអំឡុងសង្គ្រាមនៅវៀតណាមឬអ៊ីរ៉ាក់ ។ គ្មានអ្វីគួរឲ្យសង្ស័យទេថា វិធានទាំងនេះធ្វើឲ្យជីវិតរបស់យុទ្ធជនធម្មតាមានភាពងាយស្រួល ហើយមានមនុស្សមួយចំនួនអាចចាត់ទុកប្រការនេះថាជាការធ្វើឲ្យច្បាប់សង្គ្រាមមានលក្ខណៈកាន់តែ«យុត្តិធម៌»ឡើង ។ ប៉ុន្តែច្បាប់ទាំងនេះបង្កើតជាគ្រោះថ្នាក់ថ្មីចំពោះជនស៊ីវិល ។ តួយ៉ាងពិធីសារនេះផ្តល់ឋានៈជាយុទ្ធជនស្របច្បាប់ឲ្យដល់ពួកខ្មាំងដែលលាក់ខ្លួន និងអាវុធយុទ្ធភណ្ឌនៅក្នុងចំណោមជនស៊ីវិល ដរាបណាអ្នកប្រយុទ្ធបង្ហាញខ្លួនចំពោះគូបដិបក្ខដែលបើកការវាយប្រហារមុន ពោលគឺមុនពេលការវាយប្រហារចេញពីចំណោមជនស៊ីវិលដែលច្បាស់ណាស់ថានឹងជាប់នៅក្នុងខ្សែគ្រៀម ។ វាជាសំណាងអាក្រក់ចំពោះទាហានបម្រុងរបស់ សាដាម ហ៊ូសេន ដែលប្រទេសអ៊ីរ៉ាក់និងសហរដ្ឋអាមេរិកមិនទាន់ផ្តល់សច្ចាប័នទៅលើពិធីសារនេះនៅឡើយ ដោយសារពិធីសារនេះអាចផ្តល់ការការពារតាមផ្លូវច្បាប់ចំពោះការវាយប្រហាររបស់អ្នកប្រយុទ្ធជាច្រើនប្រសិនបើមិនមានជនស៊ីវិលជួយបិទបាំងទេនោះ ។

មិនតែប៉ុណ្ណោះ ផ្នែកមួយចំនួននៃពិធីសារទី១ ទន្ទឹមគ្នានឹងការដោះស្រាយជាមួយនឹងការវាយប្រហារដោយគ្មានរើសមុខ (ពោលគឺប្រតិបត្តិការសឹកដែលមិនបែងចែកឲ្យបានច្បាស់រវាងយុទ្ធជននិងអយុទ្ធជន) បានរៀបរាប់អំពីកាតព្វកិច្ចរបស់អ្នកការពារកាន់តែសង្ខេបជាងមុនទៅទៀត ។ ប្រការនេះទោះបីជាថាកម្រិតនៃការខូចខាតកើតឡើងនៅក្នុងប្រតិបត្តិការសឹកក៏ដោយ គឺតែងតែត្រូវបានកំណត់ដោយការសម្រេចចិត្តតាំងមូលដ្ឋានយោធារបស់អ្នកការពារឲ្យផុតពីការវាយប្រហារ ។

យ៉ាងណាមិញអង្គការលើកលែងទោសអន្តរជាតិ (អាមណេស្ទីអ៊ីនធឺណាស្យូណាល់) បានចេញរបាយការណ៍មួយកាលពីឆ្នាំមុនស្តីអំពីសកម្មភាពរបស់កងកម្លាំងការពាររបស់អ៊ីស្រាអែលនៅតំបន់ ជេនីន ដែលជាការខកខានគួរឲ្យកត់សម្គាល់ មិនទាំងបានបញ្ជាក់អំពីកាតព្វកិច្ចតាមផ្លូវច្បាប់របស់កងកម្លាំងប៉ាឡេស្ទីនចំពោះជនស៊ីវិលរបស់ខ្លួនឡើយ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សក៏បានចេញរបាយការណ៍ទាំងស្រុងមួយអំពីតំបន់ជេនីន ដែល

លើកឡើងតែពីរបីប្រយោគប៉ុណ្ណោះ អំពីប្រការដែលអ្នកប្រយុទ្ធបារ៉ាឡេស្ទីនបានដាក់មូលដ្ឋាននៅក្នុងចំណោមជនស៊ីវិល ។ (ជាការផ្តល់មុខមាត់ដល់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ហើយប្រហែលជាការឆ្លើយតបទៅនឹងការរិះគន់នោះ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានចាប់ផ្តើមកត់សម្គាល់យ៉ាងប្រុងប្រយ័ត្នទៅលើកាតព្វកិច្ចរបស់កងកម្លាំងការពារ ក៏ដូចជាអ្នកវាយប្រហារដែរ) ។ ចំណែកឯអង្គការកាកបាទក្រហមអន្តរជាតិ នៅក្នុងសារមួយមកពីនាយកអង្គការនេះនៅពេលសង្គ្រាមនៅអ៊ីរ៉ាក់ចាប់ផ្តើមនោះបានអំពាវនាវជាទូទៅដល់ភាគីនានាឲ្យប្រតិបត្តិតាមច្បាប់សង្គ្រាម ប៉ុន្តែសង្កត់ធ្ងន់ទៅលើអ្នកវាយប្រហារ រួមមានសហរដ្ឋអាមេរិកនិងចក្រភពអង់គ្លេស ដោយមិនបាននិយាយចំៗដល់អ្នកការពារខ្លួនខាងភាគីអ៊ីរ៉ាក់ផងទេ ។ ប៉ុន្តែការពិតដែលមិនអាចប្រកែកបានគឺថា ក្របខ័ណ្ឌនៃពិធីសារទី១ ដាក់ស្ពែងបង្កឲ្យមានការធ្វេសប្រហែសបែបនេះឯង ។

## ច្បាប់សង្គ្រាមដែលត្រូវពិចារណាឡើងវិញ

ការពិតនៅត្រង់ថាគ្រប់សង្គ្រាមទាំងអស់គឺជាដើងវិភាគច្បាប់សង្គ្រាមក្រោយៗទៀត ។ ខណៈដែលសង្គ្រាមនៅអ៊ីរ៉ាក់និយាយជាគោលសំខាន់អំពីគោលការណ៍ច្បាប់ដែលចែងច្បាស់លាស់និងការរំលោភបំពានទៅលើគោលការណ៍នោះ វានឹងបញ្ចប់ដោយមានការពិចារណាឡើងវិញនូវច្បាប់ដែលបញ្ជាក់ច្បាស់លាស់ ថាតើគួរធ្វើសង្គ្រាមតាមវិធីណាខ្លះ ។

អស់រយៈពេល២០ឆ្នាំមកហើយ ចំណុចសំខាន់នៃភាពប្រាកដប្រជាក្នុងការបង្កើត ការបកស្រាយ និងការបង្កើតច្បាប់សង្គ្រាម បានផ្លាស់ប្តូរជាបន្តបន្ទាប់ចេញពីការចាត់តាំងយោធាពីសំណាក់រដ្ឋនាំមុខនានា និង“ការអនុវត្តន៍របស់រដ្ឋ”រៀងៗខ្លួន ។ ចំណុចសំខាន់នេះថែមទាំងងាកចេញពីអង្គការកាកបាទក្រហមអន្តរជាតិ (ដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវដែលមានអំណាចពិសេស) និងឈានទៅជាអង្គការក្រៅរដ្ឋាភិបាលកាន់តែសកម្មនិងកាន់តែស្វាហាប់ ដែលក្នុងនោះមានការប្រមូលផ្តុំគ្នាជាពិសេសផលិតចេញបានជាសន្ធិសញ្ញាអូតាវ៉ា ការហាមប្រាមមិនឲ្យប្រើប្រាស់មីន និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ចំណុចសំខាន់ៗរបស់អង្គការក្រៅរដ្ឋាភិបាលនេះគឺមិនអាចខ្វះបានក្នុងបុព្វហេតុមនុស្សធម៌នៅក្នុងពេលមានសង្គ្រាម ។ ប៉ុន្តែយោបល់ផ្លាស់ប្តូរវាហួសពីមានប្រយោជន៍ទៅទៀត ចំណែកឯកម្មសិទ្ធិទៅលើច្បាប់សង្គ្រាមចាំបាច់ត្រូវផ្តល់ទម្ងន់កាន់តែច្រើនទៅលើការអនុវត្តន៍របស់រដ្ឋនៃប្រទេសដែលនាំមុខនានា ។ ប្រការនេះមិនមានន័យថាការអនុវត្តរបស់រដ្ឋគឺសុទ្ធតែមានបញ្ហានោះទេ ហើយក៏មិនមានន័យគ្រប់ការអនុវត្តន៍របស់រដ្ឋសុទ្ធតែមានបញ្ហានោះដែរ ដូចជាអ៊ីរ៉ាក់គឺជារដ្ឋមួយ ហើយរដ្ឋនេះកំពុងតែប្រយុទ្ធគ្នាដែរ ប៉ុន្តែវាមានន័យថា ការអនុវត្តន៍របស់រដ្ឋអធិបតេយ្យដែលកាន់លទ្ធិប្រជាធិបតេយ្យដែលប្រយុទ្ធនៅក្នុងសង្គ្រាមយ៉ាងពិតប្រាកដនោះគួរតែមានលក្ខណៈវិវឌ្ឍន៍ឡើងក្នុងការរៀបចំច្បាប់សង្គ្រាម ។ ប្រការនេះរួមទាំងការលើកកម្ពស់បទដ្ឋាននៃច្បាប់សង្គ្រាមដើម្បីឆ្លុះបញ្ចាំងអំពីការរីកចម្រើននៃបច្ចេកវិទ្យានិងអាវុធទំនើបៗដាក់ស្ពែង ជាបទដ្ឋាននានាដែលគួរតែក្លាយទៅជានិយាមសម្រាប់យោធានាំមុខនានា ទីមួយគឺណាតូ និងយោធាក្រៅពីណាតូទៀត ។

អង្គការក្រៅរដ្ឋាភិបាលងប់ខ្ញាំងពេកទៅលើនីតិវិធីអន្តរជាតិជាងនីតិវិធីក្នុងស្រុក ។ ប៉ុន្តែរបៀបវារៈនេះកាន់តែទោរទន់ទៅរកអន្តរជាតិនិយមដើម្បីផលប្រយោជន៍របស់ផងខ្លួន ហើយគោលបំណងជាក់លាក់នៃរបៀបវារៈនេះគឺសំដៅទប់អធិបតេយ្យភាពរបស់សហរដ្ឋអាមេរិក ។ ដូចនេះរបៀបវារៈនេះបង្កើននូវអនុប្បទានសិទ្ធិអធិបតេយ្យភាពដូចដែលបានចែងនៅក្នុងរបៀបវារៈសិទ្ធិមនុស្ស និងច្បាប់សង្គ្រាម ទៅជាអំពើប្រកបដោយគុណធម៌ដែលរដ្ឋមួយអាចបំពេញតំណាងឲ្យប្រជាពលរដ្ឋរបស់ខ្លួន ។ ផ្ទុយមកវិញ របៀបវារៈនេះផ្តល់ឯកសិទ្ធិដល់អន្តរជាតិនិយមជួនកាលថែមទាំងធ្វើឲ្យមានការដើរថយក្រោយរបស់ច្បាប់សង្គ្រាមទៀតផង ដូចជាផ្តល់ឯកសិទ្ធិដល់យុទ្ធជនខ្ទាមលើសជនស៊ីវិលទៅទៀត ។ ដោយសារហេតុផលនេះ គុណវិបត្តិនៃសង្គ្រាមនៅអ៊ីរ៉ាក់សម្រាប់អនាគតច្បាប់សង្គ្រាមនឹងត្រូវតែមានការយល់ថាការយកចិត្តទុកដាក់ចំពោះពិធីសារទី១ ដែលអនុញ្ញាតឲ្យអ្នកប្រយុទ្ធធម្មតាអាចលាក់ខ្លួនជាមួយជនស៊ីវិលនោះគឺជាការខុសឆ្គង ហើយប្រការដែលសហរដ្ឋអាមេរិកបដិសេធចំណុចនេះគឺជាការត្រឹមត្រូវ ។

និយាយឲ្យកាន់តែទូលាយជាងនេះទៀត ប៉ុន្មានឆ្នាំថ្មីៗនេះ អង្គការក្រៅរដ្ឋាភិបាលបាននិងកំពុងតែលើកកម្ពស់ច្បាប់សង្គ្រាមឲ្យមានលក្ខណៈសុក្រឹត ក្នុងការរក្សាឲ្យបាននូវមនោគមវិជ្ជាសិទ្ធិមនុស្សបានគត់មត់ ។ តាមការអនុវត្តន៍ជាក់ស្តែងភាពសុក្រឹតនិយមនេះគឺសំដៅទៅលើភាគីម្ខាងនៃជម្លោះតែប៉ុណ្ណោះ ពោលគឺភាគីដែលព្យាយាមគោរពតាមច្បាប់ ។ ផលវិបាកទីពីរនៃសង្គ្រាមនៅអ៊ីរ៉ាក់សម្រាប់អនាគតច្បាប់សង្គ្រាមនឹងក្លាយជាការរារាំងដល់ការលើកតម្កើងបទដ្ឋាន ធ្វើសង្គ្រាមឲ្យខ្ពស់ក្នុងការការពារជនស៊ីវិលនៅខណៈដែលបន្ទុកនោះធ្លាក់តែទៅលើកងកម្លាំងវាយប្រហារដែលមិនធ្លាក់ទៅលើភាគីទាំងសងខាងដែលធ្វើសង្គ្រាមជាមួយគ្នា ។ កិច្ចការបច្ចុប្បន្ននេះផ្តល់រង្វាន់លើកទឹកចិត្តដល់កងកម្លាំងការពារខ្លួនឲ្យទទួលស្គាល់ថាឧក្រិដ្ឋសង្គ្រាមប្រឆាំងនឹងជនស៊ីវិលរបស់ខ្លួន គឺជាយុទ្ធសាស្ត្រដ៏ល្អបំផុតសម្រាប់ទប់ទល់នឹងសត្រូវដែលមានអំណាចប៉ុន្តែមានលក្ខណៈហ្មត់ចត់ ។ នៅចុងបញ្ចប់ការប្រជុំប្រជានបង្កើតឡើងនូវច្បាប់សង្គ្រាមមួយដែលសន្មតទៅតាមការអនុវត្តជាក់ស្តែងថា បន្ទុកទាំងអស់ត្រូវធ្លាក់លើភាគីតែម្ខាង ជាភាគីដែលមានបច្ចេកវិទ្យាខ្ពស់ និងយោធាដែលមិនសូវអស់សង្ឃឹម ។ ក្រោយពីកាំជ្រួចមីស៊ីលគ្រូសត្រូវបានបាញ់ចេញ ហើយធ្វើឲ្យយុទ្ធជនជំនួសក្នុងពេលសង្គ្រាមស្ងប់ស្ងៀម យើងនឹងក្រឡេកទៅក្រោយមើលសង្គ្រាមដែលបានធ្វើឡើង ។ អ្វីដែលយើងនឹងរកមើលគឺថា អត្ថន័យនៃការធ្វើសង្គ្រាមដែលមាន «ភាពស៊ីមេទ្រីគ្នា» គឺមិនមែនអ្វីដែលយើងបានគិតឃើញទេ ។ បញ្ហានេះមិនខុសគ្នាច្រើនពីបញ្ហាបច្ចេកវិទ្យាទេ ។ ប៉ុន្តែទម្រង់នៃការធ្វើសង្គ្រាមបានស្តែងឲ្យឃើញសាជាថ្មីថាតាមការសន្មតដោយស្ងៀមស្ងាត់ថាខាងភាគីខ្សោយត្រូវតែប្រយុទ្ធដោយប្រើប្រាស់ការរំលោភបំពានជាលក្ខណៈប្រព័ន្ធទៅលើច្បាប់និងវិធីសាស្ត្ររបស់ខ្លួន ។ ប្រការនេះមិនមែនជាមូលដ្ឋានច្បាប់សង្គ្រាមប្រកបដោយនិរន្តរភាពនោះទេ ។ បញ្ហាគឺនៅត្រង់ថាមិនមានភាពស្មើគ្នាក្នុងការធ្វើសង្គ្រាម ។

**រយៈណោគ អាន់ដឺសុន, កម្មវិធីឧក្រិដ្ឋកម្មសង្គ្រាម**

## សេចក្តីជូនដំណឹងរបស់សមាគមអ្នកនិពន្ធខ្មែរ

សមាគមអ្នកនិពន្ធខ្មែរសូមជម្រាបដល់ប្រជាជនកម្ពុជាគ្រប់រូបថា សមាគមបានរៀបចំ «**វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជា-ធិបតេយ្យ**» ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចជា៖

◆ រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំសាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំ គឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

សមាគមអ្នកនិពន្ធខ្មែរសូមអំពាវនាវដល់ប្រជាជនកម្ពុជាចូលរួមសរសេរអត្ថបទទាំងឡាយអំពី៖ ១) រឿងរ៉ាវផ្ទាល់ខ្លួន ២) ព្រឹត្តិការណ៍ដែលលោកអ្នកធ្លាប់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិង ៣) ផ្តល់ដំណោះស្រាយចំពោះបញ្ហាប្រវត្តិសាស្ត្រនេះ ។ ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។

សមាគមអ្នកនិពន្ធខ្មែរនិងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានកិត្តិយសដោយចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តី «ស្វែងរកការពិត» ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ ការចូលរួមរបស់លោកអ្នកគឺជាការរួមចំណែកលើកស្ទួយតម្លៃនៃការសរសេរនិងចំណេះដឹង ។

សូមផ្ញើអត្ថបទរបស់លោកអ្នកមកសមាគមអ្នកនិពន្ធខ្មែរទីស្នាក់ការៈ វត្តបទុមវតី ភ្នំពេញ ឬទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៨៣ ០៧២ និង០១២ ៩៨៨ ១៧៦ ចាប់ពីថ្ងៃទី២០ ខែឧសភា រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៣ ។

**យូ ប៊ូ**

**ប្រធានសមាគមអ្នកនិពន្ធខ្មែរ**

# ប្រសិនបើមេដឹកនាំខ្មែរក្រហមស្លាប់អស់

## ខៀវ ប៉ុណ្ណារី ៖ ជនរងគ្រោះនៃអំពើអាស្រូវប្ដី

មរណភាពរបស់ ខៀវ ប៉ុណ្ណារី នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០០៣ ធ្វើឲ្យមានការផ្ដោតអារម្មណ៍កាន់តែច្រើនឡើងទៅលើមេដឹកនាំខ្មែរក្រហមដែលមានវ័យកាន់តែចាស់ ព្រមទាំងការរៀបចំឲ្យមានតុលាការកាត់ទោសមេដឹកនាំដែលនៅរស់ទាំងស្រីទាំងប្រុសដែលបានប្រព្រឹត្តអំពើឃោរឃៅកាលពីអតីតកាល ។ ការស្លាប់របស់ ខៀវ ប៉ុណ្ណារី មានសក្ដានុពលក្នុងការបំភ្លឺដល់រឿងមួយទៀតដែលគេតែងតែមើលរំលងទាក់ទងនឹងអតីតកាលរបស់ខ្មែរក្រហម ពោលគឺតួនាទីរបស់ស្ត្រីដែលជាជនដៃដល់ផង និងជាជនរងគ្រោះផង ។ ប៉ុន្តែគួរឲ្យសោកស្ដាយ ជារឿយៗស្ត្រីដែលជាប្រធានបទនៃការសិក្សាត្រូវបានផាត់ចោល ហើយបែរជានិយាយតែអំពីចំណុចសំខាន់ៗរបស់ខ្លួននៅក្នុងប្រវត្តិសាស្ត្រទៅវិញដូចជាប្រពន្ធរបស់បុរសល្បីល្បាញម្នាក់ ។ ខៀវ ប៉ុណ្ណារី គឺជាប្រធានបទមួយដែលចាំបាច់ ប៉ុន្តែមិនមែនសិក្សាត្រឹមតែភាពជាប្រពន្ធរបស់គាត់ទេ គឺត្រូវសិក្សាអំពីសិទ្ធិរបស់គាត់ផ្ទាល់ទៀតផង ។ ម្យ៉ាងវិញទៀតគួរឲ្យចាប់អារម្មណ៍និងអស្ចារ្យណាស់ក្នុងការអានដំណើររឿងដ៏វែងឆ្ងាយតាំងពីវ័យកុមាររបស់ ប៉ុណ្ណារី ចាប់ពីសិស្សសាលាដែលអាចនឹងមានជោគជ័យរហូតមកដល់នារីជាមេដឹកនាំមួយរូបនៃរបបយង់ឃ្នងរួចមកក្លាយជាស្ត្រីវិកលចរិតដែលត្រូវការចាំបាច់នូវការថែទាំឥតដាច់ ។ ដោយសារខ្វះប្រភពឯកសារដើមនិងឯកសារទីពីរទាក់ទងនឹងជីវិតរបស់ ខៀវ ប៉ុណ្ណារី ហើយដោយសារភាពរអាក់រអួលនៃដំណើររឿងដោយសារភាពវិកលរបស់ ប៉ុណ្ណារី បណ្ដាលឲ្យការស៊ើបអង្កេតអំពីជីវិត និងពេលវេលាដែល ខៀវ ប៉ុណ្ណារី បានឆ្លងកាត់នោះ មានសំណួរច្រើនជាងចម្លើយ ។

ខៀវ ប៉ុណ្ណារី កើតឆ្នាំ១៩២០ នៅខេត្តបាត់ដំបង ។ ឪពុករបស់ ខៀវ ប៉ុណ្ណារី គឺជាចៅក្រម ។ គ្មានឯកសារដែលរក្សាទុកនិយាយអំពីម្ដាយរបស់ ខៀវ ប៉ុណ្ណារី ឡើយ ។ បើតាមសំណេររបស់ អេលីហ្សាប៊ែត ប៊ែកយ័រ ដែលនិពន្ធសៀវភៅក្រោមចំណងជើងថា «ពេលសន្ធ្រាមផុតរលត់ទៅ» បានបញ្ជាក់ថាក្រោយពេល ខៀវ ប៉ុណ្ណារី និងប្អូនស្រី ត្រឡប់មកពីទីក្រុងប៉ារីសវិញ អ្នកទាំងពីរមិនបានមកលេងនឹងម្ដាយដែលខំមកស្កាត់រកជួបនៅភ្នំពេញហើយរង់ចាំអស់រយៈពេលពីរខែនោះទេ ។ ការឃ្លាតចាកពីម្ដាយបែបនេះគឺដោយសារមានបញ្ហានៅក្នុងគ្រួសារ ។ ឪពុកអ្នកទាំងពីរដែលរត់ចោលម្ដាយទៅរកស្រីផ្សេង ។ ទោះបីជា ខៀវ ប៉ុណ្ណារី និង ខៀវ ធីរិទ្ធ ទទួលបានជោគជ័យក្នុងការសិក្សានៅប្រទេសកម្ពុជាក្ដី ប៉ុន្តែនៅពេលទៅបន្តការសិក្សានៅប្រទេសបារាំង ខៀវ ប៉ុណ្ណារី មានអារម្មណ៍ជិតដាមយ៉ាងជ្រាលជ្រៅដោយសារការបែកបាក់គ្រួសារនេះ ។

ប៉ុណ្ណារី និង ធីរិទ្ធ រៀនចប់នៅវិទ្យាល័យស៊ីសុវត្ថិ ។ ប៉ុណ្ណារី គឺជាស្ត្រីទីមួយ ដែលបានទទួលសញ្ញាប័ត្របាក់ឌុបមកពីប្រទេសបារាំង ។ ចំណែកឯប្អូនស្រីរបស់ ប៉ុណ្ណារី គឺជាស្ត្រីទីមួយដែលទទួលបានសញ្ញាប័ត្រអក្សរសាស្ត្រអង់គ្លេស ។ សមិទ្ធផលទាំងនេះហាក់មានសារសំខាន់ចេញពីឋានៈរបស់ខ្លួនក៏ពិតមែន ប៉ុន្តែសមិទ្ធផលទាំងនេះមានកិត្យានុភាពតិចជាងកាលពីដំណាក់កាលដំបូង ។ សញ្ញាប័ត្របាក់ឌុបរបស់ ប៉ុណ្ណារី មានតម្លៃស្មើនឹងសញ្ញាប័ត្រថ្នាក់វិទ្យាល័យនៅក្នុងប្រព័ន្ធអប់រំមួយដែលមានលក្ខណៈខ្សោយតែប៉ុណ្ណោះ ។ មិនតែប៉ុណ្ណោះ កិត្យានុភាពរបស់ ប៉ុណ្ណារី និង ធីរិទ្ធ ដែលបានមកពីការអប់រំថ្នាក់សម្រាំងបែបនេះ គឺបានមកក្រោយពីបក្សកុម្មុយនិស្តកម្ពុជាទទួលបានភាពល្បីល្បាញ ។ ប្រការនេះមិនមែនមានន័យថា ប៉ុណ្ណារី មិនឆ្លាតនោះទេ ប៉ុន្តែគឺចង់បញ្ជាក់ថាឋានៈដែល ប៉ុណ្ណារី ទទួលបានមិនគួរជាការបញ្ជាក់អំពីជោគជ័យរបស់ ប៉ុណ្ណារី នោះឡើយ ។

នៅឆ្នាំ១៩៤៩ ខៀវ ប៉ុណ្ណារី ធ្វើដំណើរជាមួយប្អូនស្រីទៅកាន់ទីក្រុងប៉ារីសដើម្បីយកសញ្ញាប័ត្រខាងអប់រំ ។ បំណងរបស់ ខៀវ ធីរិទ្ធ នៅទីក្រុងប៉ារីសគឺចង់ចូលរៀននៅសាកលវិទ្យាល័យ

និងរៀបការជាមួយ អៀង សារី ដែលជាមេដឹកនាំកុម្មុយនិស្ត ទើបតែលេចមុខនិងរៀនមុន ខៀវ ធីរិទ្ធ មួយឆ្នាំនៅវិទ្យាល័យស៊ីសុវត្ថិ ។ ឱកាសនេះធ្វើឲ្យ ប៉ុណ្ណារី ជួបគ្នាជាមួយនឹង សាឡុត ស ដែលជាមេដឹកនាំកុម្មុយនិស្តម្នាក់ដែលក្រោយមកមិនយូរប៉ុន្មាន មានរហស្សនាមថា “ប៉ុល ពត” មានអាយុប្អូន ប៉ុណ្ណារី ៥ឆ្នាំ ។

នៅឆ្នាំ១៩៥១ សាឡុត ស ក្រោយពីប្រឡងធ្លាក់បីឆ្នាំជាប់ៗគ្នាមក ត្រូវរដ្ឋាភិបាលផ្តាច់អាហារូបករណ៍ ហើយក៏សម្រេចចិត្តត្រឡប់មកប្រទេសកម្ពុជាវិញ ។ ខៀវ ប៉ុណ្ណារី ក៏ត្រូវបានផ្តាច់អាហារូបករណ៍ដែរ ប៉ុន្តែមិនមែនធ្លាក់ដោយសារពិន្ទុមិនល្អនោះទេ ផ្ទុយមកវិញគឺដោយសារការពាក់ព័ន្ធនយោបាយ គឺការចាប់ផ្តើមកសាងខ្សែរយៈកុម្មុយនិស្ត ។ ត្រង់ចំណុចនេះមិនមានអ្វីបញ្ជាក់ឲ្យបានច្បាស់លាស់ទេ ថាតើ ប៉ុណ្ណារី មានការពាក់ព័ន្ធជាមួយនឹងមនោគមវិជ្ជាកុម្មុយនិស្តដោយរបៀបណា ។ ប្អូនស្រីរបស់ ប៉ុណ្ណារី បានជំរុញឲ្យ ប៉ុណ្ណារី ចូលរៀនវគ្គសិក្សាទ្រឹស្តីម៉ាក្សស៊ីសនិយម នៅទីនោះហើយដែល ប៉ុណ្ណារី បានជួបជាមួយ សាឡុត ស ។ ប៉ុន្តែគ្មានឯកសារណាបញ្ជាក់អំពីជំនឿរបស់ ប៉ុណ្ណារី ទៅលើកុម្មុយនិស្តនិងប្រសិទ្ធភាពរបស់លទ្ធិកុម្មុយនិស្ត ។ គេអាចត្រឹមតែស្មានៗថា ការសេពគប់ជាមួយ សាឡុត ស បានបង្ហាញអំពីចំណាប់អារម្មណ៍របស់ ប៉ុណ្ណារី ទៅលើមនោគមវិជ្ជាកុម្មុយនិស្ត ព្រមទាំងភ្ជាប់ ប៉ុណ្ណារី យ៉ាងមាំទៅនឹងចលនានេះ ដោយមិនគិតអំពីជំនឿផ្ទាល់ខ្លួន ។

នៅពេលដែលអ្នកទាំងពីរវិលត្រឡប់មកភ្នំពេញវិញដែលជាទីក្រុងមួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់សម្តេច សីហនុ ប៉ុណ្ណារី បានចាប់ផ្តើមបោះពុម្ពផ្សាយទស្សនាវដ្តីមួយមានចំណងជើងថា “នារី” ។ ទស្សនាវដ្តីនេះមានផ្សាយអំពីការធ្វើម្ហូបនិងអត្ថបទនានាអំពីម៉ូតខោអាវទាន់សម័យ ព្រមទាំងការថែរក្សាសម្ផស្ស ក៏ដូចជាបញ្ហាសង្គមដូចជាការចិញ្ចឹមកូនជាដើម ដោយមានចំណងជើងគួរឲ្យទាក់ទាញដូចជាថា “តើគួរអប់រំកុមារនៅក្នុងសេរីភាព ឬការជិះជាន់” ។ ប៉ុណ្ណារី បានបកប្រែរឿងនិទានពីភាសាបារាំងដូចជា “អ្នកភ្ជួរស្រែនិងកូន” ហើយបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីនារីដែលដាក់លក់នៅហាង “Petit Paris” នៅទីក្រុងភ្នំពេញ ។

នៅក្នុងអំឡុងពេលនៃការបំពេញការងារនេះ ប៉ុណ្ណារី បង្ហាញនូវសមានចិត្តទៅរកកុម្មុយនិស្តតិចតួចណាស់ ។ ម៉ី កំផត ដែលក្លាយជាប្រធានធនាគារឯកជនដ៏ធំមួយនៅទីក្រុងភ្នំពេញ គឺជាសិស្សរបស់ ប៉ុណ្ណារី នៅវិទ្យាល័យឆ្នាំដំបូង ។ លោកនៅចាំបានថា ប៉ុណ្ណារី មានប្រាជ្ញាវ័យឆ្លាតនិងមានគំនិតជាតិនិយម ប៉ុន្តែមិនដឹងថានៅក្នុងថ្នាក់រៀនគំនិតកុម្មុយនិស្តនិងជាតិនិយមនេះចេញពីខ្លួន ប៉ុណ្ណារី ផ្ទាល់ឬជាគំនិតរបស់ សាឡុត ស ដែលរៀបការជាមួយគ្នានៅឆ្នាំ១៩៥៦នោះទេ ។

ប្អូនស្រីរបស់ ប៉ុណ្ណារី ឈ្មោះ អៀង ធីរិទ្ធ និយាយថានៅសម័យនោះ ខ្លួននិងប្រពន្ធរបស់អ្នកដទៃៗទៀតត្រូវតែខិតខំធ្វើការងារដើម្បីឧបត្ថម្ភគ្រួសារនិងបក្ស ពីព្រោះប្តីៗរវល់ចាត់ចែង ហើយអ្នកដទៃទៀតមិនទទួលបានការងារមានប្រាក់កម្រៃខ្ពស់ទេ ។ អៀង ធីរិទ្ធ សរសេរថា “ខ្ញុំឈប់ធ្វើការងារនយោបាយដើម្បីយកពេលទៅបង្រៀននៅសាលារដ្ឋ ។ បងស្រីនិងខ្ញុំទាំងពីរនាក់បងប្អូនជាគ្រូបង្រៀននៅវិទ្យាល័យសាលារដ្ឋ ។ ដើម្បីរស់ខ្ញុំត្រូវតែមានការងារធ្វើ” ។ អ្នកទាំងពីរប្រហែលជាផ្តល់ថវិកាដល់បក្ស ។ ភស្តុតាងថ្មីៗបង្ហាញថា ថវិកាភាគច្រើនបានមកពីប្រទេសចិន មិនមែនបានមកពីវិទ្យាល័យដែល ប៉ុណ្ណារី និងប្អូនស្រីបង្រៀនឡើយ ។

មានភស្តុតាងមួយចំនួនបង្ហាញថា ប៉ុណ្ណារី បន្តធ្វើការបក្សយ៉ាងសកម្ម មិនត្រឹមតែឧបត្ថម្ភបក្សជាថវិកាប៉ុណ្ណោះទេ ប៉ុន្តែភស្តុតាងបញ្ជាក់អំពីបញ្ហានេះមានលក្ខណៈមិនពេញលេញឡើយ ។ នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ មានការបាញ់ប្រហារគ្នានៅតាមវិថីនានានៅទីក្រុងភ្នំពេញរវាងជនកុម្មុយនិស្តនិងកងកម្លាំងសីហនុ ។ នៅក្នុងការវាយប្រយុទ្ធមួយនោះ ខៀវ ប៉ុណ្ណារី ហៀបតែនឹងត្រូវចាប់ខ្លួនបានទៅហើយ ប៉ុន្តែនៅមិនទាន់ដឹងថា ប៉ុណ្ណារី ត្រូវចាប់ខ្លួនខុសកន្លែងឬខុសពេលវេលា ឬក៏ ប៉ុណ្ណារី ជាសមាជិកសកម្មនៅក្នុងការប្រយុទ្ធនោះយ៉ាងណានោះទេ ។ ការបង្ហាញមួយទៀតអំពីការបន្តបំណងនយោបាយរបស់ ប៉ុណ្ណារី គឺការបង្កើតអង្គការនារីកុម្មុយនិស្តនៅឆ្នាំ១៩៦១ ។ មិនតែប៉ុណ្ណោះសោត នៅឆ្នាំ១៩៧៣ ប៉ុណ្ណារី ត្រូវបានតែងតាំងជាលេខាបក្សខេត្តកំពង់ធំ ។ ក្រោមការគ្រប់គ្រងរបស់ ប៉ុណ្ណារី តំបន់នេះក្លាយជាតំបន់តឹងរ៉ឹងខ្លាំងណាស់ ដែលអនុវត្តនយោបាយបក្សបានកម្រិតខ្ពស់បំផុត ។ យុទ្ធជនមកពីតំបន់នេះរំឭកឡើងវិញថា

"នៅតំបន់កំពង់ធំ អង្គការដឹកនាំដោយមនុស្សម៉ឺងម៉ាត់ណាស់ ។ វិន័យរឹងរិតតែគួរឲ្យខ្លាច ។ ការសម្លាប់កើតមានច្រើន..." ។

ប៉ុន្តែចម្ងល់នៅតែមានទៅលើសារជាតិពិតនៃអង្គការនារីនេះដែល ប៉ុណ្ណារី បង្កើតឡើងដោយស្ងាត់ៗនៅឆ្នាំ១៩៦១ ។ មកដល់ឆ្នាំ១៩៧៦ អង្គការនេះប្រែឈ្មោះទៅជា "សមាគមនារីកម្ពុជាប្រជាធិបតេយ្យ" ។ វាអាចជាការពិតដែលថា អង្គការនោះមានបំណងក្តាប់អំណាចនិងឥទ្ធិពលពិតប្រាកដ ប៉ុន្តែការប្រយុទ្ធគ្នាដែលរុញច្រាន ប៉ុណ្ណារី និងមិត្តរួមលទ្ធិកុម្មុយនិស្តដទៃទៀតឲ្យទៅនៅជនបទកាលពីឆ្នាំ១៩៦៥ ក៏មិនស្របគ្នាទៅនឹងបេសកកម្មរបស់អង្គការនេះដែរ ។ វាហួសពីការពិតទៅទៀតថាអង្គការនេះដើរតួយ៉ាងសំខាន់នៅក្នុងការទាក់ទាញស្ត្រីឲ្យចូលបម្រើបុព្វហេតុបដិវត្តន៍ ហើយមានមន្ទិលសង្ស័យថាក្រោយឆ្នាំ១៩៧៥ ប៉ុណ្ណារី គឺជាមេដឹកនាំសំខាន់ម្នាក់ ។ ចលនាកុម្មុយនិស្តឡាវនិងវៀតណាមបានព្យាយាមអស់ជាច្រើនឆ្នាំមកហើយក្នុងការទាក់ទងជាមួយសមាគមនារីកម្ពុជា ពីព្រោះអតីតចលនាទាំងនេះមានអង្គការនារីដែលមានឥទ្ធិពលជាច្រើន ។ រហូតមកដល់ឆ្នាំ១៩៧៦ ទើបសមាគមនារីកម្ពុជាចាប់ផ្តើមដំណើរការដ៏សំខាន់របស់ខ្លួនទៅលើក្រុមផ្សេងៗទៀត ។ ចាប់ពីថ្ងៃទី២៨ ខែសីហា ដល់ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៧៦ គណៈប្រតិភូដែលមានសមាជិកប្រាំនាក់បានធ្វើដំណើរទៅប្រទេសវៀតណាម ប៉ុន្តែក្នុងពេលនោះ ខៀវ ប៉ុណ្ណារី ដែលជាប្រធានសមាគមនារីកម្ពុជាប្រជាធិបតេយ្យជាផ្លូវការ មិនបានចូលរួមជាមួយគណៈប្រតិភូនោះឡើយ ។ សមាគមនារីកម្ពុជាបានអញ្ជើញខាងវៀតណាមមកបំពេញទស្សនកិច្ចនៅកម្ពុជាម្តង ។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៧ គណៈប្រតិភូវៀតណាមបានមកដល់ទីក្រុងភ្នំពេញ ។ តាមសម្តីរបស់អ្នកដឹកនាំគណៈប្រតិភូសមាគមនារីវៀតណាម



ហាទីគី បានឲ្យដឹងថា ប៉ុណ្ណារី គ្មានវត្តមាននៅអំឡុងពេលទស្សនកិច្ចចំនួនមួយសប្តាហ៍នោះទេ ។ ធីរិទ្ធ ពន្យល់ហេតុផលថា ខ្លួនគឺជាអ្នកតំណាងសមាគមនារីកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលដែលហាទីគី សួរអំពី ប៉ុណ្ណារី, ធីរិទ្ធ ឆ្លើយថា ប៉ុណ្ណារី មានជំងឺ ។ មិនតែប៉ុណ្ណោះ អត្ថបទយកការណ៍អំពីទស្សនកិច្ចនេះដែលផ្សាយតាមវិទ្យុភ្នំពេញ មិនបាននិយាយអំពី ប៉ុណ្ណារី ហើយក៏គ្មានជនជាតិខ្មែរណាម្នាក់និយាយថា ប៉ុណ្ណារី ជាប្រធានសមាគមនារីកម្ពុជាដែរ ទោះបីជាគ្មានអ្នកណាចេញមុខកាន់តំណែងនេះក៏ដោយ ។ នៅជិតបញ្ចប់ដំណើរទស្សនកិច្ចនេះ ហាទីគី មានចំណាប់អារម្មណ៍ថា គ្មានសមាគមនារីកម្ពុជាពិតប្រាកដទេ ។

អាចមានការពន្យល់ពីរយ៉ាងទៅលើភាពស្រពេចស្រពិលនេះ ។ វាទំនងដូចជាថា នៅត្រង់ចំណុចពេលវេលានេះ ប៉ុណ្ណារី ចេញជារោគសញ្ញាវិកលចរិតរួចទៅហើយ គ្រាន់តែជំងឺនេះមិនទាន់វិវត្តពេញទំហឹង ។ ប៉ុណ្ណារី គឺជាប្រធានអង្គការនេះយ៉ាងពិតប្រាកដ ហើយការលាលែងរបស់ ប៉ុណ្ណារី អាចបណ្តាលឲ្យសមាគមនេះរលាយ ។ ផ្ទុយមកវិញ អង្គការនេះមិនដែលមានតួនាទីច្រើននៅក្នុងចលនាកុម្មុយនិស្តកម្ពុជាទេ ហើយការលាលែងរបស់ ប៉ុណ្ណារី មានឥទ្ធិពលតិចតួចប៉ុណ្ណោះទៅលើតួនាទីដែលមានលក្ខណៈខ្សោយស្រាប់ទៅហើយនោះ ។ ទោះជាក្នុងកម្រិតណាក៏ដោយ នៅពេលដែលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជាពេញទំហឹង សុខភាពផ្លូវចិត្តរបស់ ប៉ុណ្ណារី ស្ថិតក្នុងដំណើរដាបទៅៗឈានទៅរកភាពទ្រុឌទ្រោមទៅហើយ ។ មានការលើកឡើងមួយចំនួនថា វិកលភាពរបស់ ប៉ុណ្ណារី កាន់តែធ្ងន់ធ្ងរឡើងនៅពេលដឹងថា ប៉ុល ពត មានប្រពន្ធរួចម្តងទៅហើយនៅមុនពេលដែលខ្លួនរៀបការជាមួយ ប៉ុល ពត នោះ ហើយថាថែមទាំងមានកូនប្រុសមួយទៀតផង ។ ដោយមានការឈឺចាប់ នឹងការជិតក្បត់របស់ឪពុកខ្លួនដែលរត់ចោលម្តាយទៅរកស្រីបម្រើក្មេង ការដឹងថា ប៉ុល ពត មានប្រពន្ធមានថែមទាំងកូននោះ អាចធ្វើឲ្យ ប៉ុណ្ណារី កាន់តែវិលវល់មួយកម្រិតទៀត ។ ប៉ុណ្ណារី ទទួលការមើលថែទាំក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ទាំងនៅក្នុងផ្ទះ និងនៅក្រៅក្រុងដែលស្ថិតនៅឆ្ងាយពីប្តីខ្លួន ។ ប្រជាជនកម្ពុជាបានខិតខំប្រឹងប្រែងធ្វើការកសាងសង្គមជាតិឡើងវិញអស់រយៈពេលជាង២០ឆ្នាំហើយ ចំណែកឯ ប៉ុណ្ណារី វិញ នៅតែរីករាយក្នុងលក្ខណៈវិកលកម្មរហូតដោយមិនដឹងអំពីទុក្ខវេទនានិងភាពខ្ទេចខ្ទាំ ដែលត្រូវធ្លាក់មកលើប្រទេសបក្សនិងស្វាមីរបស់ខ្លួន ជាពិសេសចំពោះខ្លួនឯងផ្ទាល់ឡើយ ។

មរណភាពរបស់ ប៉ុណ្ណារី នៅក្នុងឆ្នាំនេះទំនងជាមិនដូចការស្លាប់របស់មេដឹកនាំខ្មែរក្រហមផ្សេងៗទេ ពោលគឺមិនមានផលប៉ះពាល់ដល់ការចងចាំជាសមូហភាពនៅកម្ពុជាឡើយ ។ ការចងចាំរបស់ ប៉ុណ្ណារី បានបាត់បង់យូរណាស់មកហើយ ចាប់ពីមុនពេលការស្លាប់របស់ ប៉ុណ្ណារី មកម្ល៉េះ ហើយប្រសិនបើ ប៉ុណ្ណារី នៅរស់ក៏មិនអាចជួយដល់តុលាការបានច្រើនដែរ ។ ប៉ុន្តែមរណភាពនេះធ្វើឲ្យយើងស្វែងរកបញ្ហាអំពីសមភាព និងអំណាចនៅក្នុងរបបខ្មែរក្រហម ។ ខ្មែរក្រហមមិនបានធ្វើការងារឲ្យបានគ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរស្ថានភាពស្ត្រីនៅក្នុងប្រទេសកម្ពុជាឲ្យកាន់តែប្រសើរឡើង ទោះជាខ្លួនឃោសនាអំពីសមភាពនេះគ្រប់ពេលក៏ដោយ ។ ខ្មែរក្រហមបានផ្លាស់ប្តូរស្ថានភាពនៅកម្ពុជា ប៉ុន្តែបែរបានផ្លាស់ប្តូរឲ្យទៅរកឋាននរកសម្រាប់បុរសនិងស្ត្រី ។ មានយុត្តិធម៌ដែលគួរឲ្យរំភើបនៃដំណើរចាប់ផ្តើមពីខ្ពស់មកទាបធ្លាក់ចូលក្នុងវិកលភាព ។ ប៉ុន្តែក៏មានយុត្តិធម៌ត្រូវខកខានដែរ ។ ប៉ុណ្ណារី មិនត្រូវប្រឈមមុខនឹងបាបកម្មរបស់ខ្លួនឡើយ ។ ប៉ុណ្ណារី ត្រូវបានការពារដោយវិកលភាពរបស់ខ្លួន ។ ប្អូនស្រីរបស់ ប៉ុណ្ណារី អាចផ្តល់កិត្តិយសឲ្យ ប៉ុណ្ណារី នៅពេលបូជាសពជាមួយនឹង "អំពើល្អនិងការលះបង់... សម្រាប់ប្រជាជនជាទីស្រលាញ់និងជាតិរបស់ខ្លួន" ។ វាហាក់ដូចជាច្បាស់ណាស់ថា ប៉ុណ្ណារី ដែលមានការពាក់ព័ន្ធនឹងរបបប្រល័យពូជសាសន៍គឺជាជនដៃដល់ ប៉ុន្តែគេត្រូវតែទទួលស្គាល់ថា ប៉ុណ្ណារី ទំនងជាជនរងគ្រោះនៃអំពើអាស្រូវដែលឪពុកនិងប្តីរបស់ខ្លួនបន្សល់ទុកឲ្យ ។ មេដឹកនាំខ្មែរក្រហមដទៃទៀតដែលនៅរស់មិនមែនជាជនរងគ្រោះទេ ។ មិនមែនជាជនរងគ្រោះដោយសារប្រជាជន ហើយក៏មិនមែនជនរងគ្រោះដោយវិកលភាពនោះដែរ ។ ប្រសិនបើមេដឹកនាំខ្មែរក្រហមគេចផុតពីការទទួលខុសត្រូវដោយសារមរណភាពរបស់ខ្លួននោះ ទំនងជាថាជាតិខ្មែរនឹងទទួលរងនូវការបោកប្រាស់ ព្រមទាំងមិនអស់ចិត្តចំពោះអ្វីដែលខ្លួនចង់បានយ៉ាងទទូចនោះ ។

**ចូអាណា រ៉េបេកា ម៉ាន់សុន**

# មាគ៌ាឆ្ពោះទៅរកការផ្សះផ្សាជាតិនៅកម្ពុជា

### *សេចក្តីផ្តើម*

នៅឆ្នាំ២០០០ ខ្ញុំបានចូលបម្រើការជាបុគ្គលិកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានគោលដៅចម្បងពីរគឺ «ការចងចាំ» និង «យុត្តិធម៌» ។ គោលដៅទាំងពីរនេះជួយដល់ការស្ថាបនាសន្តិភាពនិងការផ្សះផ្សាជាតិនៅកម្ពុជា ។ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំមានឱកាសស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ(ត្រូវបានស្គាល់ជាទូទៅថារបបខ្មែរក្រហម) ដែលកាន់អំណាចនៅប្រទេសកម្ពុជារវាងឆ្នាំ១៩៧៥-៧៩ ហើយបានបណ្តាលឲ្យប្រជាជនស្លូតត្រង់ប្រមាណពីរលាននាក់ស្លាប់បាត់បង់ជីវិតដោយសារការអត់ឃ្លាន ការបង្ខិតបង្ខំឲ្យធ្វើពលកម្មហួសកម្លាំង ជំងឺ និងការកាប់សម្លាប់ ។ នៅខែមិថុនា ឆ្នាំ២០០៣ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅរបស់ខ្ញុំមួយក្បាលដែលមានចំណងជើងថា *«កងទ័ពខ្មែរក្រហមលេខ៧០៣: ពីជ័យជម្នះឆ្ពោះទៅការបំផ្លាញខ្លួនឯង»* ។

សៀវភៅដែលចេញរូបរាងមកនេះ គឺបានមកអំពីការស្រាវជ្រាវឯកសារដែលបន្សល់ទុកមកពីរបបខ្មែរក្រហម បទសម្ភាសន៍អតីតជនរងគ្រោះនិងជនដៃដល់នៃរបបខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតអតីតជនរងគ្រោះ និងជនដៃដល់ទាំងនោះ ។

យុទ្ធជនទាំងនោះជាមនុស្សសាមញ្ញដូចមនុស្សរាល់គ្នាអីចឹងដែរ ពោលគឺជាមនុស្សដែលត្រូវបានដឹកនាំទៅរកផ្លូវខុសដោយមេដឹកនាំខ្មែរក្រហមឆ្កួតលីលាមួយចំនួនតូច ។ ជនដែលត្រូវបានបោកប្រាស់នាំទៅរកផ្លូវខុស យើងមិនត្រូវស្អប់ខ្ពើមនិងភ័យខ្លាចនោះទេ ។ អ្វីដែលអ្នកទាំងនោះត្រូវការគឺ ការអប់រំ (មិនមែនជាការស្តីបន្ទោសឬដាក់កំហុស) ដោយនាំឲ្យចូលមករួមរស់នៅក្នុងសង្គមជាតិវិញ ។ ការឆ្លុះបញ្ចាំងនូវការពិតដូចដែលស្តែងនៅក្នុងសៀវភៅនេះនឹងជួយអ្នកអានកុំឲ្យមានអារម្មណ៍ថាសេចក្តីស្អប់គឺជាចម្លើយទៅនឹងរឿងរ៉ាវដ៏គួរឲ្យរន្ធត់នៃរបបខ្មែរក្រហម ។ ការពិតនឹងធ្វើឲ្យមានអារម្មណ៍ធូរស្បើយ លែងខ្វល់ខ្វាយនិងនាំឲ្យមានការរួបរួមផ្សះផ្សាជាមួយអ្នកផ្សេងទៀត ។

នៅអំឡុងពេលនៃការសរសេរសៀវភៅនេះ ជារឿយៗខ្ញុំបានទៅវិទ្យាល័យនិងមហាវិទ្យាល័យមួយចំនួននៅទីក្រុងភ្នំពេញដើម្បីនិយាយទៅកាន់សិស្សនិងនិស្សិតអំពីប្រវត្តិសាស្ត្រកម្ពុជានៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំបានចាប់អារម្មណ៍ចំពោះសិស្សនិងនិស្សិតជាច្រើននាក់ដែលសួរមកកាន់ខ្ញុំថា «តើហេតុដូចម្តេចបានជាប្រជាជនខ្មែរដែលមានចរិតស្លូតបូត សុភាពរាបសា បែរជាសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃយ៉ាងដូច្នេះទៅវិញ?» ។ នេះគឺជាសំណួរដែលខ្ញុំពិបាកផ្តល់ចម្លើយ ។ ភ្ជាប់ជាមួយនឹងសំណួរនេះ ខ្ញុំបានបញ្ជាក់ថា ប្រហែលមានតែមេដឹកនាំខ្មែរក្រហមប៉ុណ្ណោះដែលអាចផ្តល់នូវចម្លើយគួរឲ្យជឿជាក់បានចំពោះអំពើប្រល័យពូជសាសន៍នេះ ។

ចម្ងល់បែបនេះ ក៏បានកើតមានឡើងដូចគ្នាចំពោះជនរងគ្រោះនិងជនដៃដល់ថ្នាក់ក្រោមនៃរបបខ្មែរក្រហម ដែលខ្ញុំបានជួបសម្ភាសដែរ ។ អតីតអ្នកទោសមន្ទីរស-២១(គុកទួលស្លែង)ចំនួនពីរនាក់ដែលនៅរស់រានមានជីវិតរហូតមកទល់សព្វថ្ងៃបាននិយាយថាគាត់មិនដឹង និងមិនយល់ទាល់តែសោះរហូតមកទល់សព្វថ្ងៃនេះថាហេតុអ្វីបានជាខ្មែរក្រហមចាប់ខ្លួនគាត់ ។ នៅពេលវេលានិងទីកន្លែងខុសគ្នា ខ្ញុំបានសួរសំណួរមួយទៅកាន់អតីតយុទ្ធជនមន្ទីរស-២១ចំនួន៩នាក់ថា «តើហេតុអ្វី បានជាអ្នកទោសខ្មែរក្រហមទាំងនោះត្រូវតែយកទៅសម្លាប់ចោល?» ។ ចម្លើយជារួមរបស់អ្នកទោសទាំងនោះគឺ «អង្គការប្រាប់ថា មនុស្សដែលអង្គការចាប់យកមកទីនោះ (ស-២១) គឺជាខ្មាំង ។ យើងត្រូវតែធ្វើការតាមតួនាទីរបស់ខ្លួន ។ យើងមិនត្រូវដឹងអំពីកិច្ចការរបស់អ្នកដទៃ ។ បើយើងមិនធ្វើតាមអង្គការ យើងនឹងត្រូវស្លាប់ បងប្អូននិងឪពុក

ម្តាយយើងក៏ត្រូវស្លាប់ដូចយើងដែរ ។»

សំណួរនិងភាពស្រពេចស្រពិលអំពីប្រវត្តិសាស្ត្របែបនេះ បានបង្កើតឲ្យមាននូវភាពមិនស្ងប់អារម្មណ៍ ការចោទប្រកាន់ ការចងអាឃាដគ្នា ភាពវិលវល់នឹងអតីតកាលដែលជាមរតកនៃរបបខ្មែរក្រហម ។ ស្ថានភាពកម្ពុជាបច្ចុប្បន្នត្រូវតែមានដំណោះស្រាយនិងបញ្ចប់នូវបញ្ហាខាងលើនេះ ។ សន្តិភាពនិងការផ្សះផ្សាជាតិនឹងនាំឲ្យមានលទ្ធិប្រជាធិបតេយ្យនិងការអភិវឌ្ឍន៍ ។ ប្រសិនបើគ្មានយុត្តិធម៌ពិតប្រាកដ ក៏គ្មានសន្តិភាពដែរ ។

វិធាននានាចំពោះដំណើរការផ្សះផ្សាជាតិនេះ ខ្ញុំនឹងបង្ហាញតាមរយៈបទពិសោធន៍ដែលខ្ញុំធ្លាប់បានបម្រើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ វាមិនមែនជាការងាយស្រួល និងអាចកើតឡើងតែមួយពព្រិចភ្នែកនោះទេ ហើយក៏មិនមានវិធីដែលអាចផ្លាស់ប្តូរទស្សនៈរបស់ប្រជាជនខ្មែរ ចំពោះការគិតអំពីខ្លួនឯងនិងអ្នកដទៃភ្លាមៗនោះដែរ ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាយល់ឃើញថា «ការផ្តល់ឱកាសឲ្យអតីតជនរងគ្រោះនិងជនដៃដល់និយាយ និងស្តាប់ពាក្យការពិតទាំងសងខាងនឹងនាំឲ្យមានការរសាយចិត្ត ។ ប្រសិនបើមិនបានស្តាប់ពាក្យទាំងសងខាងតើនឹងអាចដឹងការពិតយ៉ាងដូចម្តេច? តើយើងនឹងត្រូវអត់ឱននិងផ្សះផ្សាគ្នាយ៉ាងដូចម្តេច?» ។

ដើម្បីជាមធ្យោបាយនិងដំណោះស្រាយចំពោះការផ្សះផ្សាជាតិនៅកម្ពុជា ជាដំបូងខ្ញុំនឹងបង្ហាញដោយសង្ខេបអំពីភាពមិនចុះសម្រុងគ្នារវាងអតីតជនរងគ្រោះនិងជនដៃដល់ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ ។ រឿងរ៉ាវពិស្តារអំពីជីវិតរបស់អ្នកទាំងនោះ ខ្ញុំបានកត់ត្រានៅក្នុងសៀវភៅរបស់ខ្ញុំក្នុងទំព័រ១៨៦ ។ នៅផ្នែកទីមួយខ្ញុំនឹងបង្ហាញអំពីវិធានមួយចំនួនដែលខ្ញុំបានធ្វើជាមួយអតីតជនរងគ្រោះនិងជនដៃដល់នៃរបបខ្មែរក្រហមមួយក្រុម ។ នៅផ្នែកទីពីរ ខ្ញុំនឹងបង្ហាញអំពីកម្មវិធីនានាដោយសង្ខេប (ពត៌មានពិស្តារសូមមើល www.dccam.org) ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើជុំវិញដំណើរការសន្តិភាពនិងការផ្សះផ្សាជាតិនៅកម្ពុជា ទាំងនៅមុននិងក្រោយពេលដែលមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ជាមួយគ្នានេះខ្ញុំនឹងបង្ហាញនូវតួនាទីតុលាការចម្រុះរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិដែលនឹងកើតឡើងនាពេលខាងមុខចំពោះការថែរក្សាសន្តិភាពនិងការផ្សះផ្សាជាតិពិតប្រាកដនៅកម្ពុជា ។ ខ្ញុំទាញសន្និដ្ឋានដោយពិភាក្សាទៅលើការទាមទារយុត្តិធម៌ សន្តិភាព ការផ្សះផ្សាជាតិរបស់ជនរងគ្រោះក្រោមអំពើទារុណកម្មនៃរបបខ្មែរក្រហម វឌ្ឍនភាពប្រជាធិបតេយ្យនិងសេដ្ឋកិច្ចប្រទេសកម្ពុជា ។

## បទពិសោធន៍នៅតាមមូលដ្ឋាន

ឱកាសបានដឹងអំពី «ការពិត» ដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាដែលស្ថិតក្រោមការគ្រប់គ្រងនៃរបបខ្មែរក្រហមពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ គឺមានសារសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជនកម្ពុជាក៏ដូចជាពិភពលោកទាំងមូល ។ ចាប់តាំងពីរបបខ្មែរក្រហមដួលរលំអស់រយៈពេលជាងពីរទសវត្សរ៍ទៅ ហើយដែលសំណួរមិនទាន់មានចម្លើយជាច្រើនបានបន្សល់ទុកដូចជាៈ តើហេតុអ្វីបានជារបបខ្មែរក្រហមកើតឡើង? វាកើតឡើងយ៉ាងដូចម្តេច? អ្វីខ្លះបានកើតឡើង? ហេតុអ្វីបានជាប្រជាជនខ្មែររាប់លាននាក់ស្លាប់បាត់បង់ជីវិត? ជាមួយនឹងសំណួរទាំងអស់នេះ អតីតមេដឹកនាំខ្មែរក្រហមមានឱកាសបង្វែងដានការពិតនិងលាក់លៀមនូវអំពើជាច្រើនដែលខ្លួនបានប្រព្រឹត្តនៅក្នុងរយៈពេលនៃការកាន់អំណាច ។ ការដែលមេដឹកនាំខ្មែរក្រហមមានឱកាសនិយាយបែបនេះបានធ្វើឲ្យជនរងគ្រោះនិងកម្មាភិបាលថ្នាក់ក្រោមកាន់តែវិលវល់នឹងស្រមោលអតីតកាលដែលជិតជាមមកពីការដឹកនាំក៏ឆ្គួតលីលា ។

ពីធម្មជាតិ ប្រជាជនខ្មែរមានចរិតស្លូតបូត ទៀងត្រង់រួសរាយរាក់ទាក់ញញឹមញញែមជានិច្ចដែលខ្មែរនិយមហៅថា «ញញឹមអប្សរា» ឬ «ញញឹមបាយ័ន» ។ ដោយសារមានភាពជិតស្និទ្ធនឹងវត្តអារាមព្រះពុទ្ធសាសនាថែមទៀតនោះ កម្រមានអ្នកណាហ៊ានបំពារបំពានលើជីវិតមនុស្ស និងសូម្បីតែជីវិតសត្វក៏ដោយ ។ មិនតែប៉ុណ្ណោះចាស់ព្រឹទ្ធាចារ្យខ្មែរបានប្រៀនប្រដៅកូនចៅឲ្យយល់ឃើញថា អ្នកដែលរកស៊ីចិញ្ចឹមជីវិតដោយការសម្លាប់សត្វដូចជា គោ ជ្រូក មាន់ ទា យកសាច់ ទៅលក់ គឺជាមុខរបរដែលមិនចម្រុងចម្រើនឡើយ ។ ទ្រព្យសម្បត្តិទាំងឡាយ

ដែលបានមកពីរបបនេះ គឺជាទ្រព្យក្តៅក្រហាយ ។ ក៏ប៉ុន្តែចាប់តាំងពីមានបដិវត្តន៍ខ្មែរក្រហម ស្ថានភាពដែលគួរឲ្យកត់សម្គាល់ គឺចរិតខ្មែរមួយចំនួនបានផ្លាស់ប្តូរយ៉ាងច្រើន ។ ទោះបីយ៉ាងណាក៏ដោយអនាគតកម្ពុជាត្រូវតែរំដោះឲ្យរួចពីមរតកបែបនេះ ។

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ អតីតកម្មាភិបាល ខ្មែរក្រហមមួយចំនួនជាពិសេសកងសន្តិសុខត្រូវប្រជាជនចាប់យកទៅសម្លាប់ដើម្បីសងនូវការឈឺចាប់ដែលខ្លួនទទួលរងនៅក្នុងរបបខ្មែរក្រហម ។ កងសន្តិសុខមួយចំនួនត្រូវប្រជាជនសម្លាប់ដោយវាយនឹងព្រនង់ កាប់នឹងកាំបិតពូថៅ ដុតទាំងរស់ បាញ់សម្លាប់ចោល ចងទម្លាក់ទឹក...។ ប្រជាជនខ្មែរជាច្រើននាក់បាននិយាយពីអំពើឃោរឃៅនៅក្នុងរបបខ្មែរក្រហម ។ ថ្មីៗបន្ទាប់ពីរួចផុតពីការសម្លាប់រង្គាលសាច់ញាតិដែលបានមកជួបជុំគ្នាតែងតែនិយាយអំពីការលំបាកវេទនានៅក្នុងរបបខ្មែរក្រហមនៅមុនពេលបន្តការសន្ទនារឿងរ៉ាវផ្សេងៗទៀត ។

ចាប់តាំងពីឆ្នាំ២០០០ ខ្ញុំបានជួបសម្ភាសជាមួយអតីតកងទ័ពខ្មែរក្រហមចំនួន៤០នាក់ដែលធ្លាប់ការពារនៅព្រំដែនកម្ពុជា-វៀតណាម ។ មនុស្សភាគតិចបំផុតដែលនិយាយមកកាន់ខ្ញុំដោយមិនមានការភិតភ័យ ផ្ទុយទៅវិញមនុស្សភាគច្រើនក្នុងចំណោមនោះនិយាយដោយលាក់លៀម ។ ទោះបីជាអ្នកទាំងនោះមិនបានធ្វើការនៅកន្លែងសម្លាប់មនុស្សក៏ដោយ ក៏ប៉ុន្តែអតីតកាលដែលធ្លាប់បម្រើឲ្យខ្មែរក្រហម ប្រហែលជាអ្នកទាំងនោះយល់ថាមិនគួរបើនិយាយឬមួយនិយាយទៅនឹងអាចមានបញ្ហាដល់គ្រួសាររបស់ខ្លួន ។ ជួនកាលអ្នកទាំងនោះមិនហ៊ានឆ្លើយសូម្បីតែសំណួរសាមញ្ញដូចជា «អ្នករស់នៅកន្លែងណា ឬធ្វើការនៅកន្លែងណានៅក្នុងរបបខ្មែរក្រហម?» ។ ម្តងម្កាល សំណួរបែបនេះត្រូវបានឆ្លើយកាត់ដោយប្រពន្ធឬប្តីរបស់អតីតកងទ័ពខ្មែរក្រហមទាំងនោះទៅវិញ ។ ប៉ុន្តែបន្ទាប់ពីការជជែកពីនេះពីនោះដែលនាំឲ្យអ្នកទាំងនោះយល់អំពីគោលបំណងនៃបទសម្ភាសន៍ខ្ញុំអាចទទួលបានព័ត៌មានមួយផ្នែក ។

ផន (មិនមែនជាឈ្មោះពិតប្រាកដ) ត្រូវជាប្រពន្ធរបស់ប្រធានសន្តិសុខឃុំម្នាក់ដែលសព្វថ្ងៃរស់នៅក្នុងខេត្តតាកែវបាននិយាយថាៈ «ភ្លាមៗបន្ទាប់ពីរបបខ្មែរក្រហមដួលរលំប្តីខ្ញុំត្រូវប្រជាជនដែលមានសាច់ញាតិស្លាប់នៅក្នុងរបបខ្មែរក្រហមចាប់យកទៅចងវាយធ្វើបាបនិងដុតទាំងរស់នៅលើទួលកប់ខ្មោចមួយស្ថិតនៅខាងកើតភូមិ ។ ខ្ញុំមានការខ្លោចចិត្តយ៉ាងខ្លាំង ។ ប្តីខ្ញុំបានអង្វរករអ្នកស្រុកដែរ ប៉ុន្តែឥតប្រយោជន៍» ។

សព្វថ្ងៃនេះ ផន រស់នៅជាមួយកូនស្រីពីរនាក់ ។ ឆ្លើយនឹងសំណួរដែលថា «យល់ដូចម្តេចចំពោះការស្លាប់របស់ប្តីមីង?» ។ ផន បានឆ្លើយថា «ខ្ញុំមិនដឹងថាយ៉ាងម៉េចទេ ។ នេះគឺជាកម្មផលរបស់គាត់» ។ ប្រជាជនដែលធ្លាប់រស់នៅជាមួយគ្រួសារ ផន នៅក្នុងរបបខ្មែរក្រហមបាននិយាយថា ប្តីរបស់ ផន ជាមនុស្សឃោរឃៅបំផុត ។ អ្នកណាក៏ខ្លាចប្តីរបស់ ផន ដែរ ។ គាត់សម្លាប់មនុស្ស ហើយស៊ីថ្លើមមនុស្សទៀត ។


ទុយ គិន

នៅឆ្នាំ១៩៨៤ ទុយ គិន ត្រូវបានអជ្ញាធរខេត្តកណ្តាលចាប់ឃុំខ្លួនអស់រយៈពេល១៨ខែ ដោយចោទប្រកាន់ពីបទធ្លាប់បម្រើរបបខ្មែរក្រហម និងថាបានសម្លាប់មនុស្សចំនួន៣០០នាក់នៅមន្ទីរសន្តិសុខស-២១ (គុកទួលស្លែង) ។ មូលហេតុដែលនាំទៅដល់ការចោទប្រកាន់បែបនេះដោយសារតែមានរូបថតពាក់កណ្តាលខ្លួនរបស់ គិន មួយសន្លឹកដែលថតនៅក្នុងសម័យខ្មែរ-ក្រហមមានដាក់តាំងនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ តាមរយៈប្រវត្តិរូបនិងសាក្សីមួយចំនួនដែលធ្លាប់ស្គាល់ គិន បាននិយាយថា គិន បានធ្វើការនៅមន្ទីរស-២៤ ដែលជាកន្លែងលត់ដំអ្នកទោសនិងជាសាខារបស់មន្ទីរស-២១ ។ ទោះបីយ៉ាងណាក៏ដោយ គិន បាននិយាយថា «ខ្ញុំសុំស្បថ ខ្ញុំមិនដែលបានសម្លាប់អ្នកណាម្នាក់ឡើយ ។ ប្រសិនបើយ៉ាងដូច្នេះមែន សូមទេព្តាបរាមុខខ្ញុំទៅចុះ» ។ ទោះជាគាត់ត្រូវបានដោះលែងឲ្យមានសេរីភាពវិញក៏ដោយ ក៏គាត់កំពុងនៅដោយមានការសង្ស័យ និងការគុំគួនពីអ្នកស្រុកនៅឡើយ ។

ញ៉ៀប ហូ អតីតយុទ្ធជនកងការពារអ្នកទោសនៅមន្ទីរ


ញ៉ៀប ហូ

ស-២១ បាននិយាយថា "អ្នកស្រុកបានហៅខ្ញុំថាមេខ្មែរក្រហម ។ ខ្ញុំមិនខឹងនឹងគេទេ ព្រោះខ្ញុំធ្លាប់ធ្វើពីមុនមកមែន ។ អ្នកស្រុកភាគច្រើនបានដឹងថា ខ្ញុំធ្លាប់ធ្វើការនៅគុកទួលស្លែង ។ ខ្ញុំមិនតូចចិត្តទេ ប៉ុន្តែខ្ញុំអាណិតប្រពន្ធ និងកូនរបស់ខ្ញុំ" ។


ជុំ ម៉ាញ

រៀងរាល់រដូវបុណ្យភ្ជុំ ជុំ ម៉ាញ បានយកម្ហូបអាហារទៅប្រគេនព្រះសង្ឃដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធប្រពន្ធនិងកូនរបស់គាត់ដែលខ្មែរក្រហមបានបាញ់សម្លាប់នៅនឹងមុខគាត់ ខណៈពេលដែលខ្មែរក្រហមកៀរអ្នកទោសនៅមន្ទីរស-២១ និងប្រជាជនឆ្ពោះទៅព្រំដែនកម្ពុជា-ថៃ នៅឆ្នាំ១៩៧៩ ។ ជុំ ម៉ាញ នៅនឹកឃើញរឿងរ៉ាវទាំងអស់នៅក្នុងរបបខ្មែរក្រហម ។ ជាងនេះទៅទៀតបន្ទាប់ពីឮថា រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបង្កើតសាលាក្តីដើម្បីវិនិច្ឆ័យក្តីមេដឹកនាំខ្មែរក្រហម កាន់តែធ្វើឲ្យគាត់សម្រានមិនសូវលក់និងម្តងម្កាលយល់សប្តិឃើញអំពីជីវិតគាត់នៅក្នុងរបបខ្មែរក្រហម ។


ប៊ូ ម៉េង

ប៊ូ ម៉េង បានត្រឡប់ទៅរស់នៅស្រុកកំណើតវិញ បន្ទាប់ពីមានសំណាងរួចផុតពីការសម្លាប់រង្គាលនៅមន្ទីរស-២១ ។ ម៉េង បានរស់នៅក្នុងឃុំជាមួយគ្នានឹង ហ៊ឹម ហ៊ុយ អតីតអនុប្រធានកងការពារអ្នកទោសនៅមន្ទីរស-២១ និងធ្លាប់ដឹកអ្នកទោសយកទៅកន្លែងសម្លាប់នៅជើងឯក ។ ហ៊ុយ និយាយថា ឌុច ប្រធានមន្ទីរស-២១ និងហ៊ី អនុប្រធានមន្ទីរនេះធ្លាប់បញ្ជាគាត់ឲ្យសម្លាប់អ្នកទោសនៅជើងឯកចំនួន៥នាក់ ដោយវាយនឹងដែកភ្ជួរទេះ ។ ម៉េង សួប់ ហ៊ុយ យ៉ាងខ្លាំងរហូតដល់ចង់សម្លាប់ ហ៊ុយ ដើម្បីសងនូវការឈឺចាប់ដែល ហ៊ុយ និងបក្ខពួកធ្លាប់បានធ្វើមកលើរូបគាត់កាលនៅមន្ទីរស-២១ ។

## ឆ្ពោះទៅរកការផ្សះផ្សាជាតិនៅកម្ពុជា

អ្នកសិក្សាជាន់ខ្ពស់ជាច្រើននាក់បានព្យាយាមឲ្យនិយមន័យស្រដៀងៗគ្នា ចំពោះពាក្យ "ការផ្សះផ្សា" ។ សាស្ត្រាចារ្យ អែនឌ្រូ រីកបាយ បានពន្យល់ថា "ការផ្សះផ្សាគឺសំដៅទៅលើអនាគត ហើយតម្រូវឲ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់អ្នកដែលបានបែកបាក់នឹងគ្នាតាមរយៈភាពអមិត្ត ។ ចំណុចសំខាន់នៃដំណើរការផ្សះផ្សា គឺការរៀបចំខ្លួនជាស្រេចរបស់មនុស្សក្នុងការប្រមើមើលទៅអនាគតមួយរួមគ្នា ។ ដើម្បីឲ្យមានអនាគតមួយរួមគ្នា មនុស្សទាំងនោះមិនត្រូវបំភ្លេច ប៉ុន្តែត្រូវបេះអត់ឱនចំពោះអតីតកាល ។ ដូច្នេះត្រូវស្ថិតនៅក្នុងដំហរមួយចង់ធ្វើដំណើរទៅមុខរួមគ្នា" ។ ហ៊ីស្សគីអាស អាសេហ្វា អធិប្បាយថា "ទ្រឹស្តីនៃការផ្សះផ្សាមិនមែនត្រឹមតែព្យាយាមរកដំណោះស្រាយចំពោះបញ្ហានានា ដែលជាដើមហេតុនៃជម្លោះប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើការដើម្បីផ្លាស់ប្តូរទំនាក់ទំនងរបស់ភាគីជម្លោះពីការមិនពេញចិត្តនិងប្រទូស្តរ៉ាយមកជាមិត្តភាព និងសុខដុមរមនា ។ ពិតណាស់ដើម្បីឲ្យគុណសម្បត្តិនេះកើតឡើង ភាគីទាំងសងខាងត្រូវចំណាយពេលនិងចូលរួមស្មើៗគ្នាយ៉ាងអស់ពីចិត្តនៅក្នុងដំណើរការឈានទៅរកដំណោះស្រាយ ។ សម្រាប់បញ្ហាការផ្សះផ្សាជាតិនៅកម្ពុជា លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បញ្ជាក់ថា "ដើម្បីឲ្យមានការផ្សះផ្សាជាតិត្រូវតែប្រឈមមុខនឹងការពិតនិងរកយុត្តិធម៌" ។ លោក ឆាំង យុ បានបន្ថែមថា "ការពិត" នឹងនាំឲ្យមនុស្សរសាយចិត្ត ឬរសាយគំនុំ ហើយ"យុត្តិធម៌" គឺមិនមែនជាការសងសឹកទេ ។

អតីតយុទ្ធជនខ្មែរក្រហមជាច្រើនដែលខ្ញុំបានជួបសម្ភាសតែងតែយល់ថា ខ្លួនគឺជាជនរងគ្រោះនៃប្រវត្តិសាស្ត្រ ប៉ុន្តែនៅក្នុងក្រសែភ្នែកប្រជាជនដែលជាជនរងគ្រោះជាច្រើននាក់បានយល់ថាអ្នកទាំងនោះគឺជាជនដៃដល់ ។ ទាំងនេះគឺបញ្ហាស្មុគស្មាញដែលប្រជាជនខ្មែរកំពុងប្រឈមមុខ បន្ទាប់ពីការផុតរលត់ទៅនៃ

របបខ្មែរក្រហម ។ នេះប្រសិនបើមិនបានស្តាប់ពាក្យសម្តីទាំងសងខាង តើយើងនឹងអាចបានដឹងអំពីការពិតយ៉ាងដូចម្តេច? តើធ្វើដូចម្តេចទៅទើបអាចរកយុត្តិធម៌ឲ្យជនរងគ្រោះក្រោមអំពើទារុណកម្មនិងសមាជិកគ្រួសាររបស់គេ? តើធ្វើដូចម្តេចដើម្បីអាចចៀសវាងបាននូវការសងសឹកគ្នាទៅវិញទៅមក? ប្រទេសកម្ពុជានឹងមិនអាចអភិវឌ្ឍទៅមុខជាមួយនឹងអតីតកាលបែបនេះបានឡើយ ។

### ការពិតនិងការរសាយចិត្ត

ដោយកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នានឹងនាំឲ្យមានការផ្សះផ្សាជាតិនៅកម្ពុជាពិតប្រាកដ ។ បទពិសោធន៍របស់ខ្ញុំក្នុងការនាំឲ្យមានការរសាយចិត្តដល់អតីតជនរងគ្រោះ និងជនដៃដល់មួយក្រុមនោះគឺផ្តល់ឱកាសឲ្យទាំងសងខាងនិយាយ“ការពិត” ។ ជាច្រើនឆ្នាំមកហើយដែលអ្នកទាំងនោះរស់នៅដោយជិតដាមនិងវិលវល់ជាមួយនឹងអតីតកាលនៃរបបខ្មែរក្រហម ។ ការបង្ហាញនូវការពិតតាមរបៀបនេះបន្តិចម្តងៗ ទាំងសងខាងកាន់តែយល់ច្បាស់អំពីមូលហេតុដែលនាំឲ្យមានការមិនចុះសម្រុងនឹងគ្នាកន្លងមក ហើយអាចទទួលស្គាល់ការពិតដោយស្ងៀមស្ងាត់នៅក្នុងចិត្ត ។ នៅទីបញ្ចប់ប្រទេសកម្ពុជាទាំងមូលអាចសម្រេចបាននូវ“ការផ្សះផ្សាជាតិ” ។


ម៉ែន ឡាយ

ម៉ែន ឡាយ ភេទស្រី អាយុ៦៨ឆ្នាំ (សព្វថ្ងៃរស់នៅខេត្តកណ្តាល) បានបាត់កូនប្រុសរបស់គាត់ជិត៣០ឆ្នាំទៅហើយ ចាប់តាំងពីចូលបម្រើបដិវត្តន៍នៅឆ្នាំ១៩៧០ ។ គាត់មិនប្រាកដក្នុងចិត្តថា កូនប្រុសរបស់គាត់ស្លាប់ឬនៅរស់នៅឡើយទេ ។ នៅឆ្នាំ២០០១ ខ្ញុំបានទៅផ្ទះគាត់ជាមួយនឹងចម្លើយសារភាពរបស់មិន កាន ដែលជាកូនប្រុសរបស់គាត់ ។ ចាប់តាំងពីពេលនោះមក ឡាយ បានដឹងច្បាស់ថា កូនប្រុសរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់នៅមន្ទីរស-២១ ។ ឡាយ មានប្រសាសន៍ថា គាត់ឈប់រកគ្រូទាយអំពីជោគវាសនាកូនប្រុសរបស់គាត់ទៀតហើយ ហើយនឹងធ្វើបុណ្យឧទ្ទិសកុសលដល់កូនប្រុសរបស់គាត់ ។ អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបករណីស្រដៀងគ្នានេះជាច្រើន ។ នេះគឺជាអ្វីដែលយើងតែងតែនិយាយថា “ការពិតអាចធ្វើឲ្យអ្នកមានអារម្មណ៍ធូរស្បើយលែងខ្វាយខ្វល់” ។

នៅក្នុងឆ្នាំ១៩៨៤ ទុយ គិន ត្រូវបានអាជ្ញាធរខេត្តកណ្តាលឃុំឃាំងអស់រយៈពេល១៨ខែ ដោយចោទប្រកាន់ពីបទធ្លាប់បម្រើការកងទ័ពខ្មែរក្រហម ។ ទោះបីជា គិន ត្រូវបានដោះលែងឲ្យមានសេរីភាពវិញក៏ដោយ ក៏គាត់ត្រូវចំណាយពេលវេលាជាច្រើនឆ្នាំ រស់នៅក្នុងភាពមន្ទិលសង្ស័យពីសំណាក់ញាតិជិតខាង ចំពោះអតីតភាពដែលជិតដាមពីរបបខ្មែរក្រហម ។ គិន បានដឹងថា អ្នកភូមិមួយចំនួនស្អប់គាត់ ហើយហៅគាត់ថាជា “ពួកខ្មែរក្រហម” ។ គិន និយាយថា “ខ្ញុំមិនខឹងនឹងគេទេ ។ នេះដោយសារតែខ្ញុំធ្លាប់ធ្វើកងទ័ពនារីឲ្យ ប៉ុល ពត ប៉ុន្តែខ្ញុំមិនដែលសម្លាប់មនុស្សទេ” ។ គ្រូពេទ្យឃុំម្នាក់ដែលធ្លាប់បានព្យាបាលជំងឺឲ្យ គិន បាននិយាយថា ពីមុនគាត់ស្អប់ គិន ខ្លាំងណាស់ ។ គាត់ចង់សម្លាប់ គិន ទៀតផង ពីព្រោះ គិន ជាកម្មាភិបាលខ្មែរក្រហម ។ គ្រូពេទ្យរូបនេះបាននិយាយទៀតថា អ្នកភូមិមួយចំនួនក៏ធ្លាប់គិតដូចគាត់ដែរចំពោះអតីតកាលរបស់ គិន ។ បន្ទាប់ពីការព្យាបាលជំងឺរបស់ គិន កន្លងមកនិងការស្វែងយល់កាន់តែច្រើនអំពីរឿងរ៉ាវនេះ គ្រូពេទ្យរូបនោះបានប្រែប្រួលចិត្តយ៉ាងច្រើនចំពោះ គិន ។ គាត់បាននិយាយថា ឥឡូវនេះគាត់លែងស្អប់ គិន ទៀតហើយ ។ ការព្យាបាលពេលខ្លះគាត់មិនបានយកប្រាក់ពី គិន ឡើយ ។ គាត់បញ្ជាក់ថា គិន គ្រាន់តែជាឧបករណ៍របស់ខ្មែរក្រហមប៉ុណ្ណោះ ។

ឧទាហរណ៍ចុងក្រោយមួយទៀតគឺការផ្លាស់ប្តូរអារម្មណ៍របស់អតីតអ្នកទោសនៅមន្ទីរស-២១ម្នាក់ បន្ទាប់ពីបានគូរគំនូរអំពីរបបខ្មែរក្រហមជាច្រើនផ្ទាំង ។ ប៊ូ ម៉េង បានបំពេញភារកិច្ចជាអ្នកស្ម័គ្រចិត្តដោយគូររូបភាពក្រោមប្រធានបទ “ការផ្សះផ្សាជាតិ” ដើម្បីបង្ហាញដល់មនុស្សជំនាន់ក្រោយអំពីរបបខ្មែរក្រហម ។ នៅមុនពេលគូរគំនូរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ប៊ូ ម៉េង មានកំហឹងយ៉ាងខ្លាំងចំពោះ ហ៊ឹម ហ៊ុយ ដែលធ្លាប់បានធ្វើទារុណកម្មមកលើរូបគាត់ និងអ្នកទោសដទៃទៀតនៅទីនោះ ។ ប៉ុន្តែថ្មីៗនេះ ឆ្លើយនឹងសំណួរដែលថា “យល់យ៉ាងដូចម្តេចចំពោះយុទ្ធជនខ្មែរក្រហម ជាពិសេស ហ៊ឹម ហ៊ុយ?” ។ ប៊ូ ម៉េង បានឆ្លើយថា

គាត់មិនចង់ឲ្យមានការសងសឹកគ្នាទៅវិញទៅមកមិនចេះចប់មិនចេះហើយនោះទេ ។ គេនឹងទទួលផលវិញតាមអំពើដែលគេធ្វើ ។ គេត្រូវតែប្រឈមមុខចំពោះមុខច្បាប់ ។

នៅខែឧសភា ឆ្នាំ២០០២ អតីតយុទ្ធជននៃមន្ទីរស-២១ ឬគុកទួលស្លែងចំនួនប្រាំមួយនាក់បានជួបជុំគ្នាឡើងវិញ នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងតាមការស្នើសុំរបស់លោក ប៉ាន់ ឬទ្ធី ដើម្បីថតខ្សែភាពយន្តឯកសារ ។ អ្នកទាំងនេះមិនបានស្លៀកសម្លៀកបំពាក់ខ្មៅ និងពាក់មួកកន្ទបដូចកាលពីសម័យបដិវត្តន៍ខ្មែរក្រហមនោះទេ ។ អ្នកទាំងនេះបានធ្វើដំណើរមួយៗចូលទៅក្នុងបរិវេណសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ កាលពី២៧ឆ្នាំមុន អ្នកទាំងនោះបានចូលមកគុកទួលស្លែងក្នុងតួនាទីជាអ្នកចាប់អ្នកទោស អ្នកសួរចម្លើយអ្នកទោស អ្នកការពារអ្នកទោស អ្នកធ្វើបញ្ជីឈ្មោះអ្នកទោស និងអ្នកប្រហារជីវិតអ្នកទោស ។ អ្នកទាំងនេះបានប្រាប់ថា ការងារទាំងនោះធ្វើដើម្បីជាថ្នូរនឹងការរស់រានមានជីវិតតែប៉ុណ្ណោះ ។ គ្រប់គ្នាបានសម្លឹងមើលដោយសភាពរន្ធត់ចិត្តចំពោះកេរដំណែលរបបខ្មែរ-ក្រហមនៅក្នុងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ថ្វីដ្បិតតែធ្លាប់បានធ្វើការនៅទីនេះអស់រយៈពេលជិតបីឆ្នាំក៏ដោយ ។ ប្រាក់ ខន អតីតអ្នកសួរចម្លើយអ្នកទោសបាននិយាយថា នៅពេលដែលគាត់ចូលមកដល់សារមន្ទីរទួលស្លែង គាត់មានការរន្ធត់ចិត្តចំពោះរឿងរ៉ាវកាលពីមុន ពីព្រោះទីនេះជាកន្លែងសោកនាដកម្ម ។ គាត់មានការអៀនខ្មាសខ្លួនឯងដែលបានធ្វើទង្វើទាំងអស់នេះដែលជាអំពើឃោរឃៅ ប៉ុន្តែការភ័យខ្លាចនាពេលនេះមិនដល់ក្នុងសម័យខ្មែរក្រហមទេ ។ ខន និយាយថា "នៅទីនេះបើយើងមិនធ្វើតាមបញ្ជាគេទេ នោះយើងនឹងឆាប់ស្លាប់បំផុត" ។

ចាប់តាំងពីចូលមកធ្វើការនៅមន្ទីរស-២១ ជាម សឿ អតីតយុទ្ធជនកងការពារអ្នកទោសម្នាក់ទៀតបានបញ្ជាក់ថា ឌុច ប្រធានមន្ទីរនេះមិនដែលអនុញ្ញាតឲ្យគាត់ទៅលេងផ្ទះជួបជុំឪពុកម្តាយម្តងណាទេ ។ សឿ រំឭកថា "កាលពីមុនកន្លែងនេះគួរឲ្យខ្លាចបំផុត ។ ចាប់តាំងពីខ្ញុំចាកចេញពីកន្លែងនេះ ខ្ញុំមិនដែលនឹកគិតថា នឹងមកកន្លែងនេះទៀតទេ ។ គុកទួលស្លែងជាកន្លែងឃុំឃាំងនិងធ្វើទារុណកម្មអ្នកទោសយ៉ាងសាហាវព្រៃផ្សៃ ។ ឥឡូវនេះទួលស្លែងបានក្លាយទៅជាកន្លែងចងចាំសម្រាប់ប្រជាជនកម្ពុជា" ។ អតីតយុទ្ធជនមន្ទីរស-២១ទាំងប្រាំមួយនាក់បាននិយាយដូចៗគ្នាថា នៅក្នុងរបបខ្មែរក្រហមយើងគិតតែពីខំធ្វើការរៀងៗខ្លួន ។ យើងមិនអាចជួបជុំនិងនិយាយទៅកាន់គ្នាដូចពេលនេះទេ ។ ការជំនុំគ្នាគឺជាទោសឧក្រិដ្ឋ ។ នៅពេលដែលយើងបានជួបជុំគ្នារំឭកពីរឿងអតីតកាលឡើងវិញ ធ្វើឲ្យយើងមានអារម្មណ៍ធូរស្បើយ ។

## មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ការចងចាំនិងយុត្តិធម៌

មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបំពេញកិច្ចការ "ស្វែងរកការពិត" បានបង្កើតឡើងនៅខែមករា ឆ្នាំ១៩៩៥ ដែលកាលនោះគឺជាផ្នែកមួយនៃកម្មវិធីស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់សាកលវិទ្យាល័យយែលសហរដ្ឋអាមេរិក ។ នៅខែមករា ឆ្នាំ១៩៩៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានក្លាយជាស្ថាប័នឯករាជ្យកម្ពុជាដែលសិក្សាស្រាវជ្រាវនិងថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ ដោយសហការជាមួយអ្នកស្រាវជ្រាវជាន់ខ្ពស់អន្តរជាតិ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលដៅចម្បងពីរគឺ៖ ទី១) កត់ត្រា និងថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យសម្រាប់មនុស្សជំនាន់ក្រោយ និងទី២) ចងក្រង និងរៀបចំពត៌មានដែលមានតម្លៃសម្រាប់តុលាការខ្មែរក្រហមនាពេលខាងមុខ ។ គោលដៅចម្បងទាំងពីរនេះគឺដើម្បីជំរុញ "ការចងចាំ" និង"យុត្តិធម៌"ព្រមទាំងកសាងមូលដ្ឋានច្បាប់ និងការផ្សះផ្សាជាតិនៅកម្ពុជាពិតប្រាកដ ។

ដើម្បីសម្រេចបានគោលដៅនៃ "ការចងចាំ" និង "យុត្តិធម៌" មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតនូវមូលដ្ឋានកម្មវិធីការងារចំនួន៨ ក្នុងគោលបំណងបង្ហាញឲ្យកាន់តែច្បាស់នូវប្រវត្តិសាស្ត្រខ្មែរក្រហមផ្សព្វផ្សាយពត៌មានទាំងនេះទៅឲ្យសាធារណជនបានដឹង និងជំរុញឲ្យមានការទទួលខុសត្រូវ និងផ្សះផ្សាជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គម្រោងការសំខាន់ៗរបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួមមាន÷ ១) ការចងក្រងឯកសារ ២) ការបង្កើតផែនទីទីតាំងរណ្តៅសាកសពជនរងគ្រោះ ៣) ការថតឯកសារជាមីក្រូហ្វីល ៤) ការស្រាវជ្រាវ ៥) ការបោះផ្សាយ ទស្សនាវដ្តីស្វែងរកការពិត ៦) ការជំរុញឲ្យមានការទទួលខុសត្រូវ ៧) ការបកប្រែ និងការបោះពុម្ពផ្សាយ និង៨) ការសិក្សាអំពីលលាដ៍ក្បាល

សាកសពជនរងគ្រោះ ។ ជាមួយគ្នានេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បង្កើតឡើងនូវកម្មវិធីការងារបន្ទាប់បន្សំផ្សេងទៀតដូចជា÷ ក) ការព្យាបាលជំងឺចិត្តសាស្ត្រដល់ជនរងគ្រោះក្រោមអំពើទារុណកម្ម ខ) ការបង្កើតសៀវភៅប្រវត្តិសាស្ត្រ គ) ប្រវត្តិសាស្ត្រផ្ទាល់មាត់សម្រាប់បណ្ណសារវីដេអូ ឃ) បណ្ណសាររូបថតឌីជីថល ង) ប្រមូលផ្តុំនិងពិនិត្យឯកសារពាក្យបណ្តឹង(ញត្តិ) និងច) ការបង្កើតតំណាងនៅតាមតំបន់ៗ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តកម្មវិធីបន្ទាប់បន្សំនេះជាបណ្តើរៗរួចមកហើយ ។ ដោយឯកឯង និងដោយរួមគ្នាគម្រោងការនីមួយៗនឹងក្លាយទៅជាវិភាគទានដ៏ធំធេងដល់គោលបំណងថែរក្សាប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីឲ្យមានការទទួលខុសត្រូវនិងការផ្សះផ្សានៅកម្ពុជា ។

មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងចងក្រងនូវប្រវត្តិសាស្ត្រពិតមួយអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែបញ្ចេញឈ្មោះចារីនៃបទល្មើស និងប្រាប់ឲ្យដឹងអំពីជោគវាសនាជនរងគ្រោះដែលបានបាត់ខ្លួន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែបើកឯកសារសម្ងាត់បន្សល់ទុកដោយសន្តិសុខកណ្តាលនៃរបបខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែរិះរកនូវការបង្រួបបង្រួមផ្សះផ្សាជាតិតាមរយៈការសិក្សាស្រាវជ្រាវ ក្រោយពីសោកនាដកម្មត្រូវបានបញ្ចប់ ។

ឥទ្ធិពលសោយចិត្តដែលចេញអំពី«ការពិត» សបញ្ជាក់ឲ្យឃើញអំពីគោលដៅការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ការបង្ហាញនូវការពិតតាមរយៈការស្រាវជ្រាវជាវិទ្យាសាស្ត្រពីអំពើប្រល័យពូជសាសន៍បន្តិចម្តងៗប្រជាជនកម្ពុជាអាចទទួលស្គាល់នូវការពិតដោយស្ងៀមស្ងាត់នៅក្នុងចិត្ត ។ ទោះបីថាតុលាការដែលគួរឲ្យទុកចិត្តនឹងចេញជារូបរាងក្នុងពេលខាងមុខនេះក្តី ក៏អ្វីដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបាននឹងកំពុងធ្វើនេះគឺមានគោលបំណងនាំមកនូវ «ការផ្លាស់ប្តូរភ្លាមៗនិងគួរឲ្យកត់សម្គាល់» ដល់ប្រទេសកម្ពុជានិងប្រជាជនកម្ពុជាម្តងម្នាក់ៗ ហើយទីបញ្ចប់នឹងអាចនាំដល់ «ការផ្សះផ្សាជាតិ» ក្នុងប្រទេសកម្ពុជា ។

ជាមួយនឹងការខិតខំប្រឹងប្រែងទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលជោគជ័យជាច្រើនក្នុងការធ្វើឲ្យជនរងគ្រោះក្រោមអំពើទារុណកម្មនៅក្នុងរបបខ្មែរក្រហមបានដឹងអំពីការពិតនិងការផ្លាស់ប្តូរអារម្មណ៍ ព្រមទាំងការជំរុញឲ្យមានកិច្ចព្រមព្រៀងជាផ្លូវការរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិដើម្បីរៀបចំ «ដំណើរការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម» ។

**សន្និដ្ឋានៈ គ្មានការពិត គ្មានយុត្តិធម៌, គ្មានយុត្តិធម៌ គ្មានការផ្សះផ្សាជាតិ**

ក្នុងករណីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ជាការច្បាស់ណាស់ថាប្រជាជនកម្ពុជាជាច្រើននាក់នៅតែរងឥទ្ធិពលពីរបបខ្មែរក្រហមនៅឡើយ ហើយចាំបាច់ត្រូវតែមានការផ្លាស់ប្តូរអារម្មណ៍ឡើងវិញ ។ ការពាំនាំរបស់ខ្ញុំនូវសំឡេងរបស់ជនរងគ្រោះនិងជនដៃដល់និងកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺផ្អែកលើជំនឿមួយថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងជួយនាំមកនូវការផ្លាស់ប្តូរភ្លាមៗ និងគួរឲ្យកត់សម្គាល់ជាមិនខាន ។ នៅពេលតុលាការខ្មែរក្រហមកើតមានឡើងពិតប្រាកដនោះ មជ្ឈមណ្ឌលឯកសារកម្ពុជាប្រាកដជានឹងមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ភស្តុតាងប្រឆាំងអតីតមេដឹកនាំខ្មែរក្រហម និងជាប្រភពពត៌មានដ៏ចម្បងទាក់ទងទៅនឹងតុលាការនេះ ។ ជាការពិតណាស់ នៅពេលមានតុលាការការងារទាក់ទងនឹងប្រវត្តិសាស្ត្រ ការជួបជាមួយសាធារណជន និងគម្រោងការផ្សេងៗទៀតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែមានដំណើរការដដែល ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងក្លាយជាព្រឹត្តិការណ៍មួយវាយបំបាក់វប្បធម៌ «និទណ្ឌទោស» (ភាពគ្មានទោស) ។ ការជំនុំជម្រះនឹងផ្តល់ឲ្យជនរងគ្រោះភាគច្រើននូវភាពធូរស្បើយក្នុងអារម្មណ៍ព្រមទាំងបង្ហាញដល់មហាជននូវហេតុការណ៍សម្ងាត់ផ្សេងៗជុំវិញអំពើប្រល័យពូជសាសន៍ដែលជាពត៌មានដែលប្រជាជនមិនបានដឹងពីមុនមក ។ ការដឹងនូវពត៌មានចេញពីតុលាការនេះនឹងក្លាយជាការរំសាយចិត្តសម្រាប់អ្នកដែលកំពុងទទួលផលប៉ះពាល់ពីអំពើប្រល័យពូជសាសន៍ ។ ជាមួយនឹងលទ្ធផលទាំងនេះ ប្រទេសកម្ពុជានឹងទទួលបានសន្តិភាពប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ ហេតុការណ៍នេះនឹងចូលទៅក្នុងករណីមួយហៅថា«ការពិតអាចធ្វើឲ្យអ្នកមានអារម្មណ៍ធូរស្បើយលែងខ្វល់ខ្វាយ» ។ តាមវិធីនេះ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងបានរួមចំណែកដល់«ការផ្សះផ្សាជាតិ» ពិតប្រាកដមិនខាន ។ **ហ៊ុយ វណ្ណៈ**

# បញ្ជីឈ្មោះសមាជិកគ្រួសាររបស់បុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម

| ល.រ | ឈ្មោះបុគ្គលិក | ឪពុក | ម្ដាយ | បងប្អូនស្រី | បងប្អូនប្រុស | ពូ | មីង | បងប្អូនជីដូនមួយ | ជីតា | ជីដូន | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| ១ | គីម កែវកន្និដ្ឋា | | | | | ២ | ១ | ៥ | ១ | | **៩** |
| ២ | ឃួយ វិសាលមុនី | ១ | | ២ | ១ | ១ | ៤ | ១០ | ២ | ២ | **២៣** |
| ៣ | ឆេង វើង | ១ | | ១ | ១ | | | ៣ | | | **៦** |
| ៤ | ឆាំង យុ | | | ១ | | ៣ | ១ | ៥ | | | **១០** |
| ៥ | ជួង សុភារិទ្ធ | | | | | ៧ | ៨ | ៨ | | | **២៣** |
| ៦ | នង ខត្តារ៉ា | | | | | ៩ | ៥ | | ២ | ២ | **១៨** |
| ៧ | ប៉ាង ពីរីន | | | | | ១ | | ១ | ១ | | **៣** |
| ៨ | ដាត កុសល | | | | | ៣ | ២ | ៤ | ១ | | **១០** |
| ៩ | ដេង ពង្សរ៉ាស៊ី | | | | ១ | ២ | | | | | **៣** |
| ១០ | ព្រំ ដល្លា | ១ | | | | | | ១ | | | **២** |
| ១១ | មាស ប៊ុនថាន | | | ១ | ២ | ៣ | ១ | ១២ | ១ | ១ | **២១** |
| ១២ | យិន ឆាយ | | | | | ១ | | ២ | | | **៣** |
| ១៣ | យិន នាន | | | | ១ | ៤ | ២ | ៨ | | | **១៥** |
| ១៤ | រស់ សមពៅ | ១ | ១ | ១ | ១ | | | | | | **៤** |
| ១៥ | រ៉ា ឆៃរ៉ាន់ | | | | | ១ | ៥ | ១០ | ២ | ១ | **១៩** |
| ១៦ | លី សុខឃាង | | | ១ | | | | | | | **១** |
| ១៧ | លី សុផល | | | | | ៥ | ៣ | | ៣ | ២ | **១៣** |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ១៨ | លឹម គី | ១ | ១ | ១ | | | | ៥ | | | ៨ |
| ១៩ | វ៉ាន់ថាន់ ពៅ ដារ៉ា | | | ១ | ១ | | | | | | ២ |
| ២០ | សាន់ កល្យាណ | | | | | ១ | | | ១ | | ២ |
| ២១ | សារិន វីរៈ | | | | | | | | ១ | | ១ |
| ២២ | សុខ វណ្ណៈ | | | | | ៣ | ៣ | | ១ | | ៧ |
| ២៣ | សុខា អ៊ីវ៉ែន | | | ១ | | | ១ | | | ១ | ៣ |
| ២៤ | ស៊ឹម សុភ័ក្រ្ត | | | | | ១ | | | | | ១ |
| ២៥ | ស៊ឹម សុរិយា | ១ | | ១ | | ១ | | | | | ៣ |
| ២៦ | សួ ប៊ុនស៊ួ | | | | | ២ | ១ | | ២ | ១ | ៦ |
| ២៧ | សួ ហូរីណា | | | ១ | | ១ | ១ | ៦ | | | ៩ |
| ២៨ | សើ សាយ្យាណោ | | | | | ២ | ២ | | ២ | ១ | ៧ |
| ២៩ | សំ មករា | | | | | ៣ | ២ | ៦ | | ១ | ១២ |
| ៣០ | ហ៊ុយ វណ្ណៈ | | | | ១ | ១ | ១ | ១ | ១ | | ៥ |
| ៣១ | ហ៊ុយ សោភ័ណ | | | | | ២ | ១ | | ១ | ២ | ៦ |
| ៣២ | ឡុង អូន | ១ | | | | ៥ | ២ | ៦ | | | ១៤ |
| ៣៣ | អៀ ម៉េងទ្រី | | | | | ៤ | | | | | ៤ |
| ៣៤ | អែម ឆាត | | | | ១ | ១ | ៣ | ២២ | | | ២៧ |
| ៣៥ | អ៊ូច សំអឿន | | | | ១ | ២ | ១ | | | ១ | ៥ |
| ៣៦ | អ៊ីសា ឧស្មាន | | | ១ | ២ | ៤ | ៤ | ១៦ | ១ | ១ | ២៩ |
| ៣៧ | អែម សុខឃីម | | | | | ៤ | ១ | ៦ | ២ | | ១៣ |
| ៣៨ | អ៊ី សំភី | | | | | ១ | ១ | | ២ | | ៤ |
| ៣៩ | អឿ រតនា | | | | | ២ | | ១៤ | | | ១៦ |
| | | | | | | | | | | សរុប : | ៣៦៧ |





*ឈ្មោះ សោម នឹម អាយុ ៥៦ឆ្នាំ (បច្ចុប្បន្ន), តួនាទី ប្រធានក្រុម, ចូលបដិវត្តន៍នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៤, ស្រុកកំណើតនៅឃុំព្រែកថ្មី ស្រុក១៨ តំបន់២៥ ខេត្តកណ្តាល ។ សោម នឹម (បច្ចុប្បន្ន)៖ "នៅក្នុងឆ្នាំ១៩៧៤ គេឃោសនាជ្រើសរើសទ័ព ខ្ញុំស្ម័គ្រចិត្តទៅ ព្រោះនឹកឃើញថានៅក្រោយ ពិបាកគេឲ្យលើកភ្លឺប្រឡាយ ទៅមុខក៏ពិបាកដែរ តែបានហូបគ្រាន់បើជាងនៅក្រោយ ។ កាលហ្នឹងឪពុកខ្ញុំអត់ឲ្យទៅទេ ប៉ុន្តែខ្ញុំចង់ទៅ ព្រោះអីខ្ញុំថា ខ្ញុំនៅក្រោយក៏គេមើលងាយ ខ្ញុំមិនខ្ចីនៅឲ្យគេមើលងាយទេ ខ្ញុំទៅហើយ ។ ឪពុកខ្ញុំទឹកភ្នែករងណាស់ តែដល់ខ្ញុំទៅគាត់យំ ។ ខ្មែរក្រហមបានបំផ្លាញគ្រួសារខ្ញុំ ព្រោះអីបែកបាក់បងប្អូនអស់ហើយ ឲ្យជួបជុំគ្នាឯណា បើឃើញតែបែកបាក់គ្នា អត់បាយក្រហាយទឹក បងប្អូននៅឆ្ងាយពីគ្នាបងមិនដែលស្គាល់ប្អូន ។ ខ្ញុំគ្មានជឿអីបន្តិចទេកាលហ្នឹង ប៉ុន្តែមិនដឹងធ្វើម៉េច បើយើងនៅក្រោមការគ្រប់គ្រងរបស់គេទាល់តែរស់តាមការណែនាំរបស់គេ ខ្លាចស្លាប់ធ្វើម៉េចឲ្យតែរស់ ។*

*សោម នឹម (១៩៧៥)*

**រូបតាំងពិព័រណ៍ ហេង ស៊ីនិត្យ**

# ហេង ស៊ីនិត្យៈ រូបភាពជនដៃដល់


ហេង ស៊ីនិត្យ

ខ្ញុំកើតនៅភូមិព្រៃកគាកូវ (អតីតភូមិព្រៃកថោង) ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ ខ្ញុំមានបងប្អូន៨នាក់ ។ ខ្ញុំគឺជាកូនទី៦ ។ ម្តាយខ្ញុំប្រកបរបរត្បាញ ចំណែកឪពុកខ្ញុំប្រកបរបរធ្វើស្រែចម្ការនិងជាជាងឈើ ។ ដើមឆ្នាំ១៩៧៥ ប្រជាជនក្នុងភូមិរបស់ខ្ញុំទាំងអស់បានភៀសខ្លួនចេញពីភូមិ ដើម្បីគេចពីគ្រាប់ផ្លោង ។ ម្តាយរបស់ខ្ញុំត្រូវបានឪពុកខ្ញុំជម្លៀសមកនៅជិតជនភៀសខ្លួននៅជ្រោយចង្វា ។

ចំណែកឪពុករបស់ខ្ញុំនិងខ្ញុំ ព្រមទាំងបងប្រុសខ្ញុំម្នាក់ទៀត នៅមើលគោនៅឯផ្ទះ និង រកត្រីនៅក្បែរៗភូមិដើម្បីយកមកឲ្យម្តាយខ្ញុំលក់ ។ បងៗខ្ញុំបីនាក់រស់នៅភ្នំពេញ ។ ភូមិរបស់ខ្ញុំស្ងាត់ជ្រងំ ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំនៅជ្រោយចង្វាជាមួយម្តាយឪពុកនិងបងប្អូនរបស់ខ្ញុំ ។ យើងកំពុងតែជួបជុំគ្នាក្នុងឱកាសចូលឆ្នាំថ្មី ។ នៅយប់ថ្ងៃទី១៧ ក្រោយថ្ងៃចូលឆ្នាំថ្មីបានពីរថ្ងៃមានការបាញ់គ្នាខ្លាំងណាស់ ខ្ញុំរត់ចូលក្នុងលេណដ្ឋាន ។

ពេញមួយយប់ ខ្ញុំនៅក្នុងលេណដ្ឋានរហូតដល់ពេលថ្ងៃរះខ្ញុំចេញមកក្រៅវិញស្រាប់តែឃើញប្រជាជនទាំងអស់លើកទង់ជ័យសគ្រប់គ្នា ហើយឃើញទ័ពខ្មែរក្រហមព្រាតពេញកន្លែងស្ពានជ្រោយចង្វា ។ ខ្មែរក្រហមបង្ខំឲ្យឪពុកខ្ញុំចម្លងកងទ័ពខ្មែរក្រហមពីស្រុកអរិយក្សត្រមកជ្រោយចង្វារួចហើយទាហានទាំងនោះបានឆ្លងចូលមកភ្នំពេញ ។ ក្រុមគ្រួសាររបស់ខ្ញុំក៏វិលត្រឡប់ទៅភូមិកំណើតវិញ ។ ឪពុករបស់ខ្ញុំនៅតែចម្លងប្រជាជនដែលជម្លៀសចេញពីភ្នំពេញ ។ ពេលនោះមានប្រជាជនពីទីក្រុងភ្នំពេញច្រើនណាស់ធ្វើដំណើរគគ្រឹកគគ្រេងកាត់មុខផ្ទះរបស់ខ្ញុំ ។ អ្នកទាំងនោះវេទនាណាស់ អត់បាយអត់ទឹកព្រោះមិនបានយកអង្ករនិងស្បៀងទៅជាមួយ ។ គ្រួសារខ្លះទៅសុំស្នាក់អាស្រ័យនៅនឹងផ្ទះរបស់ខ្ញុំបានប្រហែល៤-៥ថ្ងៃ កន្លះខែ ឬមួយខែក៏ត្រូវខ្មែរក្រហមជម្លៀសបន្តទៅទៀត ។ បន្ទាប់ពីប្រជាជនជម្លៀសពីទីក្រុងភ្នំពេញទៅផុតអស់ហើយ ដល់វេនប្រជាជនក្នុងភូមិរបស់ខ្ញុំត្រូវជម្លៀសម្តង ។ ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមរក្សាឲ្យនៅក្នុងភូមិដដែលដោយសារគាត់មានជំនាញជាងឈើ ។ បងប្អូនខ្ញុំអ្នកដែលនៅលីវសុទ្ធតែបាននៅជួបជុំឪពុកម្តាយទាំងអស់ ចំណែកបងៗដែលមានគ្រួសារហើយត្រូវជម្លៀសឲ្យទៅរស់នៅឆ្ងាយដោយជិះតាមកប៉ាល់ទៅតាមទន្លេមេគង្គលើ ។ យើងលាគ្នាដោយទឹកភ្នែក ។

បន្ទាប់ពីជម្លៀសប្រជាជនស្ងាត់អស់ពីភូមិហើយ យប់ៗឡើងចន្លោះពីម៉ោង៧ដល់ម៉ោង១០ ខ្ញុំឃើញទាហានខ្មែរក្រហមប្រមាណពីរបីនាក់បណ្តើរប្រជាជនទាំងជួរៗដែលមានដៃជាប់ចំណងដើរកាត់តាមមុខផ្ទះខ្ញុំពីទិសខាងត្បូងទៅទិសខាងជើង ។ អ្នកទាំងនោះដើរដោយស្ងៀមស្ងាត់ជាទីបំផុត ។ ជួនកាលឮសំឡេងមនុស្សស្រែកឮអ៊ឺក ពេលនោះខ្ញុំដឹងថាខ្មែរក្រហមបានវាយមនុស្សហើយ ។ ខ្ញុំឮឪពុកខ្ញុំនិងចាស់ៗក្នុងភូមិនិយាយថាខ្មែរក្រហមយកប្រជាជនទាំងនោះទៅរៀនសូត្រ ប៉ុន្តែតាមពិតមានន័យថា អ្នកទាំងនោះត្រូវយកទៅសម្លាប់ ។

ខ្មែរក្រហមចាប់ផ្តើមប្រមូលប្រជាជនចាស់ពីរបីភូមិមកបញ្ចូលតែមួយភូមិ ហើយភូមិរបស់ខ្ញុំត្រូវបានដូរឈ្មោះទៅជាភូមិប្រយុទ្ធដែលមានប្រជាជនប្រមាណ៣០គ្រួសារ ។ ឪពុកខ្ញុំធ្វើជាងឈើ ធ្វើរនាស់ នង្គ័ល ។ ម្តាយខ្ញុំត្រូវចាត់ចូលជាវ័យកណ្តាលធ្វើចម្ការ ។ បងៗខ្ញុំចូលក្នុងកងចល័ត ចំណែកខ្ញុំដែលមានអាយុ១៣ឆ្នាំត្រូវឃ្វាលគោ ។ ការងារប្រចាំថ្ងៃរបស់ខ្ញុំគឺឃ្វាលគោពីរក្បាលឲ្យបានល្អ ។ គោខ្ញុំឈ្មោះ អាខ្វា និងអាប្រាក់ ។ អាប្រាក់ ជាគោស្លូតមិនចេះជល់ទេ ចំណែកអាខ្វាពូកែជល់ខ្លាំងណាស់ នៅក្នុងភូមិស្ទើរតែគ្មានគោមួយណាជល់ឈ្នះវាឡើយ ។ ម្យ៉ាងទៀត គោរបស់ខ្ញុំចេះសំពះ ខ្ញុំគ្រាន់តែប្រាប់ថា «អាខ្វាសំពះ» វាលុតជង្គង់ក្រាបសំពះ ហើយខ្ញុំអាចឡើងជិះវាបានដោយស្រួល ។ ខ្ញុំស្រលាញ់គោរបស់ខ្ញុំណាស់ ហើយវាក៏ស្រលាញ់ខ្ញុំវិញដែរ ។

ក្រុមកុមារឃ្វាលគោទាំងអស់ត្រូវទៅឃ្វាលគោនៅព្រៃឆ្ងាយៗពីភូមិ ប៉ុន្តែសំណាងល្អគោរបស់ខ្ញុំនិងគោ៣នឹមទៀត គឺជាគោគំរូដូច្នេះអាចឃ្វាលនៅក្បែរៗភូមិបាន ។

ពេលមួយខ្ញុំមានជំងឺគ្រុនចាញ់ ។ ខ្ញុំដេករងាញាក់តែម្នាក់ឯងនៅក្រោមដើមឈ្នួរដែលមានស្លឹកជ្រុះក្រាលពាសពេញដី ចំណែកគោមិនដឹងដើរទៅដល់ណា ។ មួយសន្ទុះធំខ្ញុំស្វាងពីរងាញាក់ទើបរត់រកគោ ។ ខ្ញុំភ័យខ្លាំងណាស់ខ្លាចបាត់គោ ។ បើបាត់គោខ្ញុំពិតជាត្រូវទទួលទណ្ឌកម្មជាមិនខាន ។ កាលនោះឲ្យតែធ្វើអ្វីខុសបន្តិចបន្តួចខ្ញុំភ័យស្ទើរស្លាប់ ខ្ញុំហាក់ដូចជាបាក់ស្បាតតែម្តង ។ ឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមរើសកងចល័ត ពេលនោះបងប្រុសរបស់ខ្ញុំដែលមានអាយុច្រើនជាងខ្ញុំបន្តិចបានចូលកងចល័តភូមិ ។ ខ្ញុំនៅតែឃ្វាលគោដដែល ។ រយៈពេលប្រហែលមួយខែទើបខ្ញុំបានជួបមុខបងម្តង ។ ពេលជួបគ្នាម្តងៗ ពួកខ្ញុំសប្បាយចិត្តណាស់រត់ទៅរកគ្នា ។

នៅឆ្នាំ១៩៧៦នេះ កុមារឃ្វាលគោដូចជាខ្ញុំត្រូវប្រធានកងចេញបញ្ជាឲ្យរែកដីនៅពេលយប់ទៀត ។ ក្នុងម្នាក់ត្រូវរែកឲ្យបានមួយម៉ែត្រគូប បើមិនបានមិនអាចទៅដេកបានឡើយ ។ ពួកខ្ញុំចូលគ្នាជាក្រុមបីៗនាក់ ម៉្លោះហើយដីបីម៉ែត្រគូបម្នាក់ជាអ្នកកាប់ដីពីរនាក់ជាអ្នកសែង ។ យើងធ្វើការសុទ្ធតែប្រណាំងគ្នាដើម្បីឲ្យឆាប់ហើយឆ្អាលនឹងបានទៅដេក ។ ជារៀងរាល់ព្រឹកទាំងអស់គ្នាត្រូវស្រូតងើបពីម៉ោងបីទៀបភ្លឺ ដើម្បីបោសសំរាមនៅតាមផ្លូវក្នុងភូមិ ។ ផ្លូវភូមិដែលមានប្រវែងប្រមាណ៧០០ម៉ែត្រត្រូវបានបោសសម្អាតជារៀងរាល់ថ្ងៃ ។ ខ្ញុំមានវេន២ថ្ងៃបោសម្តង ។ បោសសំរាមរួចហើយម៉ោង៥ត្រូវកើបអាចម៍គោរបស់ខ្លួនឯងយកមកដាក់ក្នុងរណ្តៅដី ហើយត្រូវរាយការណ៍ឲ្យប្រធានក្រុមដឹងថាព្រឹកនេះខ្ញុំបានដីរប៉ុន្មាន ។ យប់ខ្លះប្រធានកងឲ្យវាយកណ្តុរយប់ខ្លះឲ្យជញ្ជូនចំបើង ។ ខ្ញុំមិនដែលបានទំនេរទេ ។

ចូលដល់ឆ្នាំ១៩៧៧ អង្គការបង្ខំឲ្យប្រជាជនវាយសម្រុកការងាររកាន់តែខ្លាំងក្លា ហើយតាមដែលខ្ញុំដឹងខ្មែរក្រហមបានសម្លាប់ប្រជាជនកាន់តែច្រើនតាំងពីចុងឆ្នាំ១៩៧៦រហូតមកដល់ឆ្នាំ១៩៧៧ ។ ប្រជាជនចាប់ផ្តើមអត់បាយខ្លាំងណាស់ព្រោះអង្គការឲ្យ ប្រជាជនហូបបបររាវក្នុងមួយខ្ទះគ្មោតដាក់អង្ករតែបីកំប៉ុងប៉ុណ្ណោះ ។ ម៉្លោះហើយម្នាក់ៗដើរកាត់ទងដំឡូងជ្វាដើម្បីយកទៅលាយបបរហូប ។ ម្នាក់ៗស្គម ហើយថែមទាំងមានចម្រៀងថា «ក្បាលជង្គង់ព័ន្ធគ្នា ក្លួតគ្នាចេញភ្លើង» ។ នេះជារឿងពិតមែន ទាំងខ្ញុំទាំងគេដើរព័ន្ធជើងហើយក្បាលជង្គង់ទង្គិចគ្នាឈឺណាស់ ។ ខ្ញុំចាប់ផ្តើមលួចអាហារ ។ ខ្ញុំលួចឡើងដើមដូងកកេរផ្លែដូងនៅលើដើម ប្រើឈើមួយចោះរួចបឺតទឹកដូង ហើយទុកផ្លែចោលនៅលើដើម ។ ខ្ញុំមិនហ៊ានបេះផ្លែដូងទេ ខ្លាចគេចាប់ភស្តុតាងបាន ។ ខ្នុរផ្លែចាស់មិនទាន់ ខ្ញុំឡើងបេះយួរតាំងពីលើដើមចុះមក មិនហ៊ានទម្លាក់មកដីទេ ។ បេះបានមកហើយយកទៅកប់ក្នុងគុម្ពចេកដែលរលួយគល់ ។ ពីរបីថ្ងៃក្រោយពេលយកគោទៅលាងទឹក ខ្ញុំលួចចូលមកហែកខ្នុរហូប ។ ពេលត្រឡប់មកពីឃ្វាលគោវិញ ខ្ញុំលួចកាប់ចេកខ្ចីយកទៅដុតហូបនៅក្នុងព្រៃជ្រៅអត់ឲ្យខ្មែរក្រហមឃើញទេ ។ ខ្ញុំឡើងយកកូនចាបនិងពងចាបនៅក្នុងសំបុកនិងទៅប្រមូលពងសត្វព្រៃនៅក្នុងគុម្ពកក់ ។ កង្កែបអាចម៍គោអី ខ្ញុំចាប់ហូបទាំងអស់ ។ ថ្ងៃមួយនោះខ្ញុំកំពុងតែកាប់ចេកលាន់ច្រោកៗ ស្រាប់តែគណៈឃុំឈ្មោះ ឌុំ ដែលជិះកង់កាត់នោះ ឈប់កង់ឈ្ញឹត ហើយសួរថា «ចុះអាណាធ្វើអីកន្លែងហ្នឹង?» ខ្ញុំពីរនាក់ពួកម៉ាកឈ្មោះ អាសួយទ្រី រត់ប្រាវលោតរំលងបន្ទាអំពិលទឹកដែលមានប្រវែង៣ម៉ែត្រ និងមានកម្ពស់ប្រហែល៦ប្ញ៧តឹក ។ ពួកខ្ញុំលោតរំលងផុតទៅពួននៅក្នុងព្រៃ ភ័យញ័រសាច់ទទ្រើក ។ ឪពុកខ្ញុំលួចបេះផ្លែដូងនៅក្រោយផ្ទះយកមកកាប់មុខលើចេញ មានទឹកនៅក្នុងផ្លែដូងហ្នឹង ដាក់អង្ករចូលយកទៅដុតនៅក្នុងភ្លក់ភ្លើងគោ ដល់ឆ្អិនដួសចែកគ្នាហូបម្នាក់បន្តិចៗ ។ កាលនោះបានបាយប្ញអ្វីបន្តិចបន្តួចហូបឆ្ងាញ់ណាស់ ហើយអរក្រៃណាអរ ។

ពេលខ្ញុំមើលគោ ខ្ញុំយកគោទៅចងនៅក្បែរកន្លែងម្តាយខ្ញុំធ្វើចំការហើយជួយធ្វើការងាររបស់គាត់ ។ ក្នុងចិត្តខ្ញុំគិតថានឹងជួយម្តាយខ្ញុំឲ្យបានច្រើន ប៉ុន្តែខ្ញុំមិនដែលជួយគាត់បានច្រើនទេព្រោះរាល់លើកខ្ញុំតែងតែឆាប់ហត់ ។ ល្ងាចឡើងពេលចងគោទុកហើយ ខ្ញុំមកអង្គុយចាំនៅមាត់ផ្លូវចាំមើលម្តាយខ្ញុំត្រឡប់មកពីចម្ការ ខ្ញុំចាំជួយទូលល្អីយកមកផ្ទះ ។ ជាធម្មតាក្នុងចំណោមក្រុមអ្នកធ្វើចម្ការដែលមានគ្នា៨នាក់ ម្តាយខ្ញុំមិនដែលដើរមុខគេទេព្រោះគាត់ខ្សោយជាងគេ គាត់តែងតែដើរក្រោយគេជានិច្ច ។

ឆ្នាំ១៩៧៨ ទឹកឡើងធំលិចភូមិទាំងអស់ ។ ពីមុនៗមកភូមិរបស់ខ្ញុំមិនដែលលិចទឹកទេ ទើបតែឆ្នាំនេះទឹកធំរហូតដល់លិចភូមិ

របស់ខ្ញុំជម្រៅត្រឹមជង្គង់ ។ មនុស្សកើតជំងឺទឹកស៊ីជើងគ្រប់គ្នា ។ ម្នាក់ៗឲ្យតែមុតអ្វីតែបន្តិចកើតទៅជាដំបៅរលួយរាប់ខែ ទោះជាបិទថ្នាំអ្វីក៏មិនជា ។ បងខ្ញុំ និងខ្ញុំសុទ្ធតែកើតដំបៅជើង ។ ខ្ញុំនៅសល់ស្លាកស្នាមរហូតដល់សព្វថ្ងៃ ។ ខ្ញុំចេះហួចចេញជាបទបែបយ៉ាងពិសេស ។ ដូច្នេះចាស់ៗដែលធ្វើការនៅផ្ទះស់ហៅខ្ញុំទៅដេកលេងជាមួយគាត់ ពេលយប់ឲ្យខ្ញុំហួចឲ្យគាត់ស្តាប់ ហើយដល់ព្រលឹមឡើងគាត់ឲ្យបង្កង និងត្រីដល់ខ្ញុំដើម្បីយកមកផ្ទះ ។

ចុងឆ្នាំ១៩៧៨ ពេលដែលទឹកស្រកទៅវិញមានមនុស្សបីនាក់ប្តឹងអំពីឪពុកខ្ញុំថាគាត់និយាយមិនចេះលាក់ការណ៍ ។ កាលជំនាន់នោះមានពាក្យថា «លាក់ការណ៍ខុស់ រស់បានយូរ» ហើយឪពុកខ្ញុំមិនចេះលាក់ការណ៍ គាត់ឃើញយ៉ាងម៉េចគាត់ថាឲ្យគេអ៊ីចឹង ។ ដល់គេខឹង គេរាយការណ៍ទៅគណៈសង្កាត់ ។ សង្កាត់ក៏ហៅឪពុកខ្ញុំទៅសហករណ៍នៅពេលយប់ដើម្បីស្អែកឡើងយកចេញពីភូមិទៅកសាង ។ ឪពុកខ្ញុំដឹងថាទៅនេះពិតជាស្លាប់ហើយ គាត់មកលាប្រពន្ធនិងកូន ។ ម៉ោងប្រហែល៧យប់ ឪពុកខ្ញុំផ្តាំលាម៉ែខ្ញុំនិងបងប្អូនខ្ញុំ ។ ម៉ែខ្ញុំធ្វើមុខក្រៀមគាត់មិនយំទេ ប៉ុន្តែមុខគាត់ក្រហម ។ បងប្អូនខ្ញុំទាំងអស់គ្នាធ្វើមុខស្រងូតស្រងាត់ ។ នៅក្នុងរបបខ្មែរក្រហមខ្ញុំមានលាក់កូនសៀវភៅមួយសម្រាប់កត់ត្រារឿងរ៉ាវអ្នកណានិយាយពីឪពុកខ្ញុំថាម៉េចខ្លះ ខ្ញុំកត់ទុកទាំងអស់ ប៉ុន្តែក្រោយមកខ្ញុំធ្វើបាត់សៀវភៅនោះ ។ ឪពុកខ្ញុំនិយាយថា «កូនកុំព្រួយបារម្ភអី ឪពុកស្លាប់ហើយ ស្អែកនេះគេយកពុកទៅសម្លាប់ហើយ» ។ គាត់ផ្តែផ្តាំម្តាយខ្ញុំថាឲ្យជួយមើលកូនឲ្យបានល្អ គាត់អត់បាននៅទេ ។ គាត់វេចខោអាវខ្មៅតែមួយចង្កេះយកទៅតាមខ្លួន ។ គាត់ថាទុកស្លៀកពេលស្លាប់ ។ គាត់ចេញទៅម៉ោង៧យប់ ដល់ម៉ោងប្រហែល៩ស្រាប់តែគាត់ត្រឡប់មកវិញ ។ គាត់ថាគេអត់យកទៅសម្លាប់ទេ គេឲ្យគាត់នៅកសាងខ្លួនទៀតទាល់តែមានកំហុសម្តងទៀតទើបគេយកទៅ ។

ខ្មែរក្រហមដែលមកគ្រប់គ្រងភូមិរបស់ខ្ញុំមានបួនដំណាក់កាល ។ ដំណាក់កាលទី១ គឺខ្មែរក្រហមស្លូតហើយសុទ្ធតែជាកូនក្មេងឲ្យតែឃើញមនុស្សចាស់ហៅញោមទាំងអស់ ។ បានមួយខែអង្គការយកមនុស្សមកពីស្រែឆ្ងាយៗមកធ្វើប្រធាននៅក្នុងស្រុកខ្ញុំ ។ ពួកនេះចាប់ផ្តើមសម្លាប់ប្រជាជន ។ ដំណាក់កាលទី៣ គេហៅពួកមជ្ឈិម ពេលហ្នឹងចុងឆ្នាំ១៩៧៧ចូលឆ្នាំ១៩៧៨ ។ ពួកមជ្ឈិមស្លូតៗណាស់ មកដល់រុះរើរាំងននដែលតុបតែងរោងសិល្បៈចែកអ្នកភូមិឲ្យកាត់ខោអាវគ្រប់គ្នា ហើយយកខោអាវដែលខ្មែរក្រហមប្រមូលទុកកាលពីឆ្នាំ៧៥នោះ យកមកចែកឲ្យប្រជាជនវិញទាំងអស់ ។ ពួកមជ្ឈិមមកបានប្រហែលបីបួនខែអង្គការផ្លាស់ពួកមជ្ឈិមចេញ យកពួកនិរតីទៅគ្រប់គ្រង ។ ពួកនិរតីហ្នឹងភ្នែកក្រហមគួរឲ្យខ្លាចណាស់ ។ ពេលនោះចុងឆ្នាំ១៩៧៨ អង្គការបញ្ចាំងកុននៅចុងព្រែកហួង ហើយប្រមូលប្រជាជនទាំងក្មេងទាំងចាស់ឲ្យទៅមើលកុនទាំងយប់ ។ កន្លែងបញ្ចាំងកុនសុទ្ធតែព័ទ្ធខ្សែអត់ឲ្យប្រជាជនដើរចេញក្រៅបរិវេណហ្នឹងទេ ។ អ្នកស្រុកខ្លះគិតថា ពេលហ្នឹងខ្មែរក្រហមមានគម្រោងសម្លាប់ប្រជាជនទាំងអស់ ។ សំណាងល្អហាក់ដូចជាមានកម្លាំងអាថ៌កំបាំងមួយជួយអ្នកភូមិឲ្យរួចជីវិត ដោយមានខ្យល់ព្យុះមកយ៉ាងខ្លាំងស្ទើរតែរលំដើមឈើអស់ ។ រំលងប្រហែលមួយខែក្រោយមក អង្គការឲ្យមើលកុនម្តងទៀតកាន់តែឆ្ងាយជាងមុន ចម្ងាយប្រហែលជាបីបួនគីឡូម៉ែត្រពីភូមិ ដើរហើយកាត់ព្រៃយប់ស្ងាត់ជ្រងំ ។ កុនបង្ហាញរូប ប៉ុល ពត ទៅទស្សនារោងចក្រធ្វើចង្ក្រាន ធ្វើចាន ធ្វើស្លាបព្រារបស់កម្ពុជាប្រជាធិបតេយ្យ បង្ហាញពីមនុស្សធ្វើស្រែ មនុស្សធ្វើអីហ្នឹងភ្លឺស្រែសុទ្ធតែលុញ ដើម្បីឲ្យរលោង ។ ដល់ពេលកុនជិតចប់មានបាតុភូតចម្លែកកើតឡើងម្តងទៀត ។ អ្នកភូមិខ្ញុំក៏បានរួចជីវិតរហូតដល់ថ្ងៃ៦ មករា ឆ្នាំ១៩៧៩ ។

នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៩ឪពុកខ្ញុំស្លាប់ដោយសារជំងឺខ្យល់គ ។ ខ្ញុំដើររកស៊ីជាមួយម្តាយខ្ញុំ ។ ខ្ញុំទៅរកត្រីយកទៅផ្អើរមួយថ្ងៃបានប្រហែលពី១៥ទៅ២០ចង្កាក់ រួចហើយខ្ញុំយកត្រីផ្អើរទៅលក់ជាមួយម៉ែខ្ញុំ ។ ម្តាយខ្ញុំធ្វើនំឲ្យខ្ញុំដើរលក់ ។ ខ្ញុំលក់ដៃឈើតាមរដូវ ។

ឆ្នាំ១៩៧៩ ខ្ញុំចូលរៀននៅសាលានៅក្នុងភូមិ ។ ដោយសារខ្ញុំបានរៀនត្រឹមថ្នាក់ទី១០ពីសង្គមមុន ខ្ញុំអាចអាននិងសរសេរបានច្រើន ។ ដល់ឆ្នាំ១៩៨០ ខ្ញុំចូលរៀនថ្នាក់ទី៤ ។ ឆ្នាំ១៩៨១ ខ្ញុំប្រឡងបញ្ចប់ថ្នាក់បឋមសិក្សា ។ ឆ្នាំ១៩៨៤ ខ្ញុំចូលរៀននៅសាលាវិចិត្រសិល្បៈផ្នែកនិពន្ធ ។ ខ្ញុំស្នាក់នៅជាមួយបងប្រុសរបស់ខ្ញុំ ផ្ទះនៅជិតវត្តភ្នំ ។ ក្រោយមកទៀត ឆ្នាំ១៩៩៣ បងខ្ញុំសុំបានដាន់ទីមួយនៅផ្សារឌុយម៉ិច ។ ទៅរៀនខ្ញុំមានខោអាវតែមួយកំប្លេទេ គឺអាវពណ៌ស និងខោជើងវែងពណ៌ទឹកប៊ិក ។

ឆ្នាំ១៩៨៨ ខ្ញុំទៅស៊ីឈ្នួលធ្វើការនៅកោះកុងសន្សំលុយបានជាង១០០០បាត្រ គ្រឡប់មកវិញខ្ញុំរៀបការប្រពន្ធ ។ ខ្ញុំរៀបការឆ្នាំ១៩៩០ ពេលនោះខ្ញុំអាយុ២៧ឆ្នាំ ។ រៀបការហើយខ្ញុំអត់មានលុយសោះ ព្រោះខ្ញុំអត់មានការងារធ្វើរំពឹងតែលើម្ដាយក្មេកខ្ញុំលក់បបរតែមួយឆ្នាំងតូចជារៀងរាល់ថ្ងៃ ។ ខ្ញុំសម្រេចចិត្តទៅធ្វើជាងសំណង់ ។ ពេលដែលអ៊ុនតាក់ចូលស្រុក ខ្ញុំក៏ធ្វើការឲ្យអ៊ុនតាក់ ។

ខ្ញុំចាប់ផ្តើមមុខរបរថតរូបពី ឆ្នាំ១៩៩៣មុនដំបូងគឺថតរូបនៅមុខវាំងខ្ញុំទិញម៉ាស៊ីនថតរូបធុនមធ្យមមួយដែលផលិតនៅប្រទេសអាល្លឺម៉ង់ ។ ខ្ញុំមានបំណងក្លាយជាអ្នកកាសែតតាំងពីខ្ញុំនៅរៀនម៉្លេះ ប៉ុន្តែគ្មានអ្នកណាជួយខ្ញុំគេថាមើលទៅខ្ញុំមិនទំនងជាស្រីឬប្រុស ។ ខ្ញុំខឹងណាស់ ។ ខ្ញុំចាប់ផ្តើមក្លាយជាអ្នកកាសែតពីខែធ្នូ ឆ្នាំ១៩៩៣ ។ លើកទី១ខ្ញុំធ្វើការឲ្យកាសែតខ្មែរឯករាជ្យ ។ មួយឆ្នាំក្រោយមកខ្ញុំធ្វើការឲ្យកាសែត *Cambodia Times* ។ ខែតុលា ឆ្នាំ១៩៩៦ ខ្ញុំធ្វើការឲ្យកាសែត *Cambodia Today* ។ រហូតដល់ខែកក្កដា ឆ្នាំ១៩៩៧ កាសែត *Cambodia Today* ត្រូវបិទខ្ញុំមកធ្វើ *Free Land* ឲ្យ *Cambodia Daily* ។ បច្ចុប្បន្ននេះខ្ញុំក្លាយទៅជាអ្នកថតរូបឯករាជ្យ គឺខ្ញុំធ្វើអីដោយខ្លួនឯង ខ្ញុំថតរូបបានល្អ ខ្ញុំយកទៅលក់ឲ្យគេ រហូតដល់កាសែតអន្តរជាតិទទួលស្គាល់ខ្ញុំ ហើយខ្ញុំឈានទៅធ្វើពិពណ៌នៅទីក្រុងបាងកកកាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០០១ ក្រោមប្រធានបទ “*Recieprocal Works*” ។

ខ្ញុំចាប់ផ្តើមចង់ធ្វើពិព័រណ៍រឿងខ្មែរក្រហមបន្ទាប់ពី *World Trade Center* ត្រូវយន្តហោះបុកកម្ទេច ហើយឯកឧត្តម កូហ្វី អាណាន់ និយាយថា *No longer Negotiate Khmer Rouge in Cambodia* ។ ចាប់ផ្តើមពីពាក្យហ្នឹងមក ខ្ញុំចង់ឲ្យរឿងរ៉ាវខ្មែរក្រហមត្រូវបានរំឭកឡើងវិញ ។ លោក ឆាំង យុ បានទៅលើកទឹកចិត្តខ្ញុំនៅក្នុងពិព័រណ៍របស់ខ្ញុំនៅទីក្រុងបាងកក ហើយគាត់បានឲ្យយោបល់ខ្ញុំអំពីរឿងធ្វើពិព័រណ៍ខ្មែរក្រហមនៅទួលស្លែង ។ មុននឹងខ្ញុំសម្រេចចិត្តធ្វើពិព័រណ៍នេះ ខ្ញុំសួរមនុស្សច្រើនណាស់ មានប្រពន្ធខ្ញុំនិងមិត្តភក្តិរបស់ខ្ញុំ ។ ភាគច្រើនអ្នកទាំងអស់នោះគាំទ្រខ្ញុំ ប៉ុន្តែមានម្នាក់ដែលខ្ញុំមិនសូវស្និទ្ធស្នាលនិយាយថា «គេរស់នៅបានសុខហើយម៉េចក៏ ស៊ីនិត្យ ឯងកកូរកកាយរឿងខ្មែរក្រហមធ្វើអីទៀត?» ពាក្យមួយម៉ាត់នេះធ្វើឲ្យខ្ញុំគិតសាឡើងវិញ ប៉ុន្តែនៅទីបំផុតខ្ញុំក៏សម្រេចចិត្តធ្វើពិព័រណ៍ខ្មែរក្រហមនៅទួលស្លែង ។ គោលបំណងនៃការធ្វើពិព័រណ៍នេះគឺខ្ញុំចង់ប្រាប់ឲ្យពិភពលោកដឹងអំពីរបបខ្មែរក្រហម ។ ខ្ញុំចង់រកជនណាម្នាក់ដែលធ្លាប់ជាឃាតករសម្លាប់មនុស្សយ៉ាងសាហាវបំផុតនៅក្នុងរបបខ្មែរក្រហម ប៉ុន្តែខ្ញុំមិនចង់បង្ហាញអំពីការសម្លាប់មនុស្សរបស់គេទេ គឺខ្ញុំបង្ហាញត្រឹមតែជីវិតរបស់គេជាមួយក្រុមគ្រួសារនិងញាតិជិតខាងរបស់គេតែប៉ុណ្ណោះ ។

ពិព័រណ៍របស់ខ្ញុំធ្វើចាប់ផ្តើមនៅខែវិច្ឆិកា ឆ្នាំ២០០២ ។ ខ្ញុំបានទទួលការសរសើរយ៉ាងច្រើនពីអ្នកមកមើលពិព័រណ៍នេះ ។ មានអ្នកខ្លះនិយាយថា «ស៊ីនិត្យអើយ រូបថតនេះមានលក្ខណៈជាគ្រួសារណាស់» ។ ក្រោយពីហ្នឹងមក អង្គការសហប្រជាជាតិក៏ងាកមកចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជាវិញអំពីរឿងតុលាការខ្មែរក្រហម ហើយក៏ឈានដល់ការចុះហត្ថលេខារវាងលោក ហេន កូរែល និងឯកឧត្តម សុខ អាន លើកិច្ចព្រមព្រៀងកាលពីខែមិថុនាកន្លងទៅថ្មីៗនេះ ។

ខ្ញុំមានគម្រោងទៅប្រទេសដាណឺម៉ាកមុនថ្ងៃទី១៥ ខែកញ្ញានេះដើម្បីទៅប្តូរបទពិសោធន៍ជាមួយនិស្សិតដាណឺម៉ាក ។ អ្វីដែលខ្ញុំនឹងនិយាយនៅទីនោះ ទីមួយគឺរឿងខ្មែរក្រហម ទីពីរខ្ញុំនឹងនិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ហើយអ្វីដែលខ្ញុំសង្ឃឹមថានឹងបានទទួលពីប្រទេសដាណឺម៉ាកមកវិញគឺបច្ចេកវិទ្យាថ្មីៗដែលខ្ញុំអាចយកមកអភិវឌ្ឍន៍ក្នុងវិជ្ជាជីវៈរបស់ខ្ញុំតទៅទៀត ។ ខ្ញុំសប្បាយចិត្តណាស់ព្រោះខ្ញុំគិតថាដំណើរទៅដាណឺម៉ាកលើកនេះគឺជាជោគជ័យរបស់ខ្ញុំ ។ ប្រសិនបើខ្ញុំបាននិយាយជាមួយថ្នាក់ធំៗរបស់ដាណឺម៉ាក ខ្ញុំនឹងសុំឲ្យគេជួយជំរុញឲ្យដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមប្រព្រឹត្តទៅឲ្យបានលឿនបំផុត ព្រោះខ្ញុំមិនចង់បានឯកសារយកទៅឆ្លើយនៅក្នុងតុលាការទេ ខ្ញុំចង់បានមនុស្សឲ្យទៅឆ្លើយនៅចំពោះមុខតុលាការ ។

តាំងពីមុនមកក៏ដូចជាបច្ចុប្បន្ន និងទៅថ្ងៃអនាគតខ្ញុំចង់ឲ្យខ្លួនឯងត្រូវបានពិភពលោកទទួលស្គាល់ថា «*He is Cambodian, Heng Sinith Photographer*» ខ្ញុំចង់បានពាក្យមួយម៉ាត់ហ្នឹងពីពិភពលោក ។ អ្វីដែលខ្ញុំប្រឹងប្រែងរាល់ថ្ងៃគឺខ្ញុំចង់បានប៉ុណ្ណឹង ។ លើសពីនេះទៀតខ្ញុំសង្ឃឹមថា អនាគតប្រទេសកម្ពុជានឹងមានរដ្ឋាភិបាលដែលមិនប្រដែងគ្នាដូចសព្វថ្ងៃនេះ ។ **ហេង ស៊ីនិត្យ**

# ភ្ជុំបិណ្ឌរំឭកដល់អ្នកស្លាប់ក្នុងរបបខ្មែរក្រហម

ពិធីបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌប្រារព្ធឡើងក្នុងរយៈពេលកន្លះខែក្នុងមួយឆ្នាំ គឺចាប់ពីថ្ងៃទី១រោច ដល់ថ្ងៃទី១៥រោច ខែភទ្របទ នៃចន្ទគតិ ។ ប្រជាជនយកម្ហូបម្ហា នំចំណី ផ្លែឈើ ថ្នាំសង្កូវទៅប្រគេនព្រះសង្ឃនៅទីវត្តអារាម ដើម្បីឧទ្ទិសកុសលផលបុណ្យទៅឲ្យញាតិទាំង៧សន្តានដែលបានធ្វើមរណកាលទៅហើយ ។ នៅក្នុងគម្ពីរនៃព្រះពុទ្ធសាសនា ពិធីបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌធ្វើឡើងដើម្បីផ្តល់ម្ហូបអាហារដល់អ្នកដែលបានស្លាប់ទៅ ។ ក្នុងអំឡុងពេលនេះ យមរាជបានដោះលែងព្រលឹងខ្មោចទាំងឡាយឲ្យមកទទួលយកម្ហូបអាហារដែលញាតិសន្តានបានឧទ្ទិសឲ្យ ។ ព្រលឹងខ្មោចទាំងអស់បានឡើងមកឋានកណ្តាល ហើយទទួលអានិសង្សម្ហូបអាហារពីក្រុមគ្រួសារ ចំណែកព្រលឹងខ្មោចណាដែលគ្មានក្រុមគ្រួសារញាតិសន្តានធ្វើបុណ្យឲ្យទេ បានត្រាច់រង្កត់ពីវត្តមួយទៅវត្តមួយដោយសេចក្តីស្រេកឃ្លាន ហើយទទួលរងទុក្ខវេទនាវិលវល់ទៅតាមយថាកម្មរបស់ខ្លួន ។

ពិធីបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌនៅឆ្នាំនេះត្រូវនឹងថ្ងៃទី១១ ដល់ថ្ងៃទី២៥ ខែកញ្ញា ស្របពេលដែលប្រទេសកម្ពុជាកំពុងរៀបចំបង្កើតរដ្ឋាភិបាលថ្មីដែលត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតជាតិកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ ហើយក៏ជាពេលវេលាដែលប្រជាជនកម្ពុជាកំពុងតែទន្ទឹងរង់ចាំតុលាការអន្តរជាតិមួយដែលនឹងត្រូវបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាជនជាង ១លាន៧សែននាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ប្រជាពលរដ្ឋដែលយកចង្ហាន់ទៅវត្ត ក្រៅអំពីឧទ្ទិសដល់បុព្វបុរសជីដូនជីតា ក៏មិនដែលភ្លេចរំឭកដល់សាច់ញាតិដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមឡើយ ។ សម្រាប់ប្រជាជនខ្មែរ បុណ្យភ្ជុំបិណ្ឌគឺជាពេលវេលាដ៏សំខាន់បំផុតដែលគាត់នឹកឃើញដល់អ្នកស្លាប់ ។ ដោយសារជំនឿដ៏មុតមាំចំពោះព្រះពុទ្ធសាសនា ប្រជាជនកម្ពុជាជឿជាក់ថា កុសលផលបុណ្យដែលគាត់បានធ្វើពិតជាជួយឲ្យព្រលឹងជនរងគ្រោះក្នុងរបបខ្មែរក្រហមរួចចាកផុតអំពីទុក្ខលំបាកវេទនា ភាពអត់ឃ្លាន ការឈឺចាប់ដោយទារុណកម្ម និងពលកម្មបាក់កម្លាំងដែលអ្នកទាំងនោះធ្លាប់បានទទួលរងកាលពីរបបខ្មែរក្រហម ។

លោកយាយ កែវ អុប អាយុ៧៣ឆ្នាំ ដែលកំពុងតែពូនភ្នំអង្ករនៅវត្តមហាមន្ត្រី បានមានប្រសាសន៍ថា យាយមកវត្តធ្វើ


រាប់បាត្របញ្ជូនមគ្គផលដល់អ្នកស្លាប់


កែវ អុប

បុណ្យដើម្បីឧទ្ទិសមគ្គផលទៅឲ្យញាតិទាំងប្រាំពីរសន្តានដែលបានស្លាប់ទៅជាពិសេសប្តីរបស់យាយនិងកូន១០នាក់ដែលបានស្លាប់ដោយអត់អាហារនៅក្នុងរបបខ្មែរក្រហម ។ ដោយមិនអាចទប់ទឹកភ្នែកបាន យាយនិយាយថា “កូនខ្ញុំពេលដែលជិតស្លាប់ វាថាម៉ែអើយម៉ែ មុននឹងស្លាប់ទៅបើបានបាយតែមួយស្លាបព្រាក៏កូនអស់ចិត្តហើយ ។ វាស្រែករកបាយរហូតដល់ដង្ហើមចុងក្រោយ ។ ខ្ញុំខ្លោចចិត្តអាណិតកូនខ្ញុំណាស់ ។ សព្វថ្ងៃនេះខ្ញុំខំធ្វើបុណ្យបញ្ជូនកុសលទៅឲ្យ មិនថាបុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំ បច្ច័យបួន បុណ្យផ្កា សង្ឃទាន ឬក៏បុណ្យអ្វីផ្សេងទៀតទេ ។ ខ្ញុំសង្ឃឹមថាកូននិងប្តីខ្ញុំនឹងបានរួចផុតពីទុក្ខវេទនា រំដោះកម្មរំដោះពៀរ ជាតិក្រោយកុំឲ្យជួបនឹងការអត់ឃ្លានទៀត” ។ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសាររបស់ យាយអុប ពីស្រុកកៀនស្វាយ ខេត្តកណ្តាល ទៅរស់នៅក្នុងព្រៃដែលពោរពេញទៅដោយជំងឺគ្រុនចាញ់នៅភ្នំលាជ ខេត្តពោធិសាត់ ។ ខ្មែរក្រហមបានដាក់កំហិតឲ្យក្រុមគ្រួសាររបស់យាយ ដែលមានគ្នា១២នាក់ កាស់គុម្ពព្រេចឲ្យបាន១៥គុម្ពក្នុងមួយថ្ងៃ ហើយផ្តល់បបររាវកក្លុកចំនួនមួយចានតែប៉ុណ្ណោះក្នុងមួយពេលៗ ។ កូនៗនិងប្តីរបស់យាយបានកើតជំងឺហើម ហើយស្លាប់ជាបន្តបន្ទាប់ ។ ដោយមិនអាចអត់ទ្រាំនឹងភាពស្រេកឃ្លានបានកូនប្រុសម្នាក់របស់យាយបានលួចដាំបាយហូប ហើយត្រូវខ្មែរក្រហមចាប់ចងនឹងគល់ត្នោតអស់រយៈពេលមួយថ្ងៃមួយយប់ ។ រហូតមកដល់បច្ចុប្បន្ននេះគ្មានពេលណាដែលយាយភ្លេចមរណភាពរបស់ប្តីនិងកូនទាំង១០នាក់ឡើយ ។


នាង អួន

អ្នកមីង នាង អួន អាយុ៥៤ឆ្នាំ ដែលបានប្រគេនចង្ហាន់ដល់ព្រះសង្ឃនៅវត្តស្វាយពពែបានឲ្យដឹងថា ប្តីរបស់មីង ឪពុកក្មេក និងប្អូនថ្លៃត្រូវខ្មែរក្រហមសម្លាប់ដោយចោទថានាយទុន ។ ពេលដែលខ្មែរក្រហមយកប្តីរបស់មីងទៅសម្លាប់មីងកំពុងតែមានផ្ទៃពោះកូនទី២បាន៧ខែ ។ មីងដឹងថាប្តីឪពុកក្មេកនិងប្អូនថ្លៃរបស់មីងស្លាប់ទៅទាំងមិនអស់ចិត្តឡើយ ហើយព្រលឹងរបស់អ្នកទាំងអស់នោះពិតជានៅវិលវល់ពុំអាចទៅរកទីស្ងប់សុខបានទេ មីងខំធ្វើបុណ្យបញ្ជូនកុសលទៅដោយសង្ឃឹមក្នុងចិត្តថា នឹងអាចជួយរំដោះកម្មពៀរឲ្យអ្នកទាំងនោះបាន ។


អ៊ុក អ៊ិត

លោកតា អ៊ុក អ៊ិត អាយុ៧០ឆ្នាំ រស់នៅខេត្តស្វាយរៀង បានឲ្យដឹងថា ឪពុកម្តាយ និងប្អូនប្រុស២នាក់របស់គាត់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ លោកតាធ្វើចង្ហាន់មកប្រគេនព្រះសង្ឃក្នុងគោលបំណងឧទ្ទិសកុសលផលបុណ្យអ្នកទាំងនោះឲ្យបានរួចចាកផុតពីទុក្ខលំបាកវេទនាដែលធ្លាប់បានទទួលរងកាលពីពេលដែលនៅមានជីវិតរស់ ។ លោកតាសង្ឃឹមថាឪពុកនិងប្អូនប្រុសពិតជាបានទទួលមគ្គផលទាំងនោះជាមិនខាន ។


ម៉ៅ ឆេង

លោកយាយ ម៉ៅ ឆេង អាយុ៦៨ឆ្នាំ ដែលបានបាត់បង់ឪពុកបងប្រុសពីរនាក់ ប្អូនប្រុសម្នាក់ និងក្មួយបួននាក់នៅក្នុងរបបខ្មែរក្រហមបានមានប្រសាសន៍ថា គ្រប់ពេលវេលាដែលយាយធ្វើបុណ្យយាយមិនដែលភ្លេចរំឭកដល់អ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមឡើយ ។ ខ្មែរក្រហមនៅក្នុងស្រុកបាភ្នំ ខេត្តព្រៃវែងបានបង្ខំឲ្យបងនិងប្អូនប្រុសរបស់យាយអូសរទេះដឹកទំនិញជំនួសគោ ហើយបន្ទាប់មកក៏យកអ្នកទាំងនោះទៅសម្លាប់ចោល ។ យាយបន្ថែមថា ឪពុកនិងបងប្អូនរបស់យាយដែលស្លាប់ទៅមិនមែនមកអំពីកម្មពៀររបស់គាត់ទេ គឺមកពីអំពើឃោរឃៅរបស់ខ្មែរក្រហមតែម្តង ។

យាយ ណៃ ហ៊ាន អាយុ៦៤ឆ្នាំ រស់នៅខេត្តកំពង់ចាម បាននិយាយថា ប្តីរបស់យាយដែលត្រូវខ្មែរក្រហមសម្លាប់បានមកពន្យល់សប្តិយាយថា គាត់ទៅចាប់កំណើតថ្មីហើយ ។ យាយ

គ្រែកអរសាទរណាស់ដែលប្ដីទៅចាប់ជាតិថ្មី ប៉ុន្តែយាយនៅតែធ្វើបុណ្យឧទ្ទិសកុសលទៅឲ្យគាត់ ហើយសង្ឃឹមថាគាត់បានទៅចាប់កំណើតនៅកន្លែងល្អនិងមានសេចក្ដីសុខចម្រើន ។

ដោយសារការរង់ចាំយុត្តិធម៌ដែលមិនឃើញមកដល់អស់រយៈកាលដ៏យូរអង្វែង ប្រជាជនកម្ពុជាបានងាកទៅពឹងព្រះពុទ្ធសាសនាដើម្បីឲ្យចិត្តរបស់គាត់បានស្ងប់និងដើម្បីរំងាប់កំហឹងដែលគាត់មានចំពោះខ្មែរក្រហម ។ យាយ កែវ អុប និយាយថា «កាលពីមុនយាយមានបំណងសងសឹកឲ្យប្ដីនិងកូនរបស់យាយ ប៉ុន្តែឥឡូវនេះយាយលែងមានគំនិតនេះទៀតហើយ ព្រោះយាយសុំសីល ។ យាយចង់ដើរផ្លូវត្រង់ទៅមុខ មិនចង់រំឭកអតីតកាលទៀតទេ ។ យាយខំធ្វើបុណ្យឲ្យបានច្រើន ហើយសង្ឃឹមថាបុណ្យរបស់យាយនឹងជួយឲ្យព្រលឹងប្ដីនិងកូនរបស់យាយរួចចាកផុតពីភាពអត់ឃ្លាន ការលំបាកវេទនានិងបានទៅកាន់ទីស្ងប់សុខ ។»

លោកយាយ ម៉ៅ ឆេង មិនប្រាកដថាបុណ្យរបស់គាត់អាចជួយឲ្យព្រលឹងឪពុកនិងបងប្អូនរបស់គាត់បានស្ងប់ទេ ប៉ុន្តែគាត់នៅតែព្យាយាមធ្វើបុណ្យបញ្ជូនទៅឲ្យហើយសង្ឃឹមថាបុណ្យនេះនឹងជួយរំដោះកម្មពៀរបានខ្លះៗ ។

ទោះជាព្រះពុទ្ធសាសនាអាចធ្វើឲ្យប្រជាជនរំងាប់កំហឹងចំពោះខ្មែរក្រហមមែន ប៉ុន្តែគាត់នៅតែរង់ចាំយុត្តិធម៌មួយដែលអាចធ្វើឲ្យចិត្តគាត់ស្ងប់ជារៀងរហូត ។ អ្នកមីង នាង អូន និយាយថាឥឡូវនេះមីងមិនគុំកួនខ្មែរក្រហមទៀតទេ ព្រោះមីងកាន់សីល៥ហើយ ប៉ុន្តែមីងគ្រាន់តែចង់ឲ្យមានយុត្តិធម៌ចំពោះមរណភាពរបស់ប្ដីនិងសាច់ញាតិរបស់មីង ។ មីងចង់ឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដើម្បីឲ្យព្រលឹងប្ដីរបស់មីងបានស្ងប់ ។ មីងបន្ថែមថា បើសង្គមខ្មែរមិនមានយុត្តិធម៌ពេញលេញ កូនខ្មែរជំនាន់ក្រោយនឹងជួបការលំបាកវេទនាតទៅទៀតជាមិនខាន ។

សាច់ញាតិរបស់អ្នកទាំងប៉ុន្មានខាងលើនេះ នៅមានបងប្អូនធ្វើបុណ្យឧទ្ទិសកុសលទៅឲ្យ ចុះចំណែកជនរងគ្រោះដែលត្រូវខ្មែរក្រហមសម្លាប់ផុតពូជ ហើយគ្មានសាច់ញាតិនៅរស់ដើម្បីធ្វើបុណ្យឲ្យ តើអ្នកទាំងនោះរងទុក្ខវេទនាយ៉ាងណា? តើមេដឹកនាំខ្មែរក្រហមដែលកំពុងតែរស់នៅសព្វថ្ងៃមានធ្លាប់នឹកគិតដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ដោយស្នាដៃដ៏កំណាចឃោរឃៅរបស់ខ្លួនដែរឬទេ? តើការធ្វើបុណ្យដាក់បាត្រទាំងប៉ុន្មានអាចជួយឲ្យព្រលឹងជនរងគ្រោះស្ងប់បានដែរទេ?

**សាន់ កល្យាណ**

# តែងតែរស់នៅក្នុងបេះដូងនិងអារម្មណ៍

សេចក្ដីស្រលាញ់រវាងម្ដាយនិងកូនស្រីមានភាពជ្រាលជ្រៅណាស់ ។ សេចក្ដីស្រលាញ់មានឥទ្ធិពល ហើយមិនអាចរលាយសាបសូន្យបានទេ ទោះជាមានភាពមិនអនុគ្រោះក៏ដោយ ។ នៅប៉ុន្មានខែចុងក្រោយនាឆ្នាំ១៩៧៥ ដោយស្ថិតនៅក្នុងភាពបែកបាក់និរាសព្រាត់ប្រាសក្នុងក្រុមគ្រួសារ ជំ សារុន នៅសល់ម្ដាយនិងកូនស្រីម្នាក់ស្ថិតនៅក្នុងបន្ទុករបស់ខ្លួន ។ សារុន គឺជាសរសៃឈាមជីវិតសម្រាប់អ្នកទាំងពីរ ។ សារុន នេះហើយដែលជាអ្នកចេញទៅធ្វើការបង្កបង្កើនផលនៅហាលវាលហាលខ្យល់ ដឹកប្រឡាយនិងទៅរកត្រីនៅបឹងទន្លេសាប ខំលាក់លួចម្ហូបមកឲ្យគ្រួសារមានដូចជាខ្យងខ្ចៅ ទឹកត្នោត របបអង្ករបន្ថែម ចេក ផ្សិតចំបើងជាដើម ។ ក្នុងនាទីជាប្រធានក្រុម សារុន បានចែកចាយម្ហូបអាហារដល់ក្រុមរបស់ខ្លួនជាជាងយកទុកសម្រាប់ខ្លួនឯង លើកលែងតែចែកអស់ហើយនៅសល់ម្ហូបទៀតទើបគាត់យកទុក ។ ដើម្បីជាការការតបស្នង ក្រុមរបស់ សារុន ជួយលាក់បាំងទុកអាហារនៅតាមព្រៃ និងតាមវាលស្រែដើម្បីយកទៅចិញ្ចឹមម្ដាយដែលស្ទើររស់ស្ទើរស្លាប់និងកូនស្រីដែលកំពុងមានជំងឺនៅឯផ្ទះ ។ នៅក្រោមការគ្រប់គ្រងដ៏គ្មានឲ្យព្រឺខ្លាចរបស់ខ្មែរក្រហម ទោះបីជា សារុន ខិតខំប្រឹងប្រែងធ្វើការយ៉ាងណាក៏ សារុន មិនអាចផ្គត់ផ្គង់ម្ដាយ

និងកូនស្រីរបស់គាត់បានដែរ បើគ្មានការលាក់លួចរបស់របរ ហូបចុកបែបនេះទេ ។ នេះមានន័យថា កិច្ចខិតខំប្រឹងប្រែងធ្វើការរបស់ សារុន មិនអាចដូរនឹងការរស់រានមានជីវិតបានឡើយ ។

ម្តាយរបស់ សារុន ឈ្មោះ ធូ អម ធ្លាប់ធ្វើជាអ្នកដាំបាយឲ្យមហេសីរបស់ក្សត្រខ្មែរគង់នៅទីក្រុងភ្នំពេញ ។ មុនមកធ្វើជាអ្នកដាំបាយ លោកយាយជាអ្នកលក់ស្ករគ្រាប់នៅនៅផ្សារទីរួមខេត្តព្រៃវែង ក្រោយពេលដែលប្តីរបស់លោកយាយឈ្មោះ ដឺ សួម រត់ចោលគ្រួសារនៅឆ្នាំ១៩៥៣ ។ ការចាប់ផ្តើមជីវិតក្នុងលក្ខណៈមិនគួរបើបែបនេះ គឺជាការប្រសិទ្ធិពរទៅវិញទេ ពីព្រោះថាលោកយាយបានបំភ្លឺផ្លូវដល់កូនស្រីរបស់លោកយាយឈ្មោះ សារុន ។ សារុន បានទទួលការអប់រំខ្ពស់និងធំដឹងក្តីឡើងនៅក្នុងទីក្រុងតែម្តង ហើយលោកយាយបានធ្វើឲ្យ សារុន មានភាពរឹងមាំអាចឆ្លងកាត់ភាពព្រឺព្រួចក្រោមស្នាដៃខ្មែរក្រហមទៀតផង ។ លោកយាយបានបង្រៀនឲ្យ សារុន ចេះធ្វើស្រែ និងធ្វើឲ្យ សារុន ក្លាយជាអ្នកភូមិម្នាក់ប្រកបដោយសមត្ថភាពគ្រប់គ្រាន់ ។ លោកយាយបានបង្រៀនឲ្យ សារុន ចេះលាក់ប្រវត្តិខ្លួនដែលធ្លាប់បានសិក្សាជ្រៅជ្រះនៅសាលាដ៏ល្បីមួយនៅក្នុងទីក្រុងភ្នំពេញ ។

សារុន កើតនៅឆ្នាំ១៩៥០ ។ នៅឆ្នាំ១៩៥៦ សារុន និងបងប្អូនប្រុសពីរនាក់របស់ សារុន បានមករួមរស់ជាមួយម្តាយនៅទីក្រុងភ្នំពេញ ។ បងប្រុសទាំងពីរនាក់ស្ថិតក្រោមការចិញ្ចឹមបីបាច់ពីសំណាក់គ្រួសារក្សត្រ ហើយទោះបីជាម្តាយមានឋានៈសង្គមខុសគ្នាក៏ដោយ ក៏អ្នកទាំងបីបានរៀនសូត្រនិងបញ្ចប់ការសិក្សានៅសាលារៀនដែលសិស្សស្ទើរទាំងអស់សុទ្ធតែមកពីវណ្ណៈខ្ពង់ខ្ពស់ ។ ក្រោយនៅសាលាបឋមសិក្សា សារុន ទទួលបានវិញ្ញាបនប័ត្រចំនួនបីបញ្ជាក់ពីកិច្ចការរបស់ខ្លួននៅវិទ្យាល័យ ។ បួនឆ្នាំក្រោយមក សារុន ទទួលបានសញ្ញាប័ត្រឌីប្លូម ហើយមួយឆ្នាំក្រោយមកទៀតទទួលបានសញ្ញាប័ត្របាក់អង ។ នៅឆ្នាំ១៩៦៨ សារុន ទទួលបានសញ្ញាប័ត្របាក់ឌុប ។ សារុន គឺជាសិស្សពូកែម្នាក់ក្នុងសាលា ។ ឆ្នាំ១៩៦៩ សារុន ចូលរៀននៅមហាវិទ្យាល័យគរុកោសល្យនិងមហាវិទ្យាល័យច្បាប់ ។ បងប្រុសច្បងរបស់ សារុន ជាអ្នកបច្ចេកទេសនៅរោងចក្រស្ករស ចំណែកប្អូនប្រុសវិញជាអ្នកបច្ចេកទេសតម្លើងស្ពាន ។

សារុន បានបន្តការសិក្សារហូតដល់បញ្ចប់វគ្គគរុកោសល្យ ។ នៅឆ្នាំ១៩៧០ ទើប សារុន ព្រមរៀបការតាមប្រពៃណីជាមួយកូនកម្លោះចៅចិនម្នាក់ឈ្មោះ តាំង ហាក់ឃុន ដែលគាមស្រលាញ់នាងអស់បីឆ្នាំមកហើយ ។ សារុន មិនបានស្រលាញ់បុរសម្នាក់នោះទេ ប៉ុន្តែដោយសារតែម្តាយគាត់និយាយថា «កូនគ្រួសារយើងមិនមាននឹងគេទេ ហើយម្តាយនៅតែម្នាក់ឯងទៀត» ។

តាំង ហាក់ឃុន គឺជាកម្លោះបិតក្នុងត្រកូលអ្នកមានមួយដែលរៀនសូត្របានជ្រៅជ្រះផ្នែកគ្រប់គ្រងពាណិជ្ជកម្មនៅទីក្រុងប៉េកាំងនិងនៅទីក្រុងហុងកុង ។ ក្រោយពីបញ្ចប់ការសិក្សា ហាក់ឃុន បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ គ្រប់គ្រងរបរជំនួញមួយជាច្រើនដែលជាភាគទុនរបស់គ្រួសារខ្លួន ដូចជាភោជនីយដ្ឋានកុកម៉េង ហាងលក់ទឹកអប់ ហាងលក់សម្លៀកបំពាក់ និងហាងលក់គ្រឿងអលង្ការ ។ ហាក់ឃុន បានស្រលាញ់ សារុន ឯប់តែម្តង ។ ប៉ុន្តែដោយភាពប្រច័ណ្ឌនិងការពារគ្រប់ជំហាន ហាក់ឃុន បានប្រើអំណាចជាប្តីរារាំងដល់បំណងរបស់ សារុន ជានិច្ច ។ ហាក់ឃុន មិនចង់ឲ្យ សារុន ធ្វើការ មិនចង់ឲ្យទៅរៀន មិនចង់ឲ្យចេញទៅក្រៅឡើយ ។ ដើម្បីធ្វើឲ្យ ហាក់ឃុន សប្បាយចិត្ត សារុន ចាប់ផ្តើមបំពេញកិច្ចការក្នុងក្របខ័ណ្ឌជំនួញអាហារណ៍នីហរណ៍របស់ ហាក់ឃុន តែម្តង ប៉ុន្តែនាងមិនព្រមបញ្ឈប់ការសិក្សាឡើយ ។ នៅឆ្នាំ១៩៧១ សារុន បានបង្កើតកូនប្រុសមួយឈ្មោះ សំបុត្រ ។ មួយឆ្នាំក្រោយមកកើតបានកូនស្រីមួយទៀតឈ្មោះ ពេជ្រ ចាន់មុន្នី ។ កូនស្រីតូចច្រឡឹងរបស់ សារុន រពឹស ហើយចេះណាស់ ។ ប្រាំឆ្នាំក្រោយមកនាងបានស្លាប់នៅក្នុងដៃរបស់ សារុន ដោយពោលពាក្យចុងក្រោយចេញពីអង្រឹងប្រាប់ម្តាយថា «ម៉ែកូនឃ្លានបាយណាស់» ។

សារុន នឹងត្រូវទទួលសញ្ញាប័ត្រពីមហាវិទ្យាល័យគរុកោសល្យនិងមហាវិទ្យាល័យច្បាប់ នៅឆ្នាំ១៩៧៥ ជាឆ្នាំដែលពួកខ្មែរក្រហមចូលមកដល់ ។ បងប្អូនប្រុសរបស់ សារុន និងភរិយារបស់ខ្លួនបានចាកចេញពីផ្ទះដើម្បីគេចពីការទម្លាក់គ្រាប់បែក ។ នៅពេល «រំដោះ» មកដល់ក្រុមគ្រួសារ សារុន ស្ថិតនៅក្រោមដំបូលតែមួយមានតាំងពីម្តាយ បងប្អូនប្រុស បង-ប្អូនស្រីថ្លៃ ប្តី កូនប្រុសនិង

កូនស្រីសារុន ។ អ្នកទាំងអស់ត្រូវខ្មែរក្រហមជម្លៀសទៅកាន់ភូមិកំណើតរបស់ម្តាយ សារុន នៅភូមិកំពង់ក្រសាំង ។ បីខែក្រោយមក ខ្មែរក្រហមបានយកប្អូនប្រុសរបស់ សារុន ទៅសម្លាប់ចោលនៅវត្តកោកកាក ដោយសារតែគាត់ជាអ្នករដ្ឋការនៅក្នុងរបបលន់ណុល ហើយបានបន្សល់ទុកនូវភរិយាមានផ្ទៃពោះឲ្យនៅមេម៉ាយ ។ មរណភាពប្អូនប្រុសរបស់ សារុន គឺជាសញ្ញាដំបូងនៃការបាត់បង់សមាជិកគ្រួសាររបស់ សារុន ចាប់ពីប្រាំបួននាក់មកនៅបួននាក់ ចាប់ពីបួននាក់មកនៅត្រឹមពីរនាក់ត្រឹមឆ្នាំ១៩៧៩ ។

ក្រោយពីប្អូនប្រុស សារុន ស្លាប់ទៅ ក្រុមគ្រួសាររបស់ សារុន ត្រូវខ្មែរក្រហមជម្លៀសមកតំបន់មួយនៅភាគខាងលិចនៃទីក្រុងភ្នំពេញ ។ បងថ្លៃស្រីរបស់ សារុន បានបាត់បង់ជីវិតដោយសារជំងឺអាសន្នរោគ ចំណែកឯប្អូនស្រីថ្លៃឆ្លងទន្លេបានកូនប្រុសមួយ ។ ក្រោយពីឆ្លងទន្លេហើយភ្លាម ខ្មែរក្រហមជម្លៀសចេញពីគ្រួសារនេះទៀត ។ កូនប្រុសរបស់ សារុន ដែលមានអាយុទើបតែ៦ឆ្នាំក៏ត្រូវបំបែកឲ្យទៅធ្វើការក្នុងកងកុមារ ។ ក្រោយពេលខ្មែរក្រហមបំបែកក្រុមគ្រួសាររបស់ សារុន បានពីរបីខែ ប្តីរបស់ សារុន បានលេបថ្នាំស្លែងសម្លាប់ខ្លួន ។ ការធ្វើអត្តឃាតនេះគឺដោយសារ ហាក់យុន ទ្រាំទ្រការលំបាកមិនបាន ព្រោះខ្លួនធ្លាប់តែជាមនុស្សដែលមានលុយ រៀនសូត្របានជ្រៅជ្រះ ដល់ពេលស្ថិតក្នុងស្ថានភាពបែបនេះ ហាក់យុន គិតថាគាត់ពិតជាគ្មានលទ្ធភាពមើលថែទាំគ្រួសាររបស់គាត់បានឡើយ ។ ដូចជានៅពេលដែលកងទ័ពខ្មែរក្រហមធ្វើបាបប្រពន្ធគាត់ដោយវាយនឹងជ្រលួញគោ ពេលនោះរាងកាយរបស់គាត់មានតែស្បែកដណ្តប់ឆ្អឹង គាត់គ្មានកម្លាំងកំហែងមកជួយប្រពន្ធបានឡើយ ។ ម្យ៉ាងទៀតដោយសារគាត់ខ្មាសនឹងខ្លួនឯងដែលមិនព្រមជឿតាមសម្តីប្រពន្ធគាត់ ដែលទទូចសុំឲ្យគាត់នាំគ្រួសារទៅរស់នៅក្រៅប្រទេស ព្រោះថាសភាពការណ៍នៅក្នុងប្រទេសកម្ពុជានឹងក្លាយជាប្រទេសកុម្មុយនិស្ត ។

ឈាមរបស់ សារុន ដែលហូរមកដោយសារខ្មែរក្រហមវាយ មានកម្រិតតិចជាងឈាមដែលហូរចេញពីមាត់របស់ប្តីនាង ក្រោយពេលលេបគ្រាប់ស្លែងសម្លាប់ខ្លួន ។

នៅឆ្នាំ១៩៧៦ បងប្រុសរបស់ សារុន បាត់បង់ជីវិត ។ សារុន បានពន្យល់ជាភាសាអង់គ្លេសថា «ដោយសារគ្មានបាយហូបជាធម្មតាបុរសហូបបាយច្រើន ដល់ទៅគ្មានបាយហូបគ្រប់គ្រាន់នាំឲ្យគ្មានកម្លាំង មានតែស្បែកដណ្តប់ឆ្អឹង ស្គមសែនស្គម ធ្វើការបាក់កម្លាំងរហូតដល់ស្លាប់ ។ មិនមែនតែគ្រួសាររបស់ខ្ញុំទេ គ្រប់គ្រួសារទាំងអស់ គ្រួសារណាក៏ដូចគ្រួសារណាដែរ» ។

សារុន នៅសល់ម្តាយនិងកូនស្រីម្នាក់នៅក្នុងបន្ទុក ។ ព្រឹកម៉ោង៣ សារុន ចេញទៅធ្វើការបាត់ទុកកូនឲ្យម្តាយមើល ។ ក្រុមការងាររបស់សារុន ទទួលបន្ទុកខាងដកស្ទូងលើកប្រឡាយ ឬទៅរកត្រីនៅទន្លេសាបរហូតដល់ម៉ោង១២ ទើបសម្រាកហូបបាយថ្ងៃត្រង់ ។ ដល់ម៉ោង១ៈ៣០នាទី ឬម៉ោង២រសៀល ចាប់ផ្តើមចូលធ្វើការវិញ ធ្វើរហូតដល់ថ្ងៃលិច ។ ជួនកាលបន្តធ្វើការរហូតដល់ពាក់កណ្តាលយប់ ដោយបញ្ឆេះម៉ាស៊ីនភ្លើងបំភ្លឺ ។ ពេលហូបបាយល្ងាច សារុន តែងតែបេះអាហារពីមាត់ពីកខ្ចប់ស្លឹកឈូកទុកសម្រាប់ផ្តល់ទៅឲ្យម្តាយនិងកូនស្រីនៅឯមូលដ្ឋាន ។ ផ្លូវទៅកាន់មូលដ្ឋាននោះគឺពោរពេញទៅដោយផ្នូរខ្មោច ។ សារុន និយាយថា «ប៉ុន្តែខ្ញុំលែងខ្លាចខ្មោចទៀតហើយ គឺខ្លាចអត់បាយហូបនិងខ្លាចកងទ័ពខ្មែរក្រហមតែប៉ុណ្ណោះ» ។ នៅពេលយប់ឡើងឃើញចង្កៀងផុងៗ ដូចជាកន្ទុយបារីរបស់កងទ័ពខ្មែរក្រហមអ៊ីចឹង ។ សាកសពកប់ក្នុងផ្នូររាក់ៗ ជួនកាលឆ្កែព្រៃមកកកាយខាំពាំចេញក្រៅ ។ ជួនកាលឃើញជើងសាកសពឆ្កែកំពុងតែអង្កៀមនិងសត្វល្អិតរោមពេញ ។ សាកសពទាំងនេះបញ្ចេញក្លិនស្អុយអសោច ។ ទឹកផឹកក៏ពុំសូវ សូម្បីតែកាកសំណល់សាកសពដែលប្រឡាក់ជើងគាត់ក៏គ្មានទឹកលាងដែរ ។

នៅឯសហករណ៍ សារុន ដាំបាយជូនម្តាយ និងកូនស្រីនៅពេលបានហូបបាយជុំគ្នាម្តងៗអ្នកទាំងបីសប្បាយចិត្តណាស់ ។ ហូបបាយរួច សារុន ត្រូវរត់ទៅដងទឹកដាក់បំពង់ចម្ងាយជិតពីរ-បីគីឡូម៉ែត្រពីផ្ទះទុកឲ្យម្តាយនិងកូន ។ បន្ទាប់មក សារុន ត្រូវរត់ត្រឡប់ទៅកន្លែងធ្វើការវិញ ។ ជួនកាលយប់ខ្លះ សារុន មិនបានដេកទៀតផង ។

សារុន និយាយថាម្តាយគាត់អាចរស់នៅបានយូរដោយសារ

តែគាត់មានសល់គ្រឿងអលង្ការ ។ នៅវេលាម៉ោងប្រមាណជា ៣ឬ៤ភ្លឺ សារុន លបលួចចុះទៅរកអាហារនៅតាមសហគមន៍ ឥស្លាមដែលមានចម្ងាយប្រមាណ១២គីឡូម៉ែត្រពីផ្ទះ ។ សារុន បានយកគ្រឿងអលង្ការមកដូរយកអង្ករ ស្ករអំពៅ និងចេក ។ បន្ទាប់មក សារុន ត្រូវលួចយកចេញពីសហករណ៍ជាមួយនឹង អលង្ការដែលវេចខ្ចប់នឹងជាយក្រមាលាក់នៅក្នុងអាវខ្មៅរបស់ នាង ។ សារុន មានបំពង់មួយនៅជាប់ខ្លួនជានិច្ច ទុកគ្រាន់ដាក់ ក្តាមខ្យង ។ ពីរគីឡូម៉ែត្រខាងលិចមូលដ្ឋាន មានផ្លូវរទេះភ្លើង វ័ណ្ឌចែកទិដ្ឋភាពជាពីរចំណែក ដោយមានកងទ័ពខ្មែរក្រហមនៅ យាមជាក្រុមៗ ។ ជួនកាល សារុន ត្រូវរង់ចាំអស់រយៈពេលពីរ ឬបីម៉ោងទម្រាំតែបានឆ្លងរួច ។ សារុន និយាយថា «ខ្ញុំធ្វើតែ ម្នាក់ឯង ខ្ញុំជឿនិងទុកចិត្តតែលើខ្លួនខ្ញុំម្នាក់ប៉ុណ្ណោះ ពីព្រោះខ្ញុំអាច រក្សាជីវិតរបស់ខ្ញុំមកដល់សព្វថ្ងៃនេះ» ។

នៅរាត្រីដែលម្តាយបាត់បង់ជីវិត សារុន បានវិលត្រឡប់ មកពីសហគមន៍ជនជាតិឥស្លាមវិញ ដោយនាំមកនូវអង្ករ ស្ករ អំពៅនិងចេកដើម្បីចិញ្ចឹមម្តាយដែលស្ថិតក្នុងសភាពទន់ខ្សោយ ។ ម្តាយរបស់ សារុន សម្រាននៅលើគ្រែសណ្តូកជើងទៅលិច ដោយមានចៅទូត ចៅ និងជីដូនម្នាក់ នៅអង្គុយជុំវិញ ។ នៅពេល អ្នករាល់គ្នាលង់លក់ក្នុងដំណេកអស់ហើយ សារុន ចាប់ផ្តើម សម្រក់ទឹកភ្នែកនៅចំពោះម្តាយ ។ ម្តាយរបស់ សារុន បាននិយាយ ថា «កុំស្តាយរបស់របរមានតម្លៃធ្វើអ្វី ។ យើងអាចទិញរបស់បាន ប៉ុន្តែមិនអាចទិញជីវិតបានឡើយ ។ នៅពេលយើងស្លាប់ យើងមិន អាចយករបស់ទៅជាមួយយើងបានឡើយ ។ ឯងត្រូវតែលក់របស់ របរទាំងអស់ដើម្បីសង្គ្រោះជីវិត» ។

លោកយាយពោលថា «ចូលដេកទៅកូន ។ កូនខំធ្វើការ ណាស់ សល់ពេលតែកន្លះម៉ោងទៀតតែប៉ុណ្ណោះ ដល់ពេលចេញ ដំណើរទៅធ្វើការទៀតហើយ ។ ចូលដេកទៅកូន ។ មិនចាំបាច់ចាំ មើលម៉ែទេកូន ។ មានមនុស្សគេមកមើលម៉ែច្រើនហើយ» ។

លោកយាយពោលពាក្យចុងក្រោយមករក សារុន ថា «កុំរ៉ៃកូនណា៎ ។ ថ្នមកូនឲ្យស្រួលបួលណា៎» ។ លោកយាយនិយាយ យ៉ាងដូចនេះពីព្រោះកូនស្រី សារុន កើតឆ្នាំកុរ កើតនៅថ្ងៃដូចគ្នា ខែដូចគ្នាជាមួយនឹងប្អូនប្រុសពៅរបស់ សារុន ដែលលង់ទឹកស្លាប់ នៅពេលមានអាយុបាន៦ឆ្នាំ ។ ពេលនោះ ពេជ្រ ចាន់មុន្នី មាន អាយុជិត៦ឆ្នាំហើយ ។ ម្តាយរបស់ សារុន ជឿថាចៅ ចាន់មុន្នី គឺកូនប្រុសពៅគាត់មកចាប់ជាតិ ទើបគាត់បារម្ភអំពីវាសនារបស់ ចៅស្រីមុន្នី ណាស់ ។

ក្រោយពេលម្តាយស្លាប់ទៅ សារុន ត្រូវស្ពាយកូនស្រី ដាក់នៅពីក្រោយខ្នងដើម្បីទៅធ្វើការជាមួយ ។ កូនស្រីរបស់ សារុន ស្គមស្គាំងស្បែកដណ្តប់ឆ្អឹង មិនអាចដើររួចទេ ។ មុនស្លាប់ មួយយប់ ពេជ្រ ចាន់មុន្នី ទទូចសុំស្ករហូប ។ សារុន ក៏ឡើងដើម ត្នោតចងក្រម៉ានឹងចង្កេះ ដាក់កាំបិតមួយនិងបំពង់មួយទៅត្រង់ទឹក ត្នោត ។ សារុន យកទឹកត្នោតមករំងាស់ធ្វើជាស្ករ ហើយដាំបបរ ស្ករពោត ។ សារុន ចម្អិនអាហារបែបនេះដើម្បីជួយសម្រាលជំងឺ ហើមជើងរបស់កូនស្រី ។ ថ្ងៃបន្ទាប់មក មេឃបង្អុរភ្លៀងយ៉ាងធំ ឥតដាច់ កូនស្រីរបស់ សារុន ដេកនៅក្នុងអង្រឹងផ្សេង ។ ដោយ សារការអស់កម្លាំង ស្រេកឃ្លាន អារម្មណ៍ទុក្ខសោកនិងភ័យខ្លាច សារុន ក៏លង់លក់ក្នុងអង្រឹងដោយមិនដឹងខ្លួន ។ មុន្នី បានស្រែក ហៅម្តាយថា «ម៉ែខ្ញុំចង់ដេកជាមួយម៉ែឯង» ។ សារុន ស្ទុះក្រោក ឡើងពីអង្រឹងទៅបីកូនស្រីមកដេកនៅលើទ្រូងខ្លួន ។ ពីរម៉ោង ក្រោយ កូនស្រី សារុន ក៏ដាច់ខ្យល់ស្លាប់ទៅ ។

សារុន ទទួលបានច្បាប់អនុញ្ញាតឲ្យឈប់មួយថ្ងៃដើម្បីបញ្ចុះ សពកូនស្រី ។ ក្រោយមក សារុន ត្រូវបញ្ជូនចេញពីសហករណ៍ទៅ ធ្វើការខាងក្រៅ ។ ចេញពីការស្លាប់របស់កូនស្រី សារុន បាននិយាយ បន្តថា ជួនកាលពេលដែលកូនហៀបនឹងស្លាប់គ្រួសារនោះមិន ប្រាប់អ្នកផ្សេងឡើយ ដើម្បីបានទទួលរបបអាហារបន្តទៀត ។ នៅពេលកូនស្លាប់ហើយ គេយកកូនទៅកាប់ចិញ្ច្រាំធ្វើជាម្ហូប ដោយភូតថាបានមកពីពោតនិងសាច់សត្វដើម្បីដូរយកបាយនិង ម្ហូបផ្សេងវិញ ។ បីឬបួនខែក្រោយពី មុន្នី ស្លាប់ គឺជារដូវច្រូត កាត់ ម្នាក់ៗមានបាយហូបគ្រប់គ្រប់ៗគ្នា ។ ប្រសិនបើ មុន្នី ទ្រាំ រស់បានដល់រដូវច្រូតកាត់នេះវិញ ម្ល៉េះនាងមិនស្លាប់ទាំងវេទនា យ៉ាងដូច្នេះទេ ។

ប្រហែលជានៅខែមេសា ឆ្នាំ១៩៧៧ សារុន ត្រូវបាន

ផ្គូរផ្គងផ្សំផ្គុំជាមួយបុរសម្នាក់ឈ្មោះ ជឿត សារ៉ាត់ ។ សារុន និយាយថា «ដោយសារខ្ញុំគ្មានកូនដូចនេះ គេក៏ជ្រើសរើសឲ្យបុរសនោះរៀបការជាមួយខ្ញុំ ។ យើងត្រូវតែរៀបការដោយមិនដឹងបុរសនោះជានណាឡើយ» ។ មុនឆ្នាំ១៩៧៥ សារ៉ាត់ គឺជាទាហានលន់ ណុល ។ បុរសនោះបានរៀបការជាមួយប្អូនស្រីរបស់កងទ័ពខ្មែរក្រហមម្នាក់ ហើយបានបន្តជាបញ្ហា ។ សារ៉ាត់ ត្រូវចាប់ដាក់គុក ប៉ុន្តែគាត់អាចរត់រួចមកធ្វើការនៅសហករណ៍ជាមួយ សារុន ។ សារុន រំឭកថា «យើងនៅជាមួយគ្នាដូចជាបងនិងប្អូនអ៊ីចឹង ។ មិនដែលស្រលាញ់គ្នាទេ ។ គាត់និងខ្ញុំមិនដែលប៉ះគ្នាម្តងឡើយ ពីព្រោះខ្ញុំមិនសប្បាយចិត្ត ហើយអស់កម្លាំងទៀតផង» ។

នៅខែសីហា ឆ្នាំ១៩៧៧ សារុន សម្រេចចិត្តរត់គេចទៅជិតព្រំដែនថៃ ។ សារុន ធ្លាក់ខ្លួនឈឺដោយសារកង្វះអាហារូបត្ថម្ភ និងមានជំងឺគ្រុនចាញ់ ។ «ពេលនេះខ្ញុំដឹងខ្លួនថាខ្ញុំច្បាស់ជាស្លាប់ហើយ» ។ «ជួនកាលខ្ញុំមិនដឹងថាមានអ្វីនៅជុំវិញខ្លួនខ្ញុំឡើយ» ។ សារុន មិនអាចឈរ ឬអង្គុយបានឡើយ ។ សារុន នៅចងចាំសម្តីចុងក្រោយរបស់ម្តាយដែលផ្តែផ្តាំថា នាងគួរតែប្រើប្រាស់របស់របរមានតម្លៃដើម្បី «សង្គ្រោះជីវិត» ។ សារុន ក៏ចាប់ផ្តើមសាកចិត្តពេទ្យខ្មែរក្រហម ក្រែងអាចប្តូរយកថ្នាំនិងការគាំពារពីអ្នកទាំងនោះបាន ។ «ពេលខ្លះគេត្រូវការ ពេលខ្លះមិនត្រូវការទេ គេនឹងសម្លាប់យើងចោល ។ ខ្ញុំចេះតែសាកចិត្តគេមួយអាទិត្យជាពីរអាទិត្យ» ។ សារុន ឃើញនារីពេទ្យម្នាក់ពាក់គ្រឿងអលង្ការទោះបីជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមក៏ដោយ ។ «នារីពេទ្យនោះពាក់អលង្ការ ហើយស្រលាញ់ខ្លួនណាស់» ។ មានថ្ងៃមួយ សារុន និយាយទៅរកនារីពេទ្យនោះថា «ខ្ញុំជិតស្លាប់ហើយ ។ ខ្ញុំមានរបស់អនុស្សាវរីយ៍មួយទុកជូនបង ហើយនៅពេលខ្ញុំស្លាប់ បងយករបស់នេះជួលគេឲ្យយកសាកសពខ្ញុំទៅកប់នៅជិតផ្នូរម្តាយខ្ញុំផង» ។ តាមពិត សារុន គ្រាន់តែចង់ផ្តល់របស់របរទៅនារីពេទ្យសុំការគាំពារតែប៉ុណ្ណោះ ។ មុនដំបូងនារីពេទ្យបដិសេធ ។ សារុន និយាយប្រាប់នារីពេទ្យនោះថា ប្រសិនបើ ខ្ញុំនិយាយរឿងនេះសូមឲ្យនារីពេទ្យសម្លាប់នាងចោល ហើយយករបស់មានតម្លៃទៅចុះ ហើយប្រសិនបើមិនបាននិយាយទេ សូមឲ្យមិត្តនារីរក្សាទុកនូវរបស់មានតម្លៃនោះចុះ ។ សប្តាហ៍ក្រោយមក សារុន ទទួលបានថ្នាំហូបប្រសើរជាងមុន ហើយនៅចុងសប្តាហ៍ សារុន ត្រូវបានគេជ្រើសរើសនិងផ្ទេរទៅមន្ទីរពេទ្យធំនិងមានបំពាក់សម្ភារប្រសើរជាងមុន ។ ក្នុងចំណោមអ្នកជំងឺទាំង៧នាក់ដែលមកដេកនៅមន្ទីរពេទ្យនោះ មានតែ សារុន ម្នាក់គត់ដែលមិនមែនជាកម្មាភិបាលខ្មែរក្រហម ។ សារុន បានរំឭកថា «ខ្ញុំគិតថានារីពេទ្យនោះមិនមែនជាខ្មែរក្រហមពិតប្រាកដទេ ។ ជួនកាលគ្រួសារជាខ្មែរក្រហម ដូច្នេះកូនចៅចេះតែធ្វើតាមទៅ» ។

មន្ទីរពេទ្យដែលខ្មែរក្រហមផ្ទេរ សារុន ទៅនោះគឺគេទុកសម្រាប់យុទ្ធជនខ្មែរក្រហមតែប៉ុណ្ណោះ ។ វេជ្ជបណ្ឌិតសុទ្ធតែជាជនជាតិចិន ហើយអាហារមានហូបចុកគ្រប់គ្រាន់ ឆ្ងាញ់ជាងនៅសហករណ៍នានា ។ សារុន និយាយដោយលាយឡំនឹងសំណើចថា «ពេលដល់ទីនោះខ្ញុំក៏ជាសះស្បើយហើយស្រស់ស្អាតទៀតផង!» ។ សារុន និយាយថា ទីនោះហើយដែលនាងបានជោគជ័យ ។ និយាយដល់ត្រឹមនេះកែវភ្នែករបស់ សារុន ឡើងភ្លឺថ្លាបញ្ជាក់ថាគាត់ចង់និយាយរឿងរ៉ាវបន្ថែមនៅមន្ទីរពេទ្យដែលគាត់បានស្នាក់នៅ ។មន្ទីរពេទ្យនោះបែកចេញក្រុមៗដូចជាសហករណ៍ដែរ ។ ក្នុងចំណោម៧ក្រុម ក្រុមទីបីពុករលួយជាងគេបង្អស់ពោលគឺ «កំណាញ់ស្វិតណាស់» ។ ក្រុមនេះទទួលខុសត្រូវខាងគ្រប់គ្រងស្ត្រីមានផ្ទៃពោះ ។ ផ្ទុយទៅវិញបែរជាយកគ្រឿងផ្គត់ផ្គង់ប្រើប្រាស់ សម្រាប់ប្រយោជន៍ផ្ទាល់ខ្លួនទៅវិញ ។ ចាប់តាំងពីមកដល់មន្ទីរពេទ្យមក សារុន ខិតខំធ្វើការយ៉ាងប្រយ័ត្នប្រយែងខំលាក់ប្រវត្តិរៀនសូត្ររបស់ខ្លួនមិនឲ្យគេដឹង ដោយធ្វើដូចជាខ្លួនចេះត្រឹមតែអាន និងសរសេរអក្សរខ្មែរបន្តិចបន្តួចប៉ុណ្ណោះ ។ នេះគឺដល់ពេលដែល សារុន ប្រើចំណេះវិជ្ជារបស់ខ្លួនលាតត្រដាងអំពីអំពើពុករលួយម្តង ។ នៅលើសន្លឹកក្រដាសតូចៗ សារុន បានសរសេរជាសំបុត្រខ្លីៗ ថ្កោលទោសក្រុមទីបី ។ សារុន បានហុចកូនកំណត់ហេតុឲ្យកូនស្រីរបស់គ្រូពេទ្យដែលដេកជិតគាត់ ។ កូនស្រីរបស់គ្រូពេទ្យនោះក៏ហុចបន្តទៅឲ្យឪពុក ដោយមិនបានប្រាប់ថាអ្នកណាសរសេរឡើយ ។ កំណត់ហេតុបន្តបន្ទាប់ទៀតត្រូវ សារុន ហុចបន្តបន្ទាប់ដោយស្ងាត់ៗជុំវិញមន្ទីរពេទ្យ ។

មិនយូរប៉ុន្មានថ្នាក់ដឹកនាំក្រុមទីបីត្រូវដកចេញពីមន្ទីរពេទ្យ ហើយឲ្យទៅធ្វើការនៅសហករណ៍នានា ។ នៅពេលនិយាយដល់រឿងជោគជ័យនេះ សារុន ផ្ទុះសំណើចឡើង ។

បី-បួនខែក្រោយពីមកដល់មន្ទីរពេទ្យនេះ សារុន ត្រូវបានបញ្ជូនត្រឡប់ទៅសហករណ៍វិញ ។ ប៉ុន្តែ សារុន មិនបានទៅសហករណ៍ឡើយ ។ «ខ្ញុំរត់ចោលសហករណ៍ទៅមើលផ្ទះសពគ្រួសារខ្ញុំ ។ ខ្ញុំឃើញឆ្អឹងនៅលើគោក ប៉ុន្តែខ្ញុំមិនខ្លាចទេ» ។ សារុន មិនត្រឡប់ទៅធ្វើការនៅក្នុងក្រុមសហករណ៍វិញទេ តែនាងបែរជារត់សំដៅទៅផ្ទះរបស់កម្មាភិបាលនារីខ្មែរក្រហមម្នាក់ស្ថិតក្នុងមជ្ឈិមវ័យដែលធ្លាប់ធ្វើជាប្រធានក្រុមរបស់គាត់កាលពីមុន ។ សារុន និយាយថា «ក្នុងចំណោមមនុស្សមួយរយនាក់មានតែម្នាក់ឬពីរនាក់ប៉ុណ្ណោះដែលស្លូតបូត ។ គាត់ស្រលាញ់ខ្ញុំពីព្រោះខ្ញុំធ្វើការច្រើននិងខស្បាហ៍ព្យាយាម» ។ ប្រធានក្រុមនោះធ្លាប់បានពន្យល់ប្រាប់ សារុន របៀបទាក់ទងនិងរកផ្លូវទៅកាន់ផ្ទះគាត់ ប្រសិនបើមានការត្រូវរកជួបគាត់ ។ ទម្រាំតែទៅដល់បាត់ដំបង សារុន ខំរកផ្លូវអស់បីយប់បីបួនថ្ងៃ ប៉ុន្តែមុនពេលទៅដល់ផ្ទះរបស់កម្មាភិបាលនារីនេះ សារុន ត្រូវខ្មែរក្រហមឃាត់ខ្លួន ។ សារុន និយាយទៅកាន់កងទ័ពខ្មែរក្រហមថានាងជាកូនស្រីរបស់កម្មា-ភិបាលប្រធានក្រុមនោះ ហើយគាត់ប្រាប់នាងឲ្យមក ។ ប្រាប់យ៉ាងដូច្នេះកងទ័ពខ្មែរក្រហមក៏នាំ សារុន ទៅដល់ផ្ទះរបស់ប្រធានក្រុមនោះតែម្តង ។ ពេលទៅដល់ផ្ទះភ្លាមប្រធានក្រុមនោះក៏ចេញមកទទួលយក សារុន ដោយគ្មានភាពស្ទាក់ស្ទើរអ្វីឡើយ ។

មកដល់ឆ្នាំ១៩៧៨ សារុន ធ្វើការនៅក្នុងសហករណ៍មួយជិតបាត់ដំបង ។ ក្រោយមកគេផ្លាស់ទៅធ្វើការនៅភ្នំសំពៅជាមួយមិត្តភក្តិបីនាក់ទៀត ។ ក្រោយពេលរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ សារុន និងមិត្តភក្តិបីនាក់ កំពង់រស់នៅជាមួយគ្នានៅខេត្តបាត់ដំបង ។ មួយឆ្នាំក្រោយមក នៅពេលនាងសុំការងាររដ្ឋាភិបាលធ្វើ នាងក៏បានជួបមុខ សារ៉ាត់ម្តងទៀត ។ សារ៉ាត់ ចេះនិយាយភាសាវៀតណាមយ៉ាងស្ទាត់ជំនាញ ហើយត្រូវបានឋានន្តរស័ក្តិឲ្យធ្វើការជាមួយរដ្ឋាភិបាលដែលផ្តួចផ្តើមដោយប្រទេសវៀតណាម ។

ទោះបីជាកាលពីមុនអ្នកទាំងពីរមិនបានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធក៏ដោយ នៅពេលនេះអ្នកទាំងពីរបានសម្រេចចិត្តមករួមរស់ជាមួយគ្នាវិញចាប់ពីពេលនោះទៅ ។ នៅឆ្នាំ១៩៨០ កូនប្រុសរបស់ សារុន មករស់នៅជារួមគ្នា ។ សារុន បានបង្កើតបានកូនប្រុសមួយឲ្យស្វាមី ។ បីឆ្នាំក្រោយមកទៀត អ្នកទាំងពីរបានកូនប្រុសពៅមួយទៀត ។ នៅអំឡុងពេលនោះ សារុន ធ្វើជាគ្រូបង្រៀននៅសាលារដ្ឋមួយ ។ នៅឆ្នាំ១៩៨៧ សារុន បានក្លាយជានាយិកាវិទ្យាល័យ ។ នៅឆ្នាំ១៩៩៤ សារុន ផ្លាស់មកធ្វើការពេញម៉ោងឲ្យក្រុមហ៊ុនផលិតស្រាបៀរកម្ពុជាជាអ្នកគ្រប់គ្រងការលក់ស្រាបៀរ នៅតំបន់១ ។ សារុន ចូលចិត្តបង្រៀនណាស់ ។ សារុន មិនចូលចិត្តធ្វើការជាមួយប្រព័ន្ធពុករលួយឡើយ ។ សព្វថ្ងៃនេះ សារុន ធ្វើការពេញៗមួយថ្ងៃដើម្បីផ្គត់ផ្គង់ការសិក្សារបស់កូនៗរៀននៅសហរដ្ឋអាមេរិក ។

ក្នុងការរំពុកឡើងវិញនូវរឿងរ៉ាវជីវិតរបស់ សារុន បង្ហាញថា ម្តាយនិងកូនស្រីរបស់ សារុន មានសារសំខាន់ណាស់ចំពោះនាង ។ ម្តាយនិងកូនស្រីបាត់បង់តែរូបកាយ ប៉ុន្តែអ្នកទាំងពីរតែងតែរស់នៅក្នុងបេះដូងនិងអារម្មណ៍របស់ សារុន ជានិច្ច ប្រការនេះហើយដែលធ្វើឲ្យ សារុន នៅតែឈឺចាប់រហូត ។ សេចក្តីស្រលាញ់រវាងម្តាយនិងកូនស្រី គឺជាសេចក្តីស្រលាញ់ដ៏ជ្រាលជ្រៅ ហើយសេចក្តីស្រលាញ់នេះបានជំរុញឲ្យ សារុន បន្តជីវិតរស់តទៅទៀត ។ ពេញមួយជីវិតរបស់ សារុន ឆ្លងកាត់គ្រប់ឧបសគ្គទាំងអស់ គាត់ខំធ្វើការមិនដែលខ្លាចនឿយហត់ឡើយ ។ សារុន បានបដិសេធមិនព្រមឲ្យគេប្រើប្រាស់ឡើយ ប៉ុន្តែសេចក្តីស្រលាញ់របស់គាត់ចំពោះកូនស្រីនាំឲ្យគាត់ស្វាគមន៍ខ្ញុំ ដែលជាជនបរទេសចូលទៅក្នុងផ្ទះគាត់ ពីព្រោះ សារុនឃើញខ្មោចកូនស្រីគាត់នៅលើមុខរបស់ខ្ញុំ ។ សារុន ជាស្ត្រីរឹងមាំមួយរូបដែលខ្ញុំកម្របានជួបណាស់ ។ សារុន និយាយដោយផ្ទាល់ចំពោះខ្ញុំថា «បើគេធ្វើបាន ខ្ញុំក៏ធ្វើបាន ។ គេឡើងត្នោតបាន ខ្ញុំក៏អាចឡើងបាន ។ ទោះបីជាអាយុ៥៣ ឬ៥៤ក្តី ក៏ខ្ញុំអាចធ្វើបានដែរ ។ ខ្ញុំមិនខ្លាចទេ» ។

**ចូអាណា រ៉េបេកា ម៉ាន់សុន**

# ស្វែងរកប្អូនប្រុស

នាងខ្ញុំឈ្មោះ អេង គ្រី ភេទស្រី អាយុ៧៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្វាយជ្រូ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល ។ ឪពុកឈ្មោះ អេង និងម្តាយឈ្មោះ ប៊ុក គាត់ទាំងពីរនាក់ស្លាប់ហើយ ។




នាងខ្ញុំមានប្អូនប្រុសម្នាក់ឈ្មោះ អេង ម៉ាក ហៅវ៉ែន កើតនៅក្នុងភូមិស្វាយជ្រូ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល បច្ចុប្បន្នមានអាយុប្រហែល៧៧ឆ្នាំ ។ បើតាមឯកសារប្រវត្តិរូបដែលបុគ្គលិក មជ្ឈមណ្ឌលឯកសារកម្ពុជាប្រគល់មកឲ្យខ្ញុំបានសរសេរថាៈ អេង ម៉ាក ហៅវ៉ែន មានឪពុកឈ្មោះ អេង(ស្លាប់) និងម្តាយឈ្មោះ ប៊ុក (ស្លាប់) ហើយមានប្រពន្ធឈ្មោះ សាយ ហៅ រៀម កើតនៅក្នុងភូមិកែង ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសប់ ខេត្តក្រចេះ និងមានកូនប្រុសម្នាក់ ស្រីពីរនាក់ នៅក្នុងឆ្នាំ១៩៧៦ ។ អេង ម៉ាក កាលមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បានបម្រើការនៅការដ្ឋានមួយនៅក្នុងខេត្តសៀមរាប នាទីទទួលខាងលោកសង្ឃ ។ ហើយក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ មាននាទីប្រធានមន្ទីរតំបន់៤៣នៅខេត្តកំពង់ធំ ។ នៅក្នុងប្រវត្តិរូបនេះក៏បានបញ្ជាក់ថា អេង ម៉ាក ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៦ នៅមន្ទីរភូមិភាគក្នុងខេត្តកំពង់ចាម យកមកដាក់គុកទួលស្លែងក្នុងផ្ទះខ បន្ទប់ធំ២ បន្ទប់តូចលេខ៥ ។

តាមរយៈឯកសារប្រវត្តិនេះ ខ្ញុំចង់សួររកប្រពន្ធព្រមទាំងកូន៣នាក់ទៀតរបស់ អេង ម៉ាក ប្រសិនបើរស់កន្លែងណាក៏ដោយហើយបានដឹងដំណឹងនេះសូមទាក់ទងតាមរយៈ÷ ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារលេខ (៨៥៥) ២៣ ២១០ ៣៥៨ **Email: dccam@online.com.kh** ឬមកសួររកនាងខ្ញុំ អេង គ្រី ដែលជាបងស្រីបង្កើតរបស់ អេង ម៉ាក នៅក្នុងភូមិស្វាយជ្រូ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល ។ ពីមុនមកខ្ញុំមិនដឹងថា អេង ម៉ាក នេះមានប្រពន្ធកូន អីចឹងទេ ទើបតែបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះមកសួររកឈ្មោះនេះតាមរយៈឯកសារប្រវត្តិរូបដែលតាំងពីជំនាន់ខ្មែរក្រហមមក ទើបខ្ញុំបានដឹងថាប្អូនប្រុសរបស់ខ្ញុំឈ្មោះ អេង ម៉ាក មានប្រពន្ធនិងកូន ។ ដូច្នេះដោយចិត្តនឹកស្រឡាញ់បងប្អូនហើយចង់ដឹងដំណឹងពីសុខទុក្ខគ្នា បើអស់លោកអ្នកណាបានស្គាល់ឈ្មោះដូចខាងលើ ឬសាមីខ្លួនផ្ទាល់មេត្តាសូមមកទាក់ទងតាមអាសយដ្ឋានដូចខាងលើដោយក្តីមេត្តានិងអនុគ្រោះផងចុះ ។ សូមអរគុណ ។

# ស្វែងរកក្រុមក្មួយៗ

នាងខ្ញុំឈ្មោះ យូ សុខ អាយុ៤៨ឆ្នាំ កើតនៅក្នុងភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល បច្ចុប្បន្នរស់នៅក្នុងភូមិឃុំដដែល ។ ឪពុកឈ្មោះ ហេ ម្តាយឈ្មោះ ប្រាំងស ។ ខ្ញុំមានបងប្អូនទាំងអស់៦នាក់ ។ ប្អូនប្រុសម្នាក់ឈ្មោះ យូ ប៉េងគ្រី និងប្រពន្ធឈ្មោះ គីម ហ៊ាង បានស្លាប់នៅក្នុងគុកទួលស្លែង ។ កាលនោះខ្ញុំបានដឹងថា ប៉េងគ្រី មានកូន៥ឬ៦នាក់ កូនស្រីច្បង ឈ្មោះ សុខ អេង កូនស្រីទីពីរឈ្មោះ សុខ ណា កូនស្រីទីបីឈ្មោះ ចិន្តា និងកូនប្រុសម្នាក់ឈ្មោះ ប្រុស ។

បច្ចុប្បន្ននេះខ្ញុំមិនដឹងថាក្មួយៗទាំងអស់ស្លាប់ឬរស់ ហើយរស់នៅទីកន្លែងណាទេ ។ ប្រសិនបើក្មួយទាំងអស់ដូចមានឈ្មោះខាងលើបានទទួលដំណឹងនេះឬអស់លោកណាបានដឹង សូមមេត្តាទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ÷ ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារលេខ (៨៥៥) ២៣ ២១០៣៥៨ **Email: dccam@online.com.kh** ឬទាក់ទងមកនាងខ្ញុំផ្ទាល់ឈ្មោះ យូ សុខ នៅក្នុងភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ។

សូមអរគុណ ។



ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនិងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ពត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of *Searching for the Truth!*. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 45, September 2003.**
**Funded by Norway, Sweden, Switzerland, the Netherlands, Canada and USA.**